សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំទីក្រុងសិង្ហបុរី និងរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **អ៊្លង ចេងឡុង**

កញ្ញា **កៅ សុគន្ធា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **អ៊ុន សត្ថកដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

## សេចក្តីថ្លែងអំណរគុណ

❋❋❋

ក្រុមខ្ញុំទាំងពីរជានិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រុម L4A1 ជំនាន់ទី ១៧ ឆ្នាំសិក្សា ២០១៦-២០១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចផ្នែកនីតិសាស្រ្ត។

សូមសំដែងនូវគារវកិច្ចគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការចំពោះ៖

**លោក ឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើតដល់រូបយើងខ្ញុំ ហើយដោយលោកអ្នកមានគុណទាំងពីរ បានខិតខំតស៊ូពុះពារគ្រប់ឧបសគ្គក្នុងការចញ្ចឹមបីបាច់ ថែរក្សា អប់រំ ប្រៀនប្រដៅ និងផ្គត់ផ្គង់ កូនគ្រប់បែបយ៉ាងទាំងសម្ភារៈ និងស្មារតី រហូតកូនទទួលបានលទ្ធផលជាផ្លែផ្កាពិសេស ទៅទៀតលោកទាំងពីរថែមទាំងបានជម្រុញកូនឲ្យក្លាយជាសសរទ្រូងរបស់ប្រទេសជាតិ ជាធនធានមនុស្សសម្រាប់សង្គម ។ មហាគុណដែលលោកទាំងពីរបានផ្តល់ គឺជាវត្ថុដែលមានតម្លៃដែលមិនអាចកាត់ថ្លៃបានហើយគ្មានថ្ងៃដែលកូនតបស្នងគុណវិញអស់ឡើយ ។

**លោក សាស្រ្តាចារ្យ បណ្ឌិត អ៊ុន សកក្កដា** គឺជាសាស្រ្តចារ្យម្នាក់ ដែលប្រកបដោយគតិបណ្ឌិត លោកបានផ្តល់ជាអនុសាសន៍ដ៏មានតម្លៃ សម្រាប់ដឹកនាំក្រុមសារណារបស់ក្រុមខ្ញុំទាំងពីរអោយ សម្រេចនូវភាពជោគជ័យជាមួយ នឹងឯកសារជាច្រើនដែលលោកបានផ្តល់ជាគ្រឹះក្នុងការចងក្រងសារណានេះ។

**លោក លោកស្រី សាស្រ្តាចារ្យ និងបុគ្គលិក** ទាំងអស់ដែលស្ថិតក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ដោយ **ឯកឧត្តម លោក លោកស្រី**បានផ្តល់ជាដំបូន្មានដ៏មានសារៈសំខាន់ដើម្បីជាគំនិតចងក្រងជាប្លង់ឲ្យមានកម្រិតស្តង់ដា ។

ក្រុមយើងខ្ញុំដែលមានសមាជិកពីរនាក់ សូមបន្ទន់កាយលើកដៃប្រណមបួងសួងដ៏ស្មោះអស់ពីដួងចិត្តសូមទេវតាថែរក្សាលោកយើងនេះមេត្តាជួយថែរក្សា **លោកអ្នកមានគុណទាំងពីរ និង លោកសាស្រ្តាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ប្រកបតែសេចក្តីសុខចម្រើន មានសុខភាពល្អ ជាម្លប់នូវភាពកក់ក្តៅនិងភាពក្សេមក្សាន្តចំពោះកូនៗក៏ដូចជានិស្សិតគ្រប់ជំនាន់ជានិច្ចតរៀងទៅ ។

# អារម្ភកថា

❁❁❁

គ្រប់បណ្តាប្រទេសទាំងអស់លើសាកលលោក គឺតែងតែមាននូវប្រវត្តិសាស្ត្រនៃការកកើតរបស់ប្រទេសក៏ដូចជាដើមកំណើតរបស់ខ្លួនតជាប់រហូតមកដល់ពេលបច្ចុប្បន្ន ។ ដើម្បីឲ្យស្របទៅ និងពាក្យថាការសិក្សាមិនចេះមានទីបញ្ចប់ដូចនេះក្រុមខ្ញុំទាំងពីរសុំលើកយកប្រទេសចំនួន២ មកធ្វើការសិក្សាអំពីការរៀបចំក្រុងក៏ដូចជាប្រវត្តិនៃការរៀបចំក្រុងរបស់ប្រទេសទាំងពីរនោះដែលក្នុងនោះរួមមាន៖ ប្រទេសកម្ពុជានិងប្រទេសសិង្ហបុរីចំពោះប្រទេសកម្ពុជាក្រុមខ្ញុំទាំងពីរ នឹងលើកយកទីក្រុងភ្នំពេញ ចំណែកប្រទេសសិង្ហបុរី ក្រុមខ្ញុំទាំងពីរ នឹងលើកយក ទីក្រុងសិង្ហបុរី មកធ្វើជាប្រធានបទស្រាវជ្រាវ។ មូលហេតុដែលក្រុមខ្ញុំទាំងពីរលើកយកទីក្រុងនៃប្រទេសចំនួន២នេះ យកមកធ្វើការសិក្សាស្រាវជ្រាវគឺដើម្បីឲ្យបានឃើញនូវចំនុចល្អ និង ចំនុចខ្វះខាតរបស់ក្រុងនៃប្រទេសទាំងពីរដើម្បីយកមកធ្វើការប្រៀបធៀបក្នុង គោលបំណងធ្វើឲ្យមានការរីកចំរើនក្នុងការសិក្សាឲ្យកាន់តែទូលាយ ។

ជាក់ស្តែងព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយដែលស្ថិតនៅលើជ្រោយឥណ្ឌូចិន និងធ្លាប់ទទួលកិត្តិយសខ្ទរខ្ទារនៅក្នុងទ្វីបអាស៊ីអាគ្នេយ៍នាសម័យអង្គរដ៏រុងរឿង ។ ជាអកុសលកម្ពុជាបានធ្លាក់ចូលទៅក្នុងសង្គ្រាមជាច្រើនលើកច្រើនសារបណ្តាលឲ្យជះឥទ្ធិពលដល់ការអភិវឌ្ឍប្រទេសយ៉ាងខ្លាំង ។ ហើយជាមូលហេតុនាំឲ្យសាលាក្រុងភ្នំពេញ ទទួលប្រតិភូកម្មអំណាចពីសំណាក់រាជរដ្ឋាភិបាល និងបានធ្វើការខិតខំយ៉ាងខ្លាំងក្នុងការកសាង នឹងអភិវឌ្ឍទីក្រុងភ្នំពេញដែលជាបេះដូងនៃប្រទេសជាតិឲ្យមានភាពរីកចម្រើនយ៉ាងខ្លាំងស្ទើរគ្រប់វិស័យនាចុងទស្សវត្សរ៍នេះ ។

ចំពោះប្រទេសសិង្ហបុរី (ឬសាំងហ្គាពួរ) ដែលទីក្រុងរបស់ប្រទេសនេះគឺឈ្មោះសិង្ហបុរី ក៏ព្រោះក្នុងនាមជារដ្ឋមួយនៃប្រទេសសិង្ហបុរី និងជារាជធានីរបស់ប្រទេសតែម្តង។ ហើយជាប្រទេសកោះដែលស្ថិតនៅចុងខាងត្បូងនៃឧបទ្វីបម៉ាឡេ និងជាប្រទេសតូចជាងគេនៅអាស៊ីអាគ្នេយ៍ក៏ប៉ុន្តែប្រទេសនេះជាមជ្ឈមណ្ឌលហិរញ្ញវត្ថុឈានមុខគេចំណាត់ថ្នាក់លេខ ៤ នៅលើពិភពលោក ដែលដើរតួនាទីយ៉ាងចំបងក្នុងវិស័យពាណិជ្ជកម្ម និងហិរញ្ញវត្ថុអន្តរជាតិ នឹងមានកំពង់ផែដ៏មមាញឹកជាងគេទាំង ៥នៅលើពិភពលោក ដែលជាលទ្ធផលនៃការខិតខំប្រឹងប្រែងកសាង និងអភិវឌ្ឍន៍របស់អ្នកដឹកនាំ ។

ដើម្បីរួមចំណែកសំដែងនូវភាពត្រេកអរដេតឧបមានូវសមិទ្ធិផលទាំងឡាយ ដែលបានសម្រេច និងយន្តការបន្តនានាក្នុងការអភិវឌ្ឍន៍ និងរៀបចំទីក្រុងរបស់ប្រទេសទាំងពីរខាងលើ ក្រុមខ្ញុំទាំងពីរបានមូលមតិគ្នាសរសេរសារណាស្តីអំពី "**ការរៀបចំទីក្រុងសិង្ហបុរី និងរាជធានីភ្នំពេញ**" ដើម្បីទុកជាស្នាដៃដ៏ពិសិទ្ធិមិនអាចកាត់ថ្លៃបានរបស់ថ្នាក់ដឹកនាំអភិវឌ្ឍក៏ដូចជាផ្តល់នូវព័ត៌មាន និងចំណេះដឹងទុកជាទុននាំ ផ្លូវអ្នកសិក្សាឲ្យជ្រួតជ្រាបក្នុងកិច្ចសិក្សាស្រាវជ្រាវ ។

ដូច្នេះស្នាដៃដ៏ក្មេងខ្ចីដែលប្រសូតចេញពី កិច្ចប្រឹងប្រែងនេះពិតជាមានកង្វះខាតដោយប្រការណាមួយដោយអន្លើជាពុំខាន ។ ក្រុមរបស់ខ្ញុំបាទរងចាំទទួលនូវការកែលម្អដោយបេតិសោមនស្សរីករាយពីគ្រប់មជ្ឈដ្ឋានសំដៅធ្វើយ៉ាងណាឲ្យស្នាដៃដ៏តូចមួយនេះ នឹងក្លាយទៅជាស្នាដៃដែលមិនអាចខ្វះបានសម្រាប់តម្រូវការនិស្សិតជំនាន់ក្រោយ ។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ............ ១
**ជំពូកទី ១ ទីក្រុងភ្នំពេញ** ............ ៣
**១.១ ទិដ្ឋភាពទូទៅនៃទីក្រុងភ្នំពេញ** ............ ៣
១.១.១ ប្រវត្តិសាស្ត្រទីក្រុងភ្នំពេញ ............ ៣
១.១.២ ភូមិសាស្ត្រទីក្រុងភ្នំពេញ ............ ៥
**១.២ មូលហេតុនាំឲ្យមានការរៀបចំទីក្រុងភ្នំពេញ** ............ ៦
១.២.១ ប្រជាសាស្ត្រ ............ ៦
ក. ប្រជាជន រចនាសម្ព័ន្ធ និងការវិវត្ត ការសង្កេត ............ ៦
ខ. វិធីសាស្ត្រ ............ ៦
១.២.២ លំនៅស្ថាន ............ ៨
ក. វិធីសាស្ត្រ ............ ៨
ខ. គោលនយោបាយលំនៅស្ថានដឹកនាំដោយសាលាក្រុង ............ ៩
១.២.៣ សេដ្ឋកិច្ច ............ ១១
ក. គោលនយោបាយសេដ្ឋកិច្ច ............ ១២
ខ. វិធីសាស្ត្រ ............ ១៣
**១.៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍរាជធានីភ្នំពេញ** ............ ១៥
១.៣.១ ប្លង់គោលរាជធានីភ្នំពេញ ............ ១៦
ក. ភ្នំពេញ ជាបេតិកភណ្ឌក្រុង រមណីយដ្ឋាន និងទេសភាព ............ ១៨
ខ. ភ្នំពេញជារាជធានីអេកូឡូហ្ស៊ីដែលគោរពបរិស្ថាន ............ ១៩
១.៣.២ បណ្តាញដឹកជញ្ជូនសាធារណៈ ............ ១៩
ក. ការអភិវឌ្ឍន៍រចនាសម្ព័ន្ធដែលមានស្រាប់ ............ ២០
ខ. រៀបចំបង្កើត ចំណតរថយន្ត និងចំណតរថយន្តសាធារណៈ ............ ២២
ខ.១ រៀបចំណតរថយន្ត ............ ២២
ខ.២ រៀបចំណតរថយន្តសាធារណៈ ............ ២៣
**ជំពូកទី២ ទីក្រុងសិង្ហបុរី** ............ ២៦
**២.១ ទិដ្ឋភាពទូទៅនៃទីក្រុងសិង្ហបុរី** ............ ២៦
២.២.១ ប្រវត្តិទីក្រុងសិង្ហបុរី ............ ២៦
២.១.២ ភូមិសាស្ត្រទីក្រុងសិង្ហបុរី ............ ២៩
២.១.៣ ការគ្រប់គ្រងប្រទេសសិង្ហបុរី និង ប្រព័ន្ធនយោបាយដឹងនាំរដ្ឋ ............ ៣០

ក.ការបែងចែកអំណាច៣ក្នុងការគ្រប់គ្រងរដ្ឋ......៣០
ក.១ ស្ថាប័នអំណាចនីតិប្បញ្ញត្តិ......៣១
ក.២ ស្ថាប័ននីតិប្រតិបត្តិ......៣១
ក.៣ ស្ថាប័នអំណាចតុលាការ......៣១
ខ ប្រព័ន្ធនយោបាយដឹកនាំ......៣១
ខ.១ បរិយាកាសនយោបាយក្នុងទីក្រុងសិង្ហបុរី......៣២
ខ.២ អំពីសភានៃទីក្រុងសិង្ហបុរី......៣២
ខ.៣ ដំណើរការនៃការរៀបចំច្បាប់នៃសាធារណរដ្ឋសិង្ហបុរី......៣៣
**២.២ អំពីការរៀបចំក្រុងសិង្ហបុរី......៣៣**
២.២.១ស្ថានភាពសេដ្ឋកិច្ចនៃទីក្រុងសិង្ហបុរី......៣៣
២.២.២ ការកសាងផែនការសម្រាប់រយៈពេលវែង......៣៤
២.២.៣ ផែនការរបស់ទីក្រុងសិង្ហបុរី......៣៥
ក ផែនការរៀបចំផ្ទះសម្បែង និងការគ្រប់គ្រងដីធ្លីក្រុង......៣៥
ខ គុណភាពរស់នៅប្រកបដោយផាសុខភាព......៣៦
២.២.៤ គោលនយោបាយរៀបចំក្រុងសិង្ហបុរី......៣៦
**២.៣ អភិបាលកិច្ចល្អនៃក្រុងសិង្ហបុរី......៣៧**
២.៣.១ គោលការកិច្ចល្អនៃទីក្រុងសិង្ហបុរី......៣៧
២.៣.២ បញ្ហាប្រឈមប្រឈមក្នុងការរៀបចំទីក្រុងសិង្ហបុរី......៣៨
២.៣.៣ សកម្មភាពប៉ះពាល់ដែលត្រូវដោះស្រាយក្នុងទីក្រុងសិង្ហបុរី......៣៩
ក. ការប្រើប្រាស់និងរៀបចំដីធ្លីក្នុងទីក្រុងសិង្ហបុរី......៣៩
ខ. ការប្រើប្រាស់មធ្យោបាយធ្វើដំណើរក្នុងទីក្រុងសិង្ហបុរី......៤០
គ. ការគ្រប់គ្រងប្រភពទឹកក្នុងទីក្រុសិង្ហបុរី......៤០
ឃ. ការគ្រប់គ្រងកាកសំណល់ក្នុងទីក្រុងសិង្ហបុរី......៤១
ង. សុខភាពបរិស្ថានក្នុងទីក្នុងទីក្រុងសិង្ហបុរី......៤១
ច. ការគ្រប់គ្រងសម្លេងកងរំពងរំខានក្នុងទីក្រុងសិង្ហបុរី......៤១
**សេចក្តីសន្និដ្ឋាន......៤៣**
**អនុសាសន៍......៤៤**
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

គ្រប់ទីក្រុងក្នុងប្រទេសទាំងអស់ក្នុងលោកមិនថានៅប្រទេសណានោះទេគឺតែងតែមានការរៀបចំ និងអភិវឌ្ឍដែលជាបំណងប្រាថ្នារបស់មេដឹកនាំ នឹងមនុស្សគ្រប់គ្នាដោយមើលឃើញពីផលប្រយោជន៍នៃការរៀបចំ និងការអភិវឌ្ឍន៍ដែលបាននាំមកនូវភាពល្អប្រសើរហូតមកទល់បច្ចុប្បន្ននេះ គឺឃើញថាមានការខុសប្លែកគ្នាយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំព្រមទាំងមានសភាពនៃការប្រែប្រួលឥតឈប់ឈរនៅគ្រប់ប្រទេសទាំងអស់ជាពិសេសគឺជីវភាពមនុស្ស និងសោភ័ណភាពក្នុងប្រទេសនីមួយៗ ។ ដោយស្របតាមការប្រែប្រួលនៃសកលភាវូបនីយកម្មនៅលើសកលលោកចេះតែលឿនទៅមុខ និងគ្រប់ទីកន្លែងសុទ្ធតែមានភាពទំនើបស៊ីវីល័យព្រមទាំងការជម្រុញពីគ្រប់មជ្ឈដ្ឋាន និងតម្រូវការចាំបាច់នៃសង្គមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងខិតខំយ៉ាងសស្រាក់សស្រាំដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍប្រទេសកម្ពុជាឲ្យសម្របខ្លួនទៅតាមភាពជឿនលឿននៃបណ្តាប្រទេសលើសកលលោក ។ ក្នុងនោះផងដែរជាជំហានដំបូងនៃការអភិវឌ្ឍក្នុងប្រទេសនីមួយៗគឺតម្រូវឲ្យមានការរៀបចំ និងអភិវឌ្ឍឲ្យចំចំនុចបេះដូងនៃប្រទេសដើម្បីសម្រួលល្បឿននៃការអភិវឌ្ឍឲ្យកាន់តែមានប្រសិទ្ធិភាពចំពោះប្រទេសកម្ពុជាវិញគេឃើញថារាជធានីភ្នំពេញជាគោលដៅចំបងក្នុងការធ្វើឲ្យមានការផ្លាស់ប្តូររូបរាងនៃប្រទេសទាំងមូល ។ ជាការពិតណាស់រាជធានីភ្នំពេញគឺជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា និងជាទីក្រុងធំជាងគេបំផុតនៃប្រទេសកម្ពុជាជាមជ្ឈមណ្ឌលសន្តិសុខ នយោបាយ សេដ្ឋកិច្ច វប្បធម៌ និងការទូត ។ មិនត្រឹមតែប៉ុណ្ណោះរាជធានីភ្នំពេញក៏មានប្រវត្តិដ៏ចំណាស់ផងដែរ ដែលត្រូវបានចាប់កំណើតឡើងនៅអំឡុងឆ្នាំ ១៣៧២ មកម្លេះហើយត្រូវបានជ្រើសរើសជារាជធានីនៅឆ្នាំ ១៤៣៤ តែរហូតមកដល់ ឆ្នាំ ១៨៦៤ ទើបលេចចេញជារូបរាងជាទីក្រុង និងបានចាប់ផ្តើម កសាងព្រះបរមរាជវាំងនៅឆ្នាំ ១៨៦៦ ដែលមានទ្រង់ទ្រាយរហូតមកដល់សព្វថ្ងៃក្រោមការចាត់ចែងរបស់ អ្នក ឧកញ៉ា ទេព និមិត្តម៉ាក់ ដោយបែរទៅទិសខាងកើតចំចំណុចប្រសព្វនៃទន្លេចតុមុខ ។ ភ្នំពេញមានទិដ្ឋភាពពេញលេញជាទីក្រុងពិតប្រាកដនៅឆ្នាំ ១៩១០ ដោយលាតសន្ធឹងតាមត្រើយខាងលិចដងទន្លេសាបដែលមានចរន្តទឹកហូរទៅមកយ៉ាងទៀតទាត់តាមរដូវកាល ។ ដែលជាប្រភពធនធានដ៏សំខាន់បំផុតរបស់ទីក្រុងតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្នធ្វើឲ្យមនុស្សជំនាន់ក្រោយបានរស់នៅលើទឹកដីមួយប្រកបដោយបរិស្ថានធម្មជាតិ និងមានវប្បធម៌សង្គមដ៏រុងរឿងរហូតរៀងមក ។ ក្នុងនោះរាជធានីត្រូវបានពង្រីកបន្តិចម្តងៗ ដោយសារការបូមដីពីក្នុងទន្លេចតុមុខមកចាក់បំពេញដែលក្រោយមកទំនប់ទឹកកាលពីមុនៗត្រូវបានក្លាយទៅជា ផ្លូវតូច ផ្លូវធំខ្លះជាមហាវិថីផងបន្ទាប់ពីទំនប់ថ្មីៗត្រូវបានពង្រីកជា លំដាប់លំដោយឆ្ពោះទៅគ្រប់ទិសទីជុំវិញរាជធានីហើយការពង្រីករាជធានីក៏មានជាប់រហូតមកដល់បច្ចុប្បន្ន ។ ជាក់ស្តែងរាជធានីភ្នំពេញមាន

ការកែសម្រួលដែនដីព្រំប្រទល់ជាបួនដំណាក់កាលក្រោយរបបប្រល័យពូជសាសន៍ប៉ុលពត។ ដំណាក់កាលទាំងបួននោះមានៈ

-លើកទី ១ ពីការបញ្ចូលស្រុកដង្កោ

-លើកទី ២ ការបង្កើតខណ្ឌឬស្សីកែវ

-លើកទី ៣ ការបញ្ចូល៩ ភូមិ របស់ឃុំកន្ទោក មកក្នុងដែនដីរដ្ឋបាលនៃរាជធានីភ្នំពេញ

-លើកទី ៤ ការបញ្ចូល២០ ឃុំ របស់ស្រុក ៥ ៖ ពញាឮ, មុខកំពូល,កៀនស្វាយ,កណ្ដាលស្ទឹង, និងអង្គស្នួលនៃខេត្តកណ្ដាលមកក្នុងដែនដីរាជធានីភ្នំពេញ ។ ដោយឃើញថារាជធានីភ្នំពេញមានការប្រព្រឹត្តទៅមិនចេះឈប់ឈរពីសម័យកាលមួយទៅសម័យកាលមួយ នឹងទទួលបាននូវការអភិវឌ្ឍលើគ្រប់វិស័យ ក៏ប៉ុន្តែដើម្បីឲ្យប្រទេស ក៏ដូចជាទីក្រុងមួយរឹតតែមានការជឿនលឿន និងរីកចម្រើន គឺប្រទេសនោះគួរតែទទួលយកនូវការអភិវឌ្ឍ និងរៀបចំប្រព័ន្ធល្អៗពីប្រទេសជិតខាងដើម្បីឲ្យការរៀបចំនិងអភិវឌ្ឍន៍កាន់តែល្អប្រសើរ និងរីកចំរើនទៅមុខយ៉ាងឆាប់រហ័សដូចជា ប្រទេសសិង្ហបុរី គឺជាប្រទេសកោះតូចមួយដែលមានប្រជាជនចំនួន៥,១៨៣,៧០០និងមានផ្ទៃដីត្រឹមតែ ៧០៤គ.ម[២] និងជាប្រទេសដែលខ្វះធនធានធម្មជាតិ ។ ចំពោះទីក្រុងវិញគឺជាប្រទេសសិង្ហបុរីតែម្ដងគឺបានន័យថាប្រទេសសិង្ហបុរីមានទីក្រុងតែមួយគត់គឺទីក្រុងសិង្ហបុរីដែលជាប្រទេសកោះ ។ ជាក់ស្ដែងកោះដែលជាប្រទេសសិង្ហបុរីបច្ចុប្បន្នគឺជាកោះរបស់ចក្រភពស្ស៊ូម៉ាត្រានស្រីវិចាយ៉ា ដែលគេហៅថាជាទីក្រុងសមុទ្រ ។ ចំពោះការបង្កើតជារូបរាងពិតប្រាកដគឺនៅថ្ងៃ ៦ កុម្ភៈ ឆ្នាំ ១៨១៩ ទទួលបានឯករាជ្យពីអង់គ្លេសជាឯកត្តោភាគគឺនៅថ្ងៃ ទី ៣១ ខែ សីហា ឆ្នាំ ១៩៦៣ បន្ទាប់មកទៀតក៏ចូលជាសមាជិក សហព័ន្ធ ម៉ាឡេស៊ី តែដោយសារតែមានការខ្វែងគំនិតក៏ចាកចេញពីសហព័ន្ធម៉ាឡេស៊ីវិញទទួលបានអធិបតេយ្យជាផ្លូវការនៅថ្ងៃទី ៨ សីហា ១៩៦៥ ។ បន្ទាប់ពីការចាក់ចេញពីសហព័ន្ធមកឃើញថាប្រទេស សិង្ហបុរី ជួបជាមួយនឹងបញ្ហាជាច្រើន ។ ឃើញបែបនេះរាជរដ្ឋាភិបាលក៏ចេញនូវផែនការរៀបចំ និងអភិវឌ្ឍប្រទេសរបស់ខ្លួនឡើងវិញតាមផែនការដែលបានកំណត់ នឹងត្រូវអនុវត្តន៍ឲ្យបានជោគជ័យ ។

# ជំពូកទី ១

# ទីក្រុងភ្នំពេញ

# ជំពូកទី ១ ទីក្រុងភ្នំពេញ

ភ្នំពេញ គឺជារាជធានីរបស់ព្រះរាជាណាចក្រកម្ពុជាហើយជាទីក្រុងដែលធំជាងគេនឹងសំខាន់ជាងគេនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ហើយប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋានតែងតែប្រាថ្នាបានមកទស្សនាទីក្រុងនេះយ៉ាងហោចណាស់ឲ្យបានម្តងក្នុងមួយជីវិត[1] ។ ទន្ទឹម នឹងនេះផងដែរគេតែងតែសសើរថាទីក្រុងភ្នំពេញគឺជាទីក្រុងគុជនៅក្នុងតំបន់ឥណ្ឌូចិន[2] និងជារាជធានីដ៏ចំនាស់មួយនៅអាស៊ី និងមានទីតាំងនៅចំណុចប្រសព្វបួនមុខនៃទន្លេមេគង្គ[3] និងជាទីក្រុងដែលជាមជ្ឈមណ្ឌលធ្វើជំនួញពាណិជ្ជកម្ម និងឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជា ។ ហើយជាទីក្រុងដែលមានការអភិវឌ្ឍន៍ជឿនលឿនទាំងធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធដែលរីកដុះដូចផ្សិតនឹងជាថ្នាល់នៃធនធានមនុស្សដែលទីក្រុងនេះមានសកលវិទ្យាល័យ[4]ច្រើនជាងគេសំរាប់សិស្សានុសិស្សសិក្សារៀនសូត្រ និងជាបណ្តុំនៃការងារច្រើនជាងគេក្នុងប្រទេសកម្ពុជា ហើយរដ្ឋាភិបាលកម្ពុជាក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើយុវជនទាំងគ្រប់វិស័យផងដែរ ។ បើគិតពីចំនួនប្រជាជនក្នុងប្រទេសកម្ពុជាវិញគេឃើញថាទីក្រុងភ្នំពេញគឺជាទីក្រុងដែលមានប្រជាជនរស់នៅច្រើនជាងគេបើគិតដល់បច្ចុប្បន្ន និងប្រជាជនដែលត្រូវបានធ្វើការស្មានទុកមុនក្នុងឆ្នាំ២០១៨ នឹងមានរហូតដល់ទៅ ១.៨៨៥.៨៨៨ នាក់ដែលក្នុងនោះមានស្រីចំនួន ៧៦៥.៩៦៦[5]នាក់ ។ ហើយក៏ជាទីក្រុងដែលរាជរដ្ឋាភិបាលយកចិត្តទុកដាក់[6]ផងដែរ ។

## ១.១ ទិដ្ឋភាពទូទៅនៃទីក្រុងភ្នំពេញ

### ១.១.១ប្រវត្តិសាស្ត្រទីក្រុងភ្នំពេញ

ក្នុងកាលកន្លងទៅហើយ (គ.ស១៣៧២) មានដូនចាស់ម្នាក់ឈ្មោះ ”ពេញ” ជាអ្នកមានភោគសម្បត្តិបរិបូរណ៍មានលំនៅក្បែរច្រាំងទន្លេបួនមុខ ។ ផ្ទះរបស់គាត់សង់នៅលើទួលខាងកើតភ្នំតូចមួយក្នុងថ្ងៃមួយទីនោះស្រាប់តែឃើញ ដើមគគីរមួយធំអណ្តែតមកក្បែរច្រាំងហើយដោយអំណាចទឹកហូរចុះឡើងដើមគគីរនោះចេះតែអណ្តែតវិលវល់នៅក្បែរច្រាំងនោះ ។ លុះដូនពេញឃើញដូច្នេះក៏ប្រញាប់ទៅអំពាវនាវហៅអ្នកជិតខាងឲ្យមកជួយទាញយកដើមគគីរនោះឡើង ។ អ្នកជិតខាងក៏នាំ

---

[1] https://www.everyday.com.kh/article/30152.html

[2] http://www.tourismcambodia.com/travelguides/provinces/phnom-penh.htm

[3] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ ( ទំព័រ ១៧)

[4] សូមមើលរូបភាពឧបសម្ព័ន្ធទិ ១ និង ២

[5] សៀវភៅ ព្រឹត្តិបត្រ រដ្ឋបាលរាជធានីភ្នំពេញ ( សូមមើលឧបសម្ព័ន្ធរូបភាព ទី៣)

[6] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ ២០១២-២០១៣

គ្នាយកឰរទៅចងហើយអូសរំកិលបន្តិចម្តងៗទាល់តែមកដល់មាត់ច្រាំង ។ ពេលនោះដូនពេញយកកំណាត់ឈើទៅកោសកៀរលាងសំអាតភក់ចេញហើយគាត់ ក៏បានឃើញក្នុងប្រហោងឈើគគីរមានព្រះពុទ្ធរូប ៤ អង្គតូចៗធ្វើអំពីសំរិទ្ធិ និងទេវរូបមួយអង្គទៀតធ្វើអំពីថ្ម ។ ទេវរូបនោះទ្រង់ឈរព្រះហស្តម្ខាងទ្រង់ដំបងព្រះហស្តម្ខាងទៀតទ្រង់ស័ង្ខព្រះកេសាបួង ។ ដូនពេញ និងអ្នកជិតខាងដែលទៅជួយមានសេចក្តីត្រេកអរណាស់ ដោយរើសបានរបស់ជាទីគោរពក៏នាំគ្នាដង្ហែព្រះបដិមាករទាំងនោះមកដល់ផ្ទះដូនពេញហើយដូនពេញចាត់ការសង់ខ្ទមមួយតូចតម្កល់ជាបណ្តោះអាសន្ន។

ថ្ងៃក្រោយមកដូនពេញអំពាវនាវឲ្យអ្នកជិតខាងជួយលើកដីពូនភ្នំដែលនៅខាងលិចផ្ទះរបស់គាត់នោះឲ្យទៅជាភ្នំមែនទែន ។បន្ទាប់ពីនោះគាត់អោយគេអារឈើគគីរនោះធ្វើជាសសរវិហារដែលគាត់បំរុងសង់លើភ្នំនោះ។

ក្នុងគ.ស ១៣៧២ ដូនពេញនិងអ្នកស្រុកជាច្រើននាក់បានស្រុះស្រួលបបួលគ្នាសាងសង់ព្រះវិហារមួយខ្ទង់ប្រក់ស្បូវតាំងនៅលើកំពូលភ្នំដែលអ្នកស្រុកបានយកដីពូនហើយគាត់ក៏នាំគ្នាដង្ហែព្រះពុទ្ធរូបសំរិទ្ធិទាំង៤អង្គទៅតំកល់ទុកក្នុងវិហារនោះ ។ ចំណែកទេវរូបថ្មមួយអង្គគាត់បានដង្ហែទៅតំកល់ទុកនៅលើអសនៈមួយនៅជើងភ្នំខាងកើត ហើយដោយគាត់យល់ថាទេវរូបនោះអណ្តែតទឹកមកពីស្រុកលាវ និង មានភាពដូចជាលាវគាត់ក៏បានសន្មត់នាមថា "អ្នកតាព្រះចៅ" នាមនោះតជាប់រហូតមកដល់សព្វថ្ងៃនេះ ។ កាលសាងសង់វិហាររួចហើយគាត់និមន្តព្រះសង្ឃមកគង់នៅលើជើងភ្នំនោះនៅទិសខាងលិចទើបមានឈ្មោះថា "វត្តភ្នំដូនពេញ" ដែលសព្វថ្ងៃហៅកាត់ថា "វត្តភ្នំ" តាំងពីពេលនោះមករហូតមកដល់សព្វថ្ងៃ។

រាជធានីភ្នំពេញត្រូវបានសាងសង់ជាលើកដំបូងនៅក្នុង សតវត្សរ៍ទី១៥ ក្នុងអំឡុងពេលរជ្ជកាលព្រះបាទស្រីសុរិយោព័រ (ពញាយ៉ាត) នៅពេលដែលព្រះអង្គបានបោះបង់ចោលរាជធានីអង្គរហើយបានមកសាងសង់រាជធានីថ្មីមួយទៀតនៅទួលបាសានក្នុង ខេត្តស្រីសឈរដែលសព្វថ្ងៃត្រូវបានគេស្គាល់ថាជាស្រុកស្រីសន្ធរខេត្តកំពង់ចាម ។ ព្រះអង្គបានគង់នៅទីនោះបានតែមួយឆ្នាំគត់ដោយសារតែមានទឹកជំនន់រាល់រដូវវស្សា ព្រះអង្គបានផ្លាស់ប្តូររាជធានីហើយបានមកសាងសង់រាជធានីថ្មីមួយទៀតតាមបណ្តោយមាត់ទន្លេចតុមុខ (ទន្លេមុខបួន) នៅក្នុងឆ្នាំ ១៤៣៤ ដែលសព្វថ្ងៃជារាជធានីភ្នំពេញ។

**ការសាងសង់ព្រះបរមរាជវាំងនៅរាជធានីភ្នំពេញមាន២លើក ៖**

- លើកទី១ ៖ ក្នុងរជ្ជកាលព្រះបាទពញាយ៉ាតក្នុងសតវត្សរ៍ទី ១៥ ។
- លើកទី២ ៖ ក្នុងរជ្ជកាលព្រះបាទនរោត្តមក្នុងសតវត្សរ៍ទី ១៩ ទើបបិតបេរ។

ការសាងសង់ព្រះបរមរាជវាំងនៅរាជធានីភ្នំពេញមាន ២ លើកដោយសារតែបន្ទាប់ពីការសាងសង់លើកទី១ (ឆ្នាំ១៤៣៤-១៤៩៧) រាជវាំងត្រូវបានផ្លាស់ទៅក្រុងអង្គរវិញក្រោយពីក្រុងអង្គរបានបន្តទៅពោធិសាត់រួចទៅបរិបូរណ៍ បន្ទាប់មកទៅលង្វែកហើយទៅឧដុង្គ ។ បន្ទាប់ពីឧដុង្គរាជវាំងត្រូវបានត្រឡប់មកសាងសង់ជាលើកទី២នៅរាជធានីភ្នំពេញក្នុងឆ្នាំ ១៨៦៥ ហើយទើបបានបិតបេរមកដល់សព្វថ្ងៃ។[7]

### ១.១.២ភូមិសាស្ត្រទីក្រុងភ្នំពេញ

ភ្នំពេញស្ថិតនៅក្នុងតំបន់ប៉ែកខាងត្បូងកណ្តាល នៃប្រទេសកម្ពុជានៅត្រង់ចំណុចប្រសព្វនៃទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់[8] ។ ទន្លេទាំងនេះផ្តល់នូវប្រព័ន្ធអេកូឡូស៊ីទឹកសាប និង ទន្លេប្រកបដោយសក្តានុពល និងជាធនធានធម្មជាតិដ៏សំខាន់សម្រាប់លក្ខខណ្ឌបរិស្ថានប្រកប ដោយចរិភាព ជាមួយសោភ័ណភាពធម្មជាតិ និងវប្បធម៌ប្រកបដោយភាពចម្រុងចម្រើនសម្រាប់ប្រជាជននៅរាជធានីភ្នំពេញតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន ។

ភ្នំពេញស្ថិតនៅចំពីមុខទន្លេមេគង្គ[9] ដែលជាទន្លេដ៏សំខាន់នៅក្នុងតំបន់អាស៊ីមានបណ្តោយប្រវែង ៤.២០០ គីឡូម៉ែត្រ (២៦១០ម៉ាយ) ។ ប្រភពដើមនៃទន្លេនេះគឺមកពីតំបន់ខ្ពង់រាបទីបេប្រទេសចិន ។ ទន្លេនេះហូរកាត់ប្រទេសកម្ពុជាពីជើងទៅត្បូងមានបណ្តោយសរុបប្រវែង៤៨៦គីឡូម៉ែត (៣០២ ម៉ាយ) ហើយហូរកាត់ភូមិសាស្ត្ររាជធានីភ្នំពេញដែលជាចំណុចប្រសព្វទន្លេបួនមុខបង្កើតបាននូវប្រព័ន្ធអេកូឡូស៊ី និងទឹកសាបដ៏គួរឲ្យទាក់ទាញសម្រាប់រាជធានីភ្នំពេញ។

ចំពោះអាកាសធាតុគឺក្តៅពេញមួយឆ្នាំដោយគ្រាន់តែមានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ។ នៅក្នុងរាជធានីភ្នំពេញកម្រិតសីតុណ្ហាភាពមានចាប់ពី ១៨អង្សារសេ ដល់ ៣៨អង្សាសេ (៦៤ដល់ ១០០អង្សារហ្វារិនហាយ )។

[7] http://phnompenh.gov.kh/phnom-penh-city/history/
[8] ឧបសម្ព័ន្ធរូបភាព ទី ៤
[9] ឧបសម្ព័ន្ធរូបភាព ទី៥

ចំពោះរដូវក្នុងរាជធានីភ្នំពេញមានចំនួន២គឺៈ

-រដូវប្រាំងចាប់ពីខែ ធ្នូ ដល់ខែ ឧសភា (រយៈពេល ៦ ខែ)

-រដូវវស្សាចាប់ពីខែ មិថុនា ដល់ខែ វិច្ឆកា (រយៈពេល ៦ ខែ)

## ១.២ មូលហេតុនាំឲ្យមានការរៀបចំទីក្រុងភ្នំពេញ

### ១.២.១ ប្រជាសាស្ត្រ

អាត្រាប្រជាជនភ្នំពេញទទួលបានមានចំនួន ១,៥០១,៧២៥ លាននាក់ ដែរស្មើនឹង ១០%នៃអាត្រាប្រជាជនសរុបទូទាំងប្រទេសដែលមានចំនួនគ្រួសារសរុប ២៩៥.៣៥៨ គ្រួសារ និងមានដង់ស៊ីតេចំនួន ២,២១៣នាក់ក្នុងមួយគ.ម²នេះជាចំនួនដ៏ខ្ពស់ប្រសិនបើធៀបទៅនឹងបណ្ដារខេត្តផ្សេងៗទូទាំងប្រទេសកម្ពុជា ។ បើក្រឡេកមើលផ្នែកសាសនានៅក្នុងក្រុងភ្នំពេញមាន ៩៦.៤% ជាអ្នកកាន់ព្រះពុទ្ធសាសនាក្នុងខណៈពេលដែលព្រះរាជាណាចក្រកម្ពុជាមានអ្នកកាន់ពុទ្ធសាសនា ៩៥% ។

**ក. ប្រជាជន រចនាសម្ព័ន្ធ និងការវិវត្ត ការសង្កេត**

ក្រុងភ្នំពេញមានកំណើនប្រជាជនក្នុងកម្រិតសមល្មមរយៈពេល១០ឆ្នាំក្រោយនេះគឺ (១៦%) ដែលមធ្យមភាគនេះបានបិតបាំងនូវការថយចុះរបស់ចំនួនប្រជាជន ដែររស់នៅក្នុងខណ្ឌកណ្ដាលទីក្រុង និងឆៀកទៅមានកំណើនប្រជាជនយ៉ាងឆាប់រហ័សនៅតាមតំបន់ជុំវិញទីក្រុងវិញ ដែលជាលទ្ធផលបង្ហាញឲ្យឃើញនូវការរីកធំនៃទីក្រុងយ៉ាងឆាប់រហ័ស[10] ។ ដើម្បីឲ្យតំបន់ក្នុងក្រុងនិងជុំវិញក្រុងដំនើរការគឺគេត្រូវធ្វើការវិភាគការវិវត្តប្រជាជននៅក្នុងដែនដីមួយហើយ គឺជាអ្វីៗដែលត្រូវធ្វើមុន និងផ្ដើមធ្វើរាល់គម្រោងនគរូបនីយកម្ម ។

ការវិភាគនេះអាចជួយឲ្យដឹងពីតម្រូវការដូចជាផ្នែកៈហេដ្ឋារចនាសម្ព័ន្ធលំនៅស្ថានសេវាកម្មមូលដ្ឋានសំណង់ដែរការធ្វើបែបនេះគឺជាប្រយោជន៍សម្រាប់សាធារណៈទាំងអស់ដើម្បីឲ្យតំបន់ក្នុងក្រុងដែលត្រូវបង្កើតនោះមានដំណើរការល្អ។

**ខ. វិធីសាស្ត្រ**

**បង្កើតព្យាករណ៍ប្រជាសាស្ត្រ**

[10] ឧបសម្ព័ន្ធរូបភាព ទី៦

ដើម្បីវាស់សន្ទុះចំនួនប្រជាជននាពេលថ្មីៗ ត្រូវវាយតម្លៃទៅលើការវិវត្តប្រជាជននៅចន្លោះការធ្វើជំរឿនទាំងពីរលើកចុងក្រោយរបស់វិទ្យាស្ថានជាតិស្ថិតិ ។ នៅពេលស្គាល់ទិន្នន័យនៃការធ្វើជំរឿនឆ្នាំ ២០០៨ នោះកត្តាកំណើនប្រជាសាស្ត្រ និងអាចត្រូវបានបញ្ជាក់បានដូចជាអាត្រាកំណើតអាត្រាមរណភាព លំហូរអន្តោប្រវេសន៍ ឬនិរប្រវេសន៍ ។ ដើម្បីប៉ាន់ប្រមាណចំនួនប្រជាជនក្នុងរយៈពេលមធ្យម និងរយៈពេលវែងត្រូវគឺបង្កើតព្យាករណ៍ ប្រជាសាស្ត្រ ដោយផ្តល់ឲ្យប្រជាជនបច្ចុប្បន្ននូវអាត្រាវិវត្តន៍របស់ប្រជាជនដែលបានសង្កេត ។ ជាញឹកញយសេណារីយ៉ូជាច្រើនត្រូវបានគេស្មានទុកដើម្បីវាយតម្លៃកំណើតប្រជាជនទៅតាមសេចក្តីសន្និដ្ឋានអំពីកំណើនតាមកម្រិត ទាប មធ្យម ឬខ្ពស់ ។

**គណនាកំណើនប្រជាជនពាក់ព័ន្ធ នឹងកម្មវិធីលំនៅស្ថានថ្មី**

ដើម្បីប៉ាន់ប្រមាណចំនួនប្រជាជនជាមធ្យមក្នុងលំនៅស្ថាននីមួយៗ[11] និងទៅតាមប្រភេទនៃលំនៅស្ថាន (ផ្ទះឯកត្តជន ផ្ទះល្វែង លំនៅស្ថានកម្មករ )។ ការអង្កេតមួយអំពីលំនៅស្ថានត្រូវបានធ្វើឡើងនៅឆ្នាំ ២០០៨ ក្នុងចំនួន ៣០៣ គ្រួសារនៅខណ្ឌឬស្សីកែវ ។ ការអង្កេតបានឲ្យស្គាល់ទំហំមធ្យមនៃគ្រួសារនីមួយៗ និងការសិក្សានៅពេលអនាគតដោយផ្អែកទៅលើលទ្ធផលនៃការធ្វើជំរឿនប្រជាជនរបស់វិទ្យាស្ថានជាតិស្ថិតិ ។ ត្រូវរាប់ចំនួនលំនៅស្ថានដែលមានលិខិតអនុញ្ញាតិសាងសង់ទៅតាមប្រភេទនីមួយៗបន្ទាប់មកយកចំនួនលំនៅស្ថានដែលត្រូវសាងសង់ទៅគុណ នឹងអត្រាទំហំមធ្យមរបស់គ្រួសារទៅតាមប្រភេទនៃលំនៅស្ថាន។[12]

**លើកយកខណ្ឌឬស្សីកែវជាឧទាហរណ៍**

នៅខាងជើងខណ្ឌឬស្សីកែវមិនសូវលូតលាស់រហូតមកដល់ឆ្នាំ ១៩៩៨ ដែលមានប្រជាជនចំនួន ១៤០ ៦៦៨ នាក់ប៉ុន្តែប្រជាជនបានកើតឡើងដល់ ២៥១ ៥២២ នាក់នៅឆ្នាំ ២០០៨ ដូច្នេះអត្រាកំណើនគឺ ៧៨% ក្នុងរយៈពេល ១០ឆ្នាំ។ ប្រសិនបើកំណើតប្រជាជនតទៅមុខទៀតនៅតែរក្សាអាត្រានេះចំនួនប្រជាជនខណ្ឌឬស្សីកែវ និងកើនឡើងដល់៤៨៧៧០០នាក់នៅឆ្នាំ២០១៨ ។ កំណើនប្រជាជននេះទើបតែចាប់ផ្តើមនៅឡើយទេ ។ សំណើរសុំលិខិតអនុញ្ញាតសាងសង់សម្រាប់កម្មវិធីសាងសង់លំនៅស្ថានធំៗ ( កាំកូស៊ីធី ប្រ៉េក្អនស៊ីធីភ្នំពេញ តំបន់ចែកដីឡូសម្រាប់ផ្ទះល្វែង) មុខជាជម្រុញកំណើនប្រជាជនបន្ថែមទៀត។ គ្រាន់តែគម្រោងដែលកំពុងកសាងសព្វថ្ងៃនេះគេអាចប៉ាន់ប្រមាណថាពីឥឡូវដល់ ឆ្នាំ២០១០ នៅក្នុងខណ្ឌឬស្សីកែវ នឹងអាចមានប្រជាជនបន្ថែមចំនួន ១៨០០០០ នាក់ហើយចាប់ពីឥឡូវដល់ឆ្នាំ២០១៥ នឹងមានប្រជាជនចំនួន៦៥៨០០នាក់ថែមទៀត ។

---

[11] ឧបសម្ព័ន្ធរូបភាព ទី ៧

[12]សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរការធ្វើជំរឿនប្រជាជនទូទៅឆ្នាំ ១៩៩៨ - ២០០៨
លិខិតអនុញ្ញាតសាងសង់ក្នុងតំបន់សិក្សា ( មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់)

ដូចនេះខណ្ឌឬស្សីកែវទាំងមូលអាច និងមានប្រជាជនចំនួន ៣១៧៣០០ នាក់ ដែរក្នុងនោះគ្រាន់តែតំបន់ឬស្សីកែវដែលមានគម្រោងនានាដែលអាចនឹងកើតមាននៅលើដីសព្វថ្ងៃនៅទំនេរផង ។ ដូច្នេះ ការគ្រប់គ្រង និងធ្វើស្ថិតិលំនៅស្ថានជាកិច្ចសំខាន់ណាស់គឺធ្វើទៅតាមរយៈការត្រួតពិនិត្យចេញលិខិតអនុញ្ញាតសាងសង់ដល់គម្រោងលំនៅស្ថាន ។ បើពុំដូច្នេះទេតំបន់ប៉ែកខាងជើងនៃទីក្រុងនឹងមិនអាចមានដំណើរការធម្មតាបានទេនៅថ្ងៃខាងមុខ ។ តាំងពីពេលនេះគេសង្កេតឃើញមានការខ្វះខាតផ្នែកសំណង់ប្រយោជន៍សាធារណៈទៅហើយ គ្មានសេវាសុខភាពគ្រប់គ្រាន់ គ្មានតំបន់បៃតង ផ្លូវតូចៗ ហើយមានចំនួនតិចតួចនូវសេវាមូលដ្ឋាន និងគ្មានថាមពលគ្រប់គ្រាន់សម្រាប់ទទួលប្រជាជនថ្មីបន្ថែម ។

### ១.២.២ លំនៅស្ថាន

មានការប្រែប្រួលផ្នែកលំនៅស្ថានជាមួយ នឹងសន្ទុះនៃចំនួនគម្រោងសំណង់ដែលសម្រាប់លក់[13] ។ ការផ្តល់លំនៅស្ថានសព្វថ្ងៃ សំដៅទៅរកតែអ្នកមានលទ្ធភាពទិញមួយមុខគត់គឺ ផ្ទះវីឡា និងផ្ទះល្វែង សម្រាប់អ្នកធូរធារ មធ្យម និងអ្នកមាន ។ ចំពោះអ្នកក្រីក្រវិញគ្មានគម្រោងណាមួយដែលអាច មានលទ្ធភាពទិញលំនៅស្ថានបានឡើយ ។ ហេតុនេះទើបបណ្តាលឲ្យមាននូវកំណើនក្នុងតំបន់លំនៅស្ថានបណ្តោះអាសន្ន (លំនៅស្ថានអនាធិបតេយ្យ ។ល។) និងធ្វើឲ្យគ្រួសារក្រីក្រចាកចេញទៅនៅក្រៅទីក្រុង ។ បង្កើតលំនៅស្ថានចម្រុះគ្រប់ប្រភេទដើម្បីបង្កើតបាននូវលំនៅស្ថានសាមញ្ញមិនសូវថ្លៃនៅរាល់សង្កាត់ដែលជាការចាំបាច់ដើម្បីពុំទុកឱកាសឲ្យកើតទីក្រុងអ្នកមាននៅម្ខាង និង ទីក្រុងអ្នកក្រនៅម្ខាង ដែលជាមូលហេតុនាំឲ្យទីក្រុងភ្នំពេញអាចបញ្ចៀសស្ថានភាពនេះបានរហូតដល់សព្វថ្ងៃ ។

### ក.វិធីសាស្រ្ត

១.ចុះក្នុងបញ្ជីរាល់ប្រភេទលំនៅស្ថានមានសព្វថ្ងៃបង្កើតផែនទីដើម្បីវិភាគទីតាំង និងមុខងាររបស់វាហើយធ្វើផែនការវាយតម្លៃនៃការប្រមូលផ្តុំនិងសភាពទំនេរនៃដី។

២.ស្គាល់គម្រោងលំនៅស្ថានដែលគម្រោងទាំងនោះនៅជា គម្រោងនៅឡើយដោយវិភាគទៅលើលិខិតអនុញ្ញាតសាងសង់។[14]

---

[13] ឧបសម្ព័ន្ធរូបភាពទី ២៣

[14]សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរ (ប្រភព មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់)

៣.ប៉ាន់ស្មានតម្រូវការលំនៅស្ថាននឹង តម្រូវការជាបរិមាណទាក់ទងទៅនឹងការវិវត្តរបស់ប្រជាជននិងតម្រូវការជាគុណភាពដើម្បីវាយតម្លៃថា តើលំនៅស្ថានប្រភេទមួយណាដែលចាំបាច់ត្រូវសាងសង់។ ចំពោះរឿងនេះជាឧទាហរណ៍ ការអង្កេតមួយស្តីអំពីលំនៅស្ថានទើបតែត្រូវបានធ្វើឡើងនៅខណ្ឌឬស្សីកែវដើម្បីវាស់ស្ទង់នូវតម្រូវការលំនៅស្ថាន និងស្គាល់ប្រភេទប្រជាជនទៅតាមប្រភេទលំនៅស្ថានដំណើររស់នៅ និងគម្រោងរស់នៅរបស់គ្រួសារទាំងឡាយនៅទីក្រុងភ្នំពេញ ។ ជាលទ្ធផលនៃការធ្វើអង្កេតនេះបានផ្តល់ឲ្យយើងនូវការស្គាល់អំពីប្រជាជនដូចមានខាងក្រោម៖

- តំបន់លំនៅស្ថានចម្រុះដែលមានផ្ទះវីឡាបុរាណ វីឡាថ្មីៗ និងផ្ទះល្វែងតូចៗ
- តំបន់ដែលមានលំនៅស្ថានកម្មករច្រើនជាពិសេសនៅទូលសង្កែនៅក្បែររោងចក្រ។
- តំបន់បណ្តោះអាសន្នភាគច្រើនស្ថិតនៅទូលសង្កែជាពិសេសស្ថិតនៅលើដីសាធារណៈ។
- តំបន់ហាមសាងសង់និងនៅតាមបណ្តោយផ្លូវរថភ្លើងនិងនៅលើច្រាំងទន្លេ ។
- តំបន់ផ្ទះល្វែងទើបនឹងសង់ថ្មីៗ
- ក្រុងថ្មីៗ ៖ កាំកូស៊ីធី[15] ឬប្រែ្កនស៊ីធីភ្នំពេញដែលមានផ្ទះវីឡា ផ្ទះល្វែង និងអាគារលំនៅដ្ឋានខ្ពស់ហើយប្រណិត ។ ទីផ្សារលំនៅស្ថានសម្រាប់ជួលមិនទាន់សូវមានច្រើនទេលើកលែងតែលំនៅស្ថានសម្រាប់ជួលឲ្យកម្មករ។

## ខ. គោលនយោបាយលំនៅស្ថានដឹកនាំដោយសាលាក្រុង

នៅខណ្ឌឬស្សីកែវសំណង់ថ្មីៗបានកាត់បន្ថយ នូវចំនួនប្រភេទលំនៅស្ថានសម្រាប់លក់ជាពិសេសប្រភេទលំនៅស្ថានដែលគ្រួសារមិនសូវធូរធារអាចទិញបាន [16]។ ដូច្នេះសំខាន់ណាស់ត្រូវរក្សាឲ្យបាននូវគ្រប់ប្រភេទលំនៅស្ថានដែលមានទាំងអស់ដើម្បីឲ្យ គ្រួសារគ្រប់ជាន់ថ្នាក់ទាំងអ្នកមាន ទាំងអ្នកក្រអាចទិញ និងរស់នៅក្នុងសង្កាត់ជាមួយគ្នាបាន ៖

១.រក្សាតំបន់លំនៅស្ថានចម្រុះជាអាទិភាពក្នុងសង្កាត់ចាស់ៗមានលំនៅស្ថានបុរាណ

សិក្ខាសាលាស្តីពីផែនការសង្កាត់ដែលធ្វើនៅ ថ្នាក់ខណ្ឌអាចជាមធ្យោបាយដើម្បីគ្រប់គ្រងការលូតលាស់ក្រុងហើយ និងបញ្ចៀសការប្រមូលផ្តុំហួសហេតុនៃសំណង់នៅក្នុងសង្កាត់ទាំងនេះ ។

[15] ឧបសម្ព័ន្ធរូបភាព ទី ៨

[16] ឧបសម្ព័ន្ធរូបភាព ទី ៩

២. ជួយជ្រោមជ្រែងលំនៅស្ថានកម្មករឲ្យបាននៅក្បែររោងចក្រ និងជម្រុញឲ្យមានគុណភាព និងសុខភាពផង។

លំនៅស្ថានកម្មករបានកើតឡើងជាមួយ នឹងរោងចក្រតាមការផ្ដើមគំនិតគម្រោងរបស់អ្នកបណ្ដាក់ទុនឯកជន ។ ដង់ស៊ីតេនៃការរស់នៅក្នុងបន្ទប់សមូហភាព ( ៤នាក់ក្នុងមួយបន្ទប់) និងអវត្តមាននូវជាសុខភាព ដូចនេះតម្រូវឲ្យបង្កើតបទបញ្ញារសម្រាប់គ្រប់គ្រងសំណង់លំនៅស្ថានប្រភេទនេះដើម្បីជាប្រយោជនិអាចតទឹកស្អាតមកប្រើប្រាស់បានស្រួលហើយ និងមានស្ថានភាពអនាម័យល្អប្រសើរ ។ លំនៅស្ថានដែលមានលក្ខណៈស្របនឹងរបៀបរស់នៅនៃគ្រួសារត្រូវជំរុញការអភិវឌ្ឍន៍ផងដែរ។

៣.គ្រប់គ្រងកម្មវិធីចែកដីឡូសម្រាប់សាងសង់ផ្ទះល្វែង និងផ្ទះវីឡាដោយមានការបង្ខំឲ្យចូលរួមចំណែកក្នុងការបង្កើតសំណង់ដែលជាប្រយោជន៍សាធារណៈនៅតាមសង្កាត់នីមួយៗ។

៤.បង្កើតឲ្យមានការរីកចំរើននៅក្នុងវិស័យសំណង់ និងលំនៅស្ថានសម្រាប់គ្រួសារក្រីក្រនៅខណ្ឌឬស្សីកែវចំពោះលំនៅស្ថានរបស់គ្រួសារក្រីក្រជាងគេដែលមានខ្ទមស្លឹកផ្ទះតូចៗ សង់ផុតពីដីនៅតាមផ្លូវ ផ្លូវរថភ្លើង ឬនៅលើដីអាចលិចទឹកនៅតាមមាត់បឹងប្រលាយកំពុងតែឈានទៅរកការបាត់បង់អស់រលីងហើយដោយមិនត្រូវបានគេគិតគូរបញ្ចូលទៅក្នុង កម្មវិធីរបស់គម្រោងរៀបចំក្រុងថ្មីឡើយប្រសិនបើលំនៅស្ថានសម្រាប់ជនក្រីក្រ នៅតែមិនអាចបញ្ចូលទៅក្នុងកម្មវិធីរបស់គម្រោងនោះទេប្រភេទនៃលំនៅស្ថានបណ្ដោះអាសន្ន នឹងនៅតែមានកើតឡើងជាបន្តបន្ទាប់ដោយផ្លាស់ទៅនិងទីតាំងពីកន្លែងមួយទៅកន្លែងមួយទៀតដោយគ្មានសង្ឃឹមថានិង អាចនៅស្ថិតស្ថេរមួយកន្លែងបានឡើយ ។ ដូច្នេះគឺចាំបាច់ត្រូវតែគិតគូរបញ្ចូលពួកគេទៅក្នុងគម្រោងពង្រីកក្រុងថ្មីដែលកំពុងដំណើរដើម្បីបំបាត់ការរីកដុះដាលលំនៅស្ថានប្រភេទនេះនៅលើទីតាំង ដែលអាចមានគ្រោះថ្នាក់ និងលើទីធ្លាសាធារណៈ ។

**ដើម្បីដោះស្រាយបញ្ហានេះបានអាជ្ញាធរអាចអនុវត្តសកម្មភាពនានាដូចខាងក្រោម ៖**

១.រក្សាលំនៅស្ថានបណ្ដោះអាសន្នដែលមានស្រាប់ ប្រសិនបើលំនៅស្ថានមិនស្ថិតនៅក្នុងតំបន់គ្រោះថ្នាក់ ។ លំនៅស្ថានត្រូវតែកែលំអឲ្យបានប្រសើរនៅ នឹងកន្លែងបើលំនៅស្ថាននោះមិនស្ថិតនៅលើតំបន់គ្រោះថ្នាក់ឬលើចំណីផ្លូវសាធារណៈទេ ។ កាលណាចំបាច់ត្រូវតែប្ដូរទីតាំងទីតាំងថ្មីត្រូវស្ថិតនៅក្នុងតំបន់ដីឡូស្របច្បាប់នៅក្នុងសង្កាត់ថ្មីមិនមែននៅក្នុងតំបន់ឆ្ងាយក្រៅក្រុង និងលិចទឹកនោះទេ ។

២.ចរចារជាមួយ នឹងអ្នកដែលជាម្ចាស់នៃគម្រោងបណ្តាក់ទុនឯកជនឲ្យកែសម្រួលនូវកម្មវិធីគម្រោងរបស់គេ កម្មវិធីលំនៅស្ថានត្រូវមានបម្រុងទុកដីមួយភាគសម្រាប់គ្រួសារក្រីក្រ ហើយប្លង់ចែកដីឡូត្រូវមានគ្រោងបញ្ចូលឡូតូចៗក្នុងសមាមាត្រដែល នឹងត្រូវកំណត់ដើម្បីសង់ផ្ទះ ឬផ្ទះល្វែងតូចៗដោយប្រជាជនខ្លួនឯង ឬដោយម្ចាស់គម្រោងបណ្តាក់ទុនឯកជន ។ តម្លៃដីឡូតូចទាំងនេះត្រូវមានការត្រួតពិនិត្យ និងគ្រប់គ្រងឲ្យបានហ្មត់ចត់កុំឲ្យធ្លាក់ចូលក្នុងស្ថានភាពកេងប្រវញ្ចតម្លើងថ្លៃដីកើតឡើងឲ្យសោះ។

បច្ចុប្បន្ននេះក្នុងសេចក្តីប្រកាសច្បាប់ស្តី អំពីយុទ្ធសាស្រ្តជាតិសម្រាប់អភិវឌ្ឍរៀបចំដោយក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំនង់មានគ្រោងទុកដីបម្រុង ៣០% នៃផ្ទៃដីគម្រោងសម្រាប់លំនៅស្ថានអ្នកក្រីក្រ ឬនិងសំណង់ប្រយោជនសាធារណៈ ។ សេចក្តីព្រាងច្បាប់នេះគឺជាឱកាសមួយដើម្បីបង្កើតដីបម្រុងសម្រាប់លំនៅស្ថាន ដែលគ្រួសារមិនសូវមានធនធានអាចមានលទ្ធភាពក្លាយទៅជា ម្ចាស់កម្មសិទ្ធិបាន ។

### ១.២.៣ សេដ្ឋកិច្ច

ភ្នំពេញស្ថិតនៅចំណុចប្រសព្វគ្នានៃ ទន្លេមេគង្គ ទន្លេបាសាក់ និង ទន្លេសាប ។ សព្វថ្ងៃនេះប្រទេសកម្ពុជាមានការអភិវឌ្ឍសេដ្ឋកិច្ចមានល្បឿនយឺតក្នុងការប្រកួតប្រជែងទីផ្សារក្នុងស្រុក និងប្រទេសនៅលើសកលលោកដែលមានសេដ្ឋកិច្ចខ្ពស់ គឺអាស្រ័យទៅលើរដ្ឋាភិបាលការបើកទ្វារឲ្យប្រទេសផ្សេងៗមកធ្វើវិនិយោគទុនពង្រឹង និងពង្រីកផលិតផលក្នុងស្រុកកាត់បន្ថយការនាំចូលនិងបង្កើនការនាំចេញច្រើន ។ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក៏ដូចជារកការងារអោយប្រជាពល ដូនេះតម្រូវឲ្យរដ្ឋរដ្ឋាភិបាលបានកែច្នៃកន្លែងផ្សេងៗអោយក្លាយទៅជាតំបន់ទេសចរណ៍ និងរកចំណូលបាន តាមរយៈភ្ញៀវបរទេសដែលចូលមកទស្សនាប្រទេសកម្ពុជា ។ ប៉ុន្តែភ្នំពេញគឺជាមជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាដូចគ្នាដែរ ហើយវាក៏ត្រូវបានចាត់ទុកថាជាផ្នែកដ៏ធំនៃសេដ្ឋកិច្ចរបស់កម្ពុជា ។ អត្រាកំណើនសេដ្ឋកិច្ចតួលេខបានកើនឡើងទ្វេដងក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងផុតមកនេះ ដែលធ្វើឱ្យមានសន្ទុះឡើងខ្លាំងនូវការលូតលាស់សេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅភ្នំពេញជាមួយ និងសណ្ឋាគារភោជនីយដ្ឋានរង្គសាលថ្មីៗមានការផុសផុល និងការសាងសង់លំនៅឯកជនមានការរីកដុះដាលជាច្រើនឡើងជុំវិញទីក្រុង ។ សេដ្ឋកិច្ចចំបងពឹងផ្អែកលើវិស័យពាណិជ្ជកម្មដូចជាកាត់ដេរពាណិជ្ជកម្ម និងបណ្តាសហគ្រាសធុនតូចនិងមធ្យម ។ ក្នុងរយៈពេលពីរបីឆ្នាំមុននេះធុរកិច្ចខាងអចលនទ្រព្យកំពុងបានរីកលូតលាស់យ៉ាងរហ័សរួមនិងការកើនឡើងយ៉ាងរហ័សនូវតំលៃអចលនទ្រព្យ។

ទេសចរណ៍ ក៏ជាវិស័យរួមចំណែកមួយដ៏សំខាន់ក្នុងទីក្រុងភ្នំពេញក៏ដូចជាការបើកមជ្ឈមណ្ឌលទិញឥវ៉ាន់ និងពាណិជ្ជកម្មកាន់តែច្រើនដែលធ្វើឱ្យភ្នំពេញក្លាយជាកន្លែងមួយក្នុងចំណោមគោលដៅទេសចរណ៍សំខាន់ក្នុងប្រទេស ។ បន្ថែមទៀតនោះផ្លូវថ្មីៗប្រឡាយ និងប្រព័ន្ធផ្លូវដែក នឹងត្រូវបានប្រើដើម្បីភ្ជាប់កាំកូស៊ីធីទៅនឹងរាជធានីភ្នំពេញ ។ គំរោងដទៃទៀតរួមមាន៖

- បុរីប្រៃ្គនដ៍ភ្នំពេញអន្តរជាតិ[17] (ស្ថិតក្រោមការសាងសង់)
- សហបាលាគារដីខាសសលរ៉ូយ៉ាល់[18] (ស្ថិតក្រោមការសាងសង់)
- សំណង់អគារហិរញ្ញវត្ថុអន្តរជាតិ[19] (ស្ថិតក្រោមការសាងសង)
- ហ្គោលដ៍ថវើ៤២[20] (ជាន់៣២ឈប់ត្រឹង)
- ថវ៉ឺអូស៊ីអាយស៊ីOCIC[21] (បានរួចរាល់ហើយ)
- វីុជាឡេស [22](ស្ថិតក្រោមការសាងសង់)
- វឌ្ឍនៈកាប់ពីថលថវ៉ឺ[23](សាងសង់រួច)

## ក. គោលនយោបាយសេដ្ឋកិច្ច

ភ្នំពេញមានការប្រែប្រួលទ្រង់ទ្រាយសេដ្ឋកិច្ចរបស់ខ្លួន ដូចជាមានការអភិវឌ្ឍយ៉ាងខ្លាំងក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មជាដើម[24] ។ ការបង្កើតតំបន់ការងារថ្មីដែលនៅទីនោះមានប្រមូលផ្តុំឧស្សាហកម្ម និងការិយាល័យបានបន្ថែមចំនួន និងចម្ងាយការធ្វើដំណើរពីផ្ទះទៅកន្លែងធ្វើការ ។ ប្រសិននៅពេលអនាគត មានការប្រមូលផ្តុំការងារកាន់តែខ្លាំងនោះការធ្វើចរាចរណ៍ឆ្លងកាត់ទីក្រុងនឹងលែងអាចធ្វើទៅកើតហើយ ។ នៅក្នុងសង្កាត់ទាំងអស់ដែលកំពុងរីកដុះដាលយ៉ាងពេញទំហឹងដែលការរលាយចូលគ្នារវាងលំនៅស្ថាន និងការងារត្រូវរក្សាទុកឲ្យបានដើម្បីឲ្យមានការអភិវឌ្ឍន៍ក្រុងប្រកបដោយតុល្យភាព ។

[17] ឧបសម្ព័ន្ធរូបភាព ទី ១០
[18] ឧបសម្ព័ន្ធរូបភាព ទី ១១
[19] ឧបសម្ព័ន្ធរូបភាព ទី ១២
[20] ឧបសម្ព័ន្ធរូបភាព ទី ១៣
[21] ឧបសម្ព័ន្ធរូបភាព ទី ១៤
[22] ឧបសម្ព័ន្ធរូបភាព ទី ១៥
[23] ឧបសម្ព័ន្ធរូបភាព ទី ១៦
[24] ឧបសម្ព័ន្ធរូបភាព ទី ១៧

## ខ. វិធីសាស្ត្រ

- វិភាគក្រឡាសេដ្ឋកិច្ចនៃតំបន់ដែលត្រូវសិក្សា (ការអង្កេតនៅលើតំបន់ផ្ទាល់និងការប្រើប្រាស់ស្ថិតិរបស់ក្រសួងឧស្សាហកម្ម ) ដើម្បីកំណត់ប្រភេទមុខរបរនានាដែលមាន ។
- រកបណ្តុំទីតាំងផ្សារ និងទីប្រជុំទាក់ទាញសកម្មភាពអាជីវកម្ម។
- ប៉ាន់ស្មានតម្រូវការផ្នែកសកម្មភាពសេដ្ឋកិច្ចអាស្រ័យទៅតាមការវិវត្តប្រជាជន និងលទ្ធភាពចូលទៅក្នុងសង្កាត់ ។

**លើកយកខណ្ឌឬស្សីកែវជាឧទាហរណ៍**

ខណ្ឌឬស្សីកែវមានលក្ខណៈសំខាន់របស់ខ្លួនតាមរយៈវត្តមាន សកម្មភាពសេដ្ឋកិច្ចផ្សេងៗដែលនាំមកនូវការបង្កើតការងារសម្រាប់ប្រជាជនដូចជា៖

- សកម្មភាពកំពុងផែ និងឃ្លាំងផ្ទុកទំនិញតាមដងទន្លេ និងផ្លូវជាតិលេខ ៥ ៖ ការដឹកជញ្ជូនការជួសជុលកប៉ាល់អាងស្តុងប្រេងស្ទូគីមិច ។
- ជាប៉ូលឧស្សាហកម្មនៅផ្នែកខាងលិចនៃសង្កាត់ទួលសង្កែ ដែលមាននិយោជិកចំនួន ៣៧០០០ នាក់ធ្វើការក្នុង ៤៤រោងចក្រ ក្នុងនោះសកម្មភាពកាត់ដេរជាសកម្មភាពចម្បង ព្រមទាំងសកម្មភាពជាច្រើនពាក់ព័ន្ធនិងរោងចក្រទាំងនោះបានកើតឡើងជាមូលហេតុនាំឲ្យកើនចំនួនគ្រួសាររស់នៅដោយសារសកម្មភាពឧស្សាហកម្ម។
- ត្រូវកត់សម្គាល់ផងដែរពីវត្តមានរោងចក្រអគ្គីសនីនៅកម្ពុជាហៅកាត់ថា EDC ដែលជាមានប្រភពបណ្តាញតង់ស្យុងខ្ពស់មួយចំនួនចេញពីទីរោងចក្រនោះ ។
- អាគាររដ្ឋបាលមានតិចតួចដូចជាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការជាតិអូឡាំពិក ។ ល។
- ប៉ូលពាណិជ្ជកម្ម ផ្សារ និងជំនួញតូចៗនៅតាមដងផ្លូវធំនានា ។ នៅឬស្សីកែវគេឃើញមានផ្សារសាធារណៈចំនួន ៥ ផ្សារឯកជនចំនួន ២ និងផ្សារមិនមានរបៀបរៀបរយចំនួន ៤ កន្លែង ។ ផ្សារនីមួយៗមានតូបពី ២០០ទៅ៥០០ តូបដោយមិនគិតរាប់បញ្ចូលអាជីវករចល័តទេ ។ ផ្សារថ្មីចំនួនពីរត្រូវបានគ្រោងទុកដោយសាលាក្រុងសម្រាប់រយៈពេលមធ្យម ។ ទីតាំងសម្រាប់ផ្សារទាំងពីរនេះមិនទាន់រកបានឡើយមូលហេតុមកពីដីនៅឬស្សីកែវថ្លៃពេក។

**សំណើរសម្រាប់គោលនយោបាយសេដ្ឋកិច្ច**

នៅតំបន់ភាគខាងជើងនៃទីក្រុងភ្នំពេញ ប៉ូលអភិវឌ្ឍន៍មួយចំនួនត្រូវបានបង្កើតឡើងនៅក្នុងគម្រោងនៃប្លង់មេ ។ បច្ចុប្បន្ននេះភាគខាងលិចនៃសង្កាត់ទួលសង្កែបានប្រែក្លាយឲ្យទៅជាប៉ូលឧស្សាហកម្មមួយរួចទៅហើយៗប៉ូលរដ្ឋបាលមួយកំពុងត្រូវបានសិក្សា ក្នុងតំបន់គម្រោងកាំកូស៊ីធី ។ ដែលនៅខាងជើងក្រុងថ្មី ដូចជាអន្លង់ក្ងានសព្វថ្ងៃមានប្រជាប្រិយខ្លាំងដែរបានរីកដុះដាលនៅជុំវិញស្នូលទីមួយដែលជាតំបន់ដ៏ធំមួយបង្កើតនៅឆ្នាំ២០០១ សម្រាប់ផ្តល់ទីជម្រកដល់គ្រួសារចល័តចេញពីកណ្តាលក្រុង ។ ទីក្រុងថ្មីនេះរីកកាន់តែខ្លាំងឡើងដោយសារនៅជិតទីនោះមានបង្កើតគម្រោងសាងសង់មួយហៅថា ប្រែ្តនភ្នំពេញ ដែលមានសំណង់លំនៅស្ថានយ៉ាងប្រណិតដែលកំពុងតែសាងសង់ ។ នៅក្នុងបរិយាកាសនេះសូមស្នើឲ្យរក្សាបណ្តាញក្រឡាសេដ្ឋកិច្ចដែលមានសព្វថ្ងៃ និងអភិវឌ្ឍសកម្មភាពសេដ្ឋកិច្ចដែលចាំបាច់បំផុតសម្រាប់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន៖

<u>១. រក្សាឲ្យបាននូវភាពចម្រុះនៃសកម្មភាពតូចៗសិប្បកម្ម ឧស្សាហកម្ម និងសេវាកម្មតូច ៗ</u>

ត្រូវជួយជ្រោមជ្រែងដល់រាល់គម្រោងទាំងឡាយណា ដែលមានបង្កើតសកម្មភាពសេដ្ឋកិច្ច និង សេវាកម្មសម្រាប់ប្រជាជនជាងគម្រោងដែលមានលំនៅស្ថានប៉ុណ្ណោះ ។

<u>២.ពង្រឹងក្រឡាពង្រាយទីតាំងផ្សារ</u>

នៅឬស្សីកែវសព្វថ្ងៃមានផ្សារទីប្រជុំជនមួយសម្រាប់ប្រជាជនប្រហែល ២៣ ០០០នាក់នេះបង្ហាញឲ្យឃើញថាមិនគ្រប់គ្រាន់ឡើយ ។ នៅកណ្តាលក្រុងភ្នំពេញមានផ្សារទីប្រជុំជន សម្រាប់ប្រជាជន១៥០០០នាក់រួចមានផ្សារធំៗបន្ថែម ។ ក្នុងផ្សារធំនីមួយៗមានតូបជាង១០០០តូបដូចជាផ្សារថ្មី ផ្សារអូឡាំពិក ។ សរុបទៅនៅក្នុងខណ្ឌកណ្តាលក្រុងផ្សារធំមួយសម្រាប់ប្រជាជនប្រមាណ ៨០០០០នាក់ ។ ចំពោះផ្សារដែលមានគ្រោងនៅក្នុងកម្មវិធីចែកដីឡូត៍សម្រាប់សង់ផ្ទះល្វែង ឬក្នុងកម្មវិធីគម្រោងសាងសង់ក្រុងថ្មីជាក់ស្តែងមិនត្រូវបានសាងសង់ឡើយ ។ ដូច្នេះសម្រាប់ប្រជាជនបច្ចុប្បន្ន និងប្រជាជននៃគម្រោងដែលកំពុងសាងសង់ត្រូវតែបង្កើត៖

- ផ្សារកណ្តាលក្រុងចំនួនពីរកន្លែងដែលមានតូបលក់លើសពី១០០០តូប។
- ផ្សារទីប្រជុំជន ( ប្រហែល៣០០តូប ) ដែលគេអាចដើរទៅដល់ ( ចម្ងាយតិចជាង ៥០០ម ) ទីតាំងផ្សារនេះជាអាទិភាពត្រូវនៅក្នុងតំបន់ដែលកំពុងពង្រីកសាងសង់យ៉ាងសកម្មដូចជាទួលសង្កែ ទឹកថ្លា និងឬស្សីកែវ ។

អ្នកម្ចាស់គម្រោងបណ្តាក់ទុនឯកជនអាចនឹងត្រូវបានជម្រុញឲ្យបង្កើតផ្សារទីប្រជុំជន ដោយដាក់ផ្សារប្រភេទនេះចូលទៅក្នុងកម្មវិធីសាងសង់ ។ សេចក្តីព្រាងច្បាប់របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដែលគ្រោងបម្រុង ៣០% នៃផ្ទៃដីឡូត៍ទាំងមូលទុកដើម្បីបង្កើតសំណង់ដើម្បីប្រយោជន៍សាធារណៈនានានោះអាចជាជំនួយដល់ការពិភាក្សាដាក់បញ្ចូលផ្សារទៅក្នុងកម្មវិធីគេបាន ។

- សម្រាប់ផ្សារធំៗចាំបាច់ត្រូវមានបម្រុងដីធំៗទុក ។ ដីទាំងនោះត្រូវសាលាក្រុងទិញ ឬអ្នកបណ្តាក់ទុនឯកជនណាម្នាក់ទិញ ។ សម្រាប់សាងសង់ផ្សារធំមួយមានជំបូលចាំបាច់ត្រូវមានដី ៩០០០ម² មានផ្លូវបំរើព័ទ្ធជុំវិញអមដោយផ្ទះល្វែង ។ ទីបំផុតតំបន់នេះបម្រើដោយផ្លូវពីរសំខាន់គឺផ្លូវជាតិលេខ ៥ និងទំនប់កប់ស្រូវត្រូវទទួលទីតាំងលក់ដុំមួយដើម្បីសម្រាលបន្ទុកផ្សារនានានៅក្នុងក្រុង ។ ដីដែលត្រូវបងម្រុងទុកមានទំហំប្រមាណ១៥០០០ម²។ផ្សារនេះ នឹងត្រូវនៅក្រៅតំបន់ក្រុងដែលបានរៀបចំរួចពីព្រោះវានឹងបង្កើតឲ្យមានសេវាកម្មនិងផ្សារចែកចាយនៅជុំវិញវា។

## ១.៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍរាជធានីភ្នំពេញ

ភ្នំពេញបានចំណាយអស់ពេលយ៉ាងច្រើនដើម្បីងើបចេញផុតពីសង្គ្រាម ។ ចាប់ពីក្រោយពីសន្ធិសញ្ញាក្រុងប៉ារីសឆ្នាំ ១៩៩១ ហើយស្របជាមួយ នឹង ការចប់ការហាមឃាត់លើវិស័យសេដ្ឋកិច្ចអស់រយៈពេល ១០ ឆ្នាំមកការកែទម្រង់ក្រុងចាស់ក៏ត្រូវបានចាប់ផ្តើមឡើង ។ ជាដំបូងរហូតមកដល់មានការបោះឆ្នោតឆ្នាំ ១៩៩៣ ដោយសារការមកដល់នៃអង្គការសហប្រជាជាតិការកកើតផ្ទះវីឡា និង អាគាររដ្ឋមួយចំនួនធំត្រូវបានជួសជុលឡើងវិញសណ្ឋាគារជាច្រើនត្រូវបានបើកទ្វារហើយឆ្នេរទន្លេមេគង្គដែលនៅពេលនោះសុទ្ធសឹងជាឃ្លាំងផ្ទុកទំនិញនានា ក៏ត្រូវបានប្រែក្លាយទៅជាសួនច្បារនេះជាសញ្ញាជាក់ស្តែងលើកដំបូងនៅក្នុងក្រុងបង្ហាញពីការមានសន្តិភាពឡើងវិញ។ចាប់ពីកណ្តាលទសវត្សរ៍ ៩០ មកដោយមានជំនួយអន្តរជាតិ និងមានការប្រមូលលើកដំបូងនៃមូលនិធិនៅកម្ពុជាគម្រោងជាច្រើនត្រូវបានអភិវឌ្ឍន៍ឡើងគម្រោងដំបូង គឺការចាក់ដីបំពេញក្នុងតំបន់ទំនាបនៅខាងមុខទន្លេបាសាក់ដើម្បីធ្វើឲ្យមានលទ្ធភាពបន្តមហាវិថីព្រះសីហនុរហូតដល់ទន្លេ និងបង្កើតសួនច្បារសម្តេច ហ៊ុន សែន ព្រមទាំងសំណង់ថ្មីៗមួយចំនួននៅខាងត្បូងសណ្ឋាគារកាំបូឌីយ៉ាណាបន្ទាប់មកគឺការជួសជុលស្តារសួនច្បារនៅវត្តភ្នំពង្រីងឆ្នេរទន្លេនៅតំបន់ជ្រោយចង្វារ និងកម្មវិធីដ៏ធំមួយគឺការជួសជុលបណ្តាញផ្លូវនានានៃសង្កាត់កណ្តាលក្រុង ។ នៅពេលជាមួយគ្នានោះមានការងារដ៏សំខាន់

សម្រាប់ជួសជុលហេដ្ឋារចនាសម្ព័ន្ធ ក៏បានចាប់ផ្តើមឡើងមានដូចជាការស្តាបនាបណ្តាញទឹកស្អាតទាំងស្រុង និងជួសជុលបណ្តាញអគ្គិសនីឡើងវិញ រួមជាមួយការជួសជុលទំនប់នៅក្រៅក្រុង និងការជួសជុលរាល់ស្ថានីយ៍បូមទឹក ។ នៅក្នុងអំឡុងចុងទសវត្សរ៍៩០ ទីក្រុងលែងមានការយឺតយ៉ាវហើយៗការអភិវឌ្ឍសេដ្ឋកិច្ចក៏បានចាប់ផ្តើមដែរដូចជា ៖ រោងចក្រកាត់ដេរបានចាប់ផ្តើមបើកដំណើរការនៅតាមសង្កាត់ជាយទីក្រុងភ្នំពេញ ។ ការបែងចែកដីឡូសម្រាប់ផ្ទះល្វែងក៏បានចាប់មានច្រើនឡើងៗនៅតាមដងមហាវិថីធំៗនិងនៅលើដីសាធារណៈដូចជាដីទីលានពហុកីឡាដ្ឋានអូឡាំពិក[25] ។ ដើម្បីឲ្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍរាជធានីភ្នំពេញមានដំណើរការកាន់តែរលូនគេតម្រូវឲ្យមាននូវប្លង់គោលសម្រាប់រាជធានី ( ១.៣.១ ប្លង់គោលរាជធានីភ្នំពេញ) និង (១.៣.២ បណ្តាញដឹកជញ្ជូនសាធារណៈ) ។

### ១.៣.១ ប្លង់គោលរាជធានីភ្នំពេញ

តាំងពីក្លាយជារាជធានីនៃប្រទេសកម្ពុជាក្នុងទស្សវត្សឆ្នាំ ១៨៦០ មកភ្នំពេញត្រូវបានពង្រីកតាមរយៈការបង្កើតតំបន់ធំៗបែងចែកជាដីឡូបន្តបន្ទាប់គ្នា[26] ។ នៅក្នុងសម័យដែលព្រះរាជាណាចក្រកម្ពុជា ស្ថិតក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះបាទសម្តេចនរោត្តមសីហានុគឺក្រុងភ្នំពេញបានប្រែខ្លួនទៅ ជាទីក្រុងមួយ ដែលមានការរីកចម្រើនពោរពេញទៅដោយការអភិវឌ្ឍដូចជា[27] ៖

ឆ្នាំ ១៩៥៨ បានកសាងមហាវិថីម៉ៅសេងទុង

ឆ្នាំ ១៩៦១ បានធ្វើការពង្រីកតំបន់ទួលគោក

ឆ្នាំ ១៩៦៣ ធ្វើការស្តាបនាពហុកីឡាដ្ឋានជាតិអូឡាំពិច[28]

ឆ្នាំ ១៩៦៤ ធ្វើការស្ថាបនាមហោស្រពទន្លេបាសាក់ កាស៊ីណូ ផ្លូវរថភ្លើង អាកាសយានដ្ឋានពោចិនតុង ។

ឆ្នាំ ១៩៦៦ ធ្វើការស្ថាបនាស្ពានសង្គមរាស្ត្រនិយមសព្វថ្ងៃ ជាស្ពានកម្ពុជា-ជប៉ុន សាលារៀនមន្ទីរពេទ្យ រោងចក្រ សហគ្រាស ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ។

---

[25]សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរ សាលារាជធានីភ្នំពេញ ឆ្នាំ ២០០៩។

[26]សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរ សាលារាជធានីភ្នំពេញ ឆ្នាំ ២០០៩។

[27]សៀវភៅ នីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា

[28] ឧបសម្ព័ន្ធរូបភាព ទី ១៨

ប៉ុន្តែនៅឆ្នាំ ១៩៧៥-១៩៧៩ ប្រទេសយើងបានជួបវិបត្តិដោយទទួលនូវការខូចខ្ទីខូចខាតយ៉ាងធំណាំដោយសារពួកខ្មែរក្រហមដោយវាបានសម្លាប់ប្រជាជនយ៉ាងច្រើន ដែលធ្វើបាត់បង់នូវធនធានមនុស្សដ៏សំខាន់សំរាប់អភិវឌ្ឍប្រទេស ទីក្រុងទាំងមូលក្លាយជាទីក្រុងខ្មោច ទីកន្លែងដែលធ្លាប់មានមនុស្សរស់នៅបែរជាស្ងាត់ជ្រងំ ប៉ុន្តែរហូតមកដល់សម័យកាលសាកលភាវូបនីយកម្មនេះ ភ្នំពេញបានឈានចូលយ៉ាងច្បាស់ទៅក្នុងដំណាក់កាលអភិវឌ្ឍស្រដៀង នឹងដំណាក់កាលអភិវឌ្ឍន៍ក្រុងធំៗនៅអាស៊ីកាលពីប៉ុន្មានឆ្នាំមុន ។ ដែលធ្វើឲ្យរាជធានីភ្នំពេញមានការរីកចំរើនខ្លាំងដូចជា៖ មានមជ្ឈមណ្ឌលពាណិជ្ជកម្ម សំណង់អាគារ ការិយាល័យខ្ពស់ៗនិងអាគារលំនៅស្ថានធំៗ[29]។ ការរីកចំរើន និងអភិវឌ្ឍបែបនេះគឺតម្រូវឲ្យមានប្លង់ដើម្បីជាគម្រោងក្នុងការអភិវឌ្ឍន៍ដែលគេហៅថាជា "ប្លង់គោល"។

**តើអ្វីទៅជាប្លង់គោល?**

ប្លង់គោលជាឯកសារ ឬគំរោងដែលមានលក្ខណៈជាយុត្តិសាស្ត្រនៃការអភិវឌ្ឍរាជធានីដល់ឆ្នាំ ២០២០ [30]។ ប្លង់គោលត្រូវបានគេចាត់ទុកថាជាប្លង់គ្រឹះសម្រាប់រៀបចំដែនដីនៃរាជធានីក៏ដូចជាខេត្ត ក្រុង នីមួយៗពីព្រោះថាប្លង់គោលនេះជាអ្នកតម្រង់ទិសក្នុងការបែងចែកឬកំណត់ផ្ទៃដីសម្រាប់តំបន់សំណង់ តំបន់ទេសចរណ៍ តំបន់ឧស្សាហកម្ម តំបន់សណ្ឋាគារ កន្លែងសួនសាធារណៈ តំបន់ដែលត្រូវការពារតំបន់ដែលត្រូវអភិវឌ្ឍ ។ល។ ប្លង់គោលជាទូទៅគឺគេថែងទស្សនវិស័យនៃការអភិវឌ្ឍដីធ្លីនៅក្នុងតំបន់រាជធានី ខេត្តតែប៉ុណ្ណោះ ហើយប្លង់នេះត្រូវបានកំណត់ដោយច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ។

ប្លង់គោលនេះមានទិសដៅកំណត់ពីរសំខាន់ៗ ទី ១ កំណត់តំបន់ដែលជាដីសាធារណៈរបស់ រដ្ឋ និងតំបន់ហាមសាងសង់ ព្រមទាំងតំបន់ប្រើប្រាស់ជារួម ឬបម្រុងទុកជាសម្បត្តិរដ្ឋ និងលំហានានា ដូចជាលំហាកម្ពស់សម្រាប់បរិក្ខាសាធារណៈធំៗផ្សេងទៀត ។ ទី២ បង្កើតអនុសាសន៍ដែលជាយុទ្ធ សាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ទីក្រុងបំណងនេះគឺសំដៅរៀបចំតម្រង់ទិសសម្រាប់ថ្ងៃ អនាគតនូវការវិនិយោគរបស់រដ្ឋ និងឯកជន[31] ។

[29]សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរ សាលារាជធានីភ្នំពេញ ឆ្នាំ ២០០៩។

[30]សៀវភៅ នីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា

[31]គម្រោងប្លង់គោលរាជធានី ភ្នំពេញ

**តើប្លង់គោលនេះមានអត្ថប្រយោជន៍អ្វីខ្លះ?**

ការរៀបចំបង្កើតជាប្លង់គោលបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ការអភិវឌ្ឍក្រុងដែលមាន ដូចជា ៖

១.ធ្វើឲ្យការសាងសង់មានបទដ្ឋានតាមការកំនត់របស់ប្លង់គោល

២.រាល់ឧទ្យានសួនច្បារ រមនីយដ្ឋាន មហោស្រព ទីធ្លាកំសាន្ត ត្រូវបានសាងសង់ដោយមាន សណ្តាប់ធ្នាប់។

៣.ទីក្រុងមានសោភ័ណភាពស្រស់បំព្រង គ្មានសំណង់អនាធិបតេយ្យមានអនាម័យ គ្មាន ភក់ជ្រាំចម្លងមេរោគ។

៤.គ្មានភាពច្របូកច្របល់សួនច្បារក្លាយជាស្តានីយបូមប្រេង ឆ្នេរទន្លេដែលជាទីលាន យក ខ្យល់អាកាសសំរាប់បំរើឲ្យអ្នកទេសចរណ៍ ប្រែក្លាយទៅជាផ្ទះស្លឹកផ្ទះឈើភូមិជរាអនាធិបតេយ្យ នៅក្នុងទីក្រុង ។

៥.ប្លង់គោលជា ប្លង់បង្ហាញពីសោភ័ណភាពតំបន់សណ្តាប់ធ្នាប់ មានបណ្តាញផ្គត់ផ្គង់ទឹក បណ្តាញលូបង្ហូរទឹកភ្លៀង និងទឹកស្អុយមានបណ្តាញអគ្គីសនីមានទីកំសាន្តមានសាលារៀនដីសំរាប់ កីឡាដ្ឋានដីសំរាប់រដ្ឋបាលទីធ្លាសំរាប់ផ្សារគ្រឹះស្ថានពាណិជ្ជកម្មនិងវប្បធម៌។

ប្លង់គោលគឺពិតជាសំខាន់ដូចនេះហើយគឺត្រូវតែមានបទបញ្ជារ និងក្រឹត្យក្រមដើម្បីបន្ថែម ល្បឿន និងកំណត់ទិសដៅដើម្បីអភិវឌ្ឍន៍ព្រោះពេលដែលគ្មានផែនការច្បាស់លាស់ការអភិវឌ្ឍន៍ ក្រុង និងប្រព្រឹត្តទៅដោយមិនចំចំនុច និងមិនចំទិសដៅនៃការអភិវឌ្ឍន៍ក្រុងដែលជាបញ្ហាប្រសិនបើ ក្រុងមិនមាននូវការអភិវឌ្ឍន៍ចំចំនុចគោលដៅ និងធ្វើឲ្យមានការរាំងស្ទះ និងខាត់បង់ពេលវេលា ។ ដូច្នេះដើម្បីកុំឲ្យមានការរាំងស្ទះការអភិវឌ្ឍន៍ទីក្រុងគឺត្រូវធ្វើតាមគម្រោង និងផែនការយុទ្ធសាស្ត្រ រៀបចំរាជធានីដើម្បីជាប្រយោជន៍សេដ្ឋកិច្ច និងសង្គមកិច្ច ដែលឆ្លុះបញ្ចាំងឲ្យឃើញថាភ្នំពេញជា បេតិកភណ្ឌក្រុងរមណីយដ្ឋាន និងទេសភាព (ក) នឹងភ្នំពេញជាគឺរាជធានីអេកូឡូស៊ីដែលគោរព បរិស្ថាន (ខ) ។

### ក.ភ្នំពេញ ជាបេតិកភណ្ឌក្រុង រមណីយដ្ឋាន និងទេសភាព

អត្តសញ្ញាណក្រុងបញ្ជាក់ដោយគម្រោងថ្មីៗ នឹងដោយការអភិរក្សការជួសជុលលើកតម្លៃ ទៅលើអាគារបេតិកភណ្ឌព្រមទាំងរមណីយដ្ឋាន ដែលមានតម្លៃសេដ្ឋកិច្ច និងសង្គមដើម្បីអភិវឌ្ឍ ទេសចរណ៍ និង រូបភាពអន្តរជាតិនៃរាជធានី ។ ដើម្បីចៀសវាងការវាយបេតិកភណ្ឌស្ថាបត្យកម្ម

ចោលគឺត្រូវបន្ថយ ពន្ធផ្ទះ ពន្ធដី នៅតំបន់សង្កាត់ចាស់ៗហើយតម្រង់ទិសគម្រោងធំៗឲ្យទៅសង់នៅតំបន់ថ្មីៗដែល នឹងក្លាយទៅជាទីក្រុងនៅពេលអនាគត ។ គម្រោងធំៗទាំងនោះមានដូចជាអគារខ្ពស់ៗជាឱកាសតែមួយគត់ សម្រាប់រាជធានីដើម្បីអភិវឌ្ឍតំបន់នានាដូចជា បឹងកក់ ចតុមុខ បឹងពោងពាយ ឬបឹងជើងឯក ដែលនឹង ពង្រឹងរូបភាពទំនើបនៃរាជធានី និងរៀបចំការអភិវឌ្ឍដោយបង្កើតបណ្តាញ តំបន់ក្រុងថ្មីប្រកបដោយពហុមុខងារ ដោយធ្វើការកសាងទំនប់កប់ស្រូវ ដែលផ្តល់ទំហំថ្មីមយយដល់ទីក្រុង និងអភិវឌ្ឍប៉ូលពហុមុខងារដែលមានប្រយោជន៍សាធារណៈធំៗ រួចដាក់បញ្ចូលការអភិវឌ្ឍមានដូចជាអន្លង់ក្ងាន តាខ្មៅ សំរោង ច្បារអំពៅ បឹងជើងឯក ទៅក្នុងគម្រោងធំៗនាពេលអនាគត់ ។

### ខ.ភ្នំពេញជារាជធានីអេកូឡូស៊ីដែលគោរពបរិស្ថាន

ភ្នំពេញជាទីក្រុងដូច្នេះត្រូវតែពង្រីកទំនាក់ទំនងឲ្យបានកាន់តែជិតស្និទ្ធ ជាមួយនឹងធម្មជាតិបង្កើនចំនួនសួនច្បារ និងដាំដើមឈើ ដើម្បីកាត់បន្ថយឥទ្ធិពលកំដៅបង្ករដោយសំណង់នានាក្នុងទីក្រុង ។ ដូចនេះចាំបាច់ត្រូវបង្កើតសួនដាំដើមឈើ និងលំហបៃតងដែលចូលរួមចំណែកយ៉ាងសកម្មនៅក្នុងជីវិតទីក្រុង ។ ការបង្កើត និងការថែទាំរុក្ខជាតិជាកម្មវត្ថុមួយដ៏សំខាន់នៃសកម្មភាពរបស់សាលក្រុងព្រោះការបង្កើតជាសួន និងលំហបៃតងនេះឡើងវាបានផ្តល់នូវឥទ្ធិពលមួយគឺបានផ្តល់សោភ័ណភាពចរិតលក្ខណៈកិត្តិនាម និងផាសុខភាពដល់ទីក្រុង ។ ដូចនេះការបង្កើតសួន រុក្ខជាតិ និងលំហបៃតងគឺត្រូវតែបញ្ចូលក្នុងសមាសភាពរបស់ក្រុង និងត្រូវមានការថៃទាំសមស្រប និងបិតថេរ ។ ដោយមើលឃើញថាសួន រុក្ខជាតិ និងលំហបៃតងពិតជាមានប្រយោជន៍ចំពោះការអភិវឌ្ឍន៍ទីក្រុងអ្នកបច្ចេកទេសនៃនាយកដ្ឋាន លំហបៃតងនិងបរិស្ថានក្រុងប៉ារីសនិងការិយាល័យលំហបៃតងនិងសួនច្បារក្រុងភ្នំពេញ គឺធ្វើការគ្រប់គ្រងដើមឈើ សួនច្បារ និងទីលានមានដាំដើមឈើដោយគោរពតាមប្រពៃណីខ្មែរ[32] និងធ្វើការពិសោធន៍លើការគ្រប់គ្រងសួនច្បារដោយមានគោលការណ៍គោរពអេកូឡូហ្ស៊ីឲ្យបានល្អ និង ស្វែងរកដំណោះស្រាយឲ្យបានល្អបំផុតរវាងក្តីកង្វល់អំពីផ្នែកសេដ្ឋកិច្ចសង្គម និងបរិស្ថាន[33] ។

### ១.៣.២ បណ្តាញដឹកជញ្ជូនសាធារណៈ

[32]សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរ សាលារាជធានីភ្នំពេញ ឆ្នាំ ២០០៩។

[33]សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរ សាលារាជធានីភ្នំពេញ ឆ្នាំ ២០០៩។

កំណើនប្រជាជន និងការរីកចម្រើនយ៉ាងឆាប់រហ័សនាំតំបន់ក្រុងនៅភ្នំពេញនាំឲ្យការធ្វើដំណើរកាន់តែវែងឆ្ងាយនិងនាំឲ្យចំនួនរថយន្តមានកាន់ តែច្រើនដែលជាហេតុនាំឲ្យមានចរាចរណ៍កាន់តែសកម្មនៅលើគ្រប់ផ្លូវធំៗ ។ ផ្លូវនៅក្នុងតំបន់កណ្តាលក្រុងមានចរាចរណ៍ច្រើនដល់កម្រិតចាស់ទៅហើយៗចំណែកការអនុវត្តគម្រោងសាងសង់ធំៗបានបន្សាយបញ្ហាញព្រឹត្តិការណ៍នេះទៅលើសង្កាត់ជាយក្រុងផងដែរ ។ ការកើនឡើងនូវចំនួនប្រជាជនបែបនេះបណ្តាលវិធានការចាត់ចែងចរាចរណ៍ដែលធ្លាប់មានពីមុនពុំមានប្រសិទ្ធិភាពដូចនេះហើយគឺត្រូវឲ្យ (ក.អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់) និង (ខ.បង្កើតចំណាតរថយន្ត និងចំណាតរថយន្តសាធារណៈ) ។

**ក.ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់**

ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងសំខាន់ក្នុងរាជធានី និងសេដ្ឋកិច្ចរាជធានីមានដូចជាៈ

**១.ផ្លូវដែក**

បណ្តាញផ្លូវដែកចាកចេញពីស្ថានីយអយស្ម័យយានភ្នំពេញ[34]ទៅតាមបីទិសៈ

- ទិសឥសាន ផ្លូវដែកវាងបឹងកក់រួចឆ្ពោះទៅដល់តំបន់ឧស្សាហកម្មនៅចន្លោះផ្លូវជាតិលេខ ៥ និងទន្លេសាប ។ ទៅក្រុងព្រះសីហនុ និងបាត់ដំបងផ្លូវដែកឆ្ពោះទៅទិសខាងលិចដោយរត់ស្រប នឹងមហាវិថីសហព័ន្ធរុស្ស៊ីរហូតទៅដល់ក្បែរអាកាសយានដ្ឋានមុននិងបែកចេញជាពីទិសខាងជើង និងមួយទៀតឆ្ពោះទៅទិសខាងត្បូង ។ បណ្តាញផ្លូវដែកដែលមានតែមួយខ្សែនឹង មានគម្លាតមួយម៉ែត្រពីម្ខាងទៅម្ខាងហើយមានស្ថានភាពទ្រុឌទ្រោមព្រមទាំងជារឿយៗនៅជាប់សងខាងតែងតែមានសំណង់បណ្តោះអាសន្នរបស់ប្រជាជនក្រីក្រ ។ ផ្លូវដែកទាំងនេះ នឹងត្រូវស្តារឡើងវិញនៅរវាងឆ្នាំ២០១៤ដោយក្រុមហ៊ុន TSO ក្រោមការទំនុកបំរុងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ។ សហគមន៍អូស្ត្រាលីកម្ពុជា TOLL ដែលជាអនាគតសម្បទានិកសម្រាប់ការដឹកជញ្ជូនបានគ្រោងអភិវឌ្ឍការដឹកទំនិញ ជាពិសេសដឹកពីទីក្រុងព្រះសីហនុមក ។ ដោយមានគម្រោងសាងសង់ស្ថានីយរថភ្លើងសម្រាប់ដឹកជញ្ជូនទំនិញនៅជិតអាកាសយានដ្ឋាន ដែលក្នុងករណីយនេះគេអាចឈ្លៀតឱកាសយកផ្លូវដែកនេះមកប្រើសម្រាប់ដឹកអ្នកដំណើរពីអាកាសយានដ្ឋានមកស្ថានីយអយស្ម័យយាន និង ផ្លូវជាតិលេខ៥ នៅទិសឥសានដោយមិនចូលទៅលាយឡំជាមួយ នឹងការកកកុញចរាចរណ៍តាមផ្លូវថ្នល់ ។ គម្រោងបែបនេះគួរណាស់តែសិក្សាលទ្ធភាពបច្ចេកទេស និងសេដ្ឋកិច្ចដោយមានការពិនិត្យ

[34] ឧបសម្ព័ន្ធរូបភាព ទី ១៩

លើផលប៉ះពាល់ដល់ប្រជាជនដែលពាក់ព័ន្ធ (ការរំដោះទីកន្លែងផលប៉ះពាល់ដោយសម្លេង សុវត្ថិភាពអ្នកប្រើប្រាស់ផ្លូវ ) ។

**២.ទន្លេ**

ផ្លូវទឹកត្រូវបានប្រើប្រាស់ដើម្បីការដឹកជញ្ជូនទំនិញ និងអ្នកដំណើរព្រមទាំងអ្នកទេសចរណ៍រួចទៅហើយ ។ ការដឹកជញ្ជូនទៀងទាត់តាមកប៉ាល់[35]នៅតាមដងទន្លេសាប និងទន្លេបាសាក់អាចជាមធ្យោបាយបន្ថែមមួយសម្រាប់ការធ្វើដំណើរនៅចន្លោះតំបន់ទំនប់កប់ស្រូវនៅខាងជើង និងក្រុងតាខ្មៅនៅខាងត្បូង ។ អ្វីៗនៅសល់ដែលត្រូវកំណត់គឺជម្រើសចំណុចកំពង់ផែល្បឿនសម្រាប់ធ្វើដំណើរ និងល័ក្ខខ័ណ្ឌដែលអាចធ្វើនាវាចរណ៍បានទៅតាមរដូវ ។

ការឆ្លង ទន្លេមេគង្គ ទន្លេសាប និងទន្លេដោយទូកដរធំៗ (ដឹកអ្នកធ្វើដំណើរ និងយានជំនិះ) អាចកាត់បន្ថយបន្ទុកនៃស្ពាននានាមានដូចជា ស្ពានបង់ថ្លៃដែលសាងសង់នៅទល់មុខទំនប់កប់ស្រូវ ស្ពានជ្រោយចង្វារ និងស្ពានមុនីវង្សដែលគេបានសាងសង់មួយបន្ថែមនៅពេលថ្មីៗនេះប៉ុន្តែមានការពិបាក នឹងចូលទៅដល់ទាំងសងខាងស្ពាន។

**៣.បណ្តាផ្លូវ រុក្ខវិថី និងមហាវិថី នៅក្នុងតំបន់កណ្តាលក្រុង**

មហាវិថី និងរុក្ខវិថីនានានៅកណ្តាលក្រុង (ហ្សាដឺហ្គូល ព្រះមុនីវង្ស ព្រះសីហនុ ម៉ៅសេតុង ព្រះនរោត្តម សហព័ន្ធរុស្ស៊ី) មានទទឹង ២០ម ទៅ ៦០ម ហើយមានលទ្ធភាពទទួលនូវរាល់បណ្តាញដឹកជញ្ជូនសម្ូហភាព (រថយន្តក្រុង ត្រាំវ៉េ រថភ្លើងអាកាស ) ដែលអាចជាលំនាំបង្កើតជាគ្រោងឆ្អឹងនៃបណ្តាញដឹកជញ្ជូនរួមចម្បងហើយបន្ទាប់មកតភ្ជាប់ទៅរាល់បណ្តាញរថយន្តក្រុង ស្របទៅតាមទំហំទទឹងផ្លូវដែលតូចៗជាង ។ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិជប៉ុន (JICA) បានទទួលធ្វើការវិភាគទៅលើបច្ចេកទេស និងសង្គមសេដ្ឋកិច្ចចាំបាច់សម្រាប់កំណត់គម្រោងនេះឲ្យបានច្បាស់លាស់នៅក្នុងក្របខ័ណ្ឌការធ្វើបច្ចុប្បន្នភាពប្លង់មេឆ្នាំ ២០០១ [36]។ ផ្លូវនៅក្នុងសង្កាត់ជាយក្រុងក៏ដូចគ្នា ត្រូវតែមានគោលការណ៍ដាក់ខ្សែបណ្តាញដឹកជញ្ជូនសាធារណៈដែរ ។ ផ្លូវមួយចំនួននឹងត្រូវពង្រីកផ្លូវផ្សេងៗទៀត នឹងត្រូវបង្កើតឡើងដោយបញ្ចូលឲ្យបានល្អសមស្របនៅក្នុងបរិស្ថានដែលពាក់ព័ន្ធព្រមទាំងហេដ្ឋារចនាសម្ព័ន្ធក្នុងលំហអាកាសដែលស្ថិតនៅលើផ្លូវមានទទឹងប្រវែងពី៥០មទៅ៦០ម ។

[35] ឧបសម្ព័ន្ធរូបភាព ទី ២០

[36] សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរ សាលារាជធានីភ្នំពេញ ឆ្នាំ ២០០៩។

តំបន់កណ្តាលនៃសង្កាត់ថ្មីៗទាំងនោះអាចបញ្ចូលគ្នា នឹងប៉ូលនៃការដឹកជញ្ជូនសម្ពហភាពថ្មី ហើយនឹងជាទីកន្លែងសម្រាប់ផ្ទេរអ្នកដំណើររវាង រថភ្លើងក្រោមដី ត្រាំវ៉េ[37] រថយន្តសាធារណៈក្នុងក្រុងនិងរថយន្តបម្រើតំបន់ក្រៅក្រុងនានា ។ ទីបញ្ចប់ត្រូវតែមានគ្រោងដីបម្រុងទុកពីឥឡូវនេះទៅសម្រាប់បង្កើតឃ្លាំង និងស្ថានីយចំណតចុងផ្លូវនៃបណ្តាញដឹកជញ្ជូននេះ ។

**ខ. រៀបចំ ចំណតរថយន្ត និងចំណតរថយន្តសាធារណៈ**

**ខ.១ រៀបចំចំណតរថយន្ត**

ការលូតលាស់ក្រុងភ្នំពេញសម្តែងឡើងដោយការពន្លាតការធ្វើដំណើរ និងការកើនឡើងនូវចំនួនយានជំនិះ[38] ។ ការធ្វើដំណើរមានកាន់តែច្រើនឡើងៗគ្រួសារមានជីវភាពធូរធារការធ្វើដំណើរកាន់តែច្រើនទាក់ទងនឹងការទិញដូរ និងការកំសាន្ត ។

ស្ថានភាពរាល់ផ្លូវត្រឡែងកែងបានឈានដល់ភាពកកស្ទះយ៉ាងខ្លាំង ដូចនេះរយៈពេលធ្វើដំណើរក៏កើនឡើងដែរនៅតំបន់កណ្តាលក្រុង និងនៅតាមផ្លូវធំៗមានការចតយានយន្តស្ថិតនៅលើចិញ្ចើមថ្នល់ និងថ្នល់ដែលត្រូវទុកសម្រាប់អ្នកថ្មើរជើង និងផ្លូវសម្រាប់ម៉ូតូសព្វថ្ងៃនៅទីក្រុងភ្នំពេញចំណតរថយន្តមិនត្រូវបានរៀបចំដោយសាលាក្រុងទេគឺត្រូវចាត់ចែងឡើងនូវទីតាំងជាក់ស្តែងតាមករណីនីមួយៗអាស្រ័យទៅតាមផលប្រយោជន៍ មូលដ្ឋានជាពិសេសសម្រាប់ផលប្រយោជន៍របស់អាជីវករដែលស្ថានភាពនេះនាំឲ្យកើតមានចំណតអនាធិបតេយ្យ ។ ដូច្នេះហើយទើបសាលាក្រុងភ្នំពេញចង់ឲ្យសិក្សាអំពីការអនុវត្តការរៀបចំចំណតរួមគ្នាទៅតាមដងផ្លូវប្រកបដោយសន្តិភាពដែលនឹងអាចឲ្យ ៖

- កាត់បន្ថយទីកន្លែងគ្របដណ្តប់ដោយយានជំនិះទាំងនៅលើចិញ្ចើមថ្នល់ និងនៅលើផ្លូវថ្នល់ ។
- បំបាត់ ឬកាត់បន្ថយការកកស្ទះចរាចរណ៍ ដែលមានកាន់តែខ្លាំងឡើងៗ។
- ធ្វើឲ្យប្រសើរឡើងរាល់ចរាចរណ៍ បម្រើពាណិជ្ជកម្ម និងលំនៅស្ថាន ។
- ធ្វើឲ្យប្រសើរឡើងសម្រាប់អ្នកថ្មើរជើងនូវលើចិញ្ចើមផ្លូវ

ការសិក្សាផ្តោតទាំងទៅលើការចតរថយន្ត ទាំងការចតម៉ូតូដោយរើសយកមហាវិថីព្រះមុនីវង្សជាទីតាំងសម្រាប់អនុវត្ត[39]។ គោលបំណងនៃបេសកកម្មនេះ គឺយកជាគំរូទៅអនុវត្តសម្រាប់ផ្លូវធំៗដទៃទៀត ។

---

[37] ឧបសម្ព័ន្ធរូបភាព ទី ២១

[38] ឧបសម្ព័ន្ធរូបភាពទី ២៤

[39] ឧបសម្ព័ន្ធរូបភាព ទី ២២

**ការសិក្សាលទ្ធភាពអនុវត្តគម្រោង**

ការសិក្សាលទ្ធភាពបង្កើតចំណតបង់ប្រាក់ត្រូវបានធ្វើឡើងក្រោយពី បានធ្វើសម្រង់នានារួចមកជម្រើសនៃការរៀបចំនេះចាប់ផ្តើមឡើងដោយកំណត់ផ្លូវដើរសម្រាប់អ្នកថ្មើរជើងដែលមានទទឹងផ្លូវ ១.៥០ ម យ៉ាងតិច បន្ទាប់មកខ្សែចំនតមួយខ្សែទំហំ ១.៨០ ម ហើយបើអាចធ្វើទៅបានត្រូវបង្កើត លំហាមួយសម្រាប់តាំងទំនិញរបស់ពាណិជ្ជករ ឬអាជីវកម្មតូចៗក្រៅផ្លូវការ ឬចំណតម៉ូតូសម្រាប់ និយោជិតថែមទៀត ។

**ខ.២ រៀបចំចំណតរថយន្តសាធារណៈ**

នៅឆ្នាំ ២០០២ សំណង់ផ្សារទំនើប សូរិយា ត្រូវបានតម្រូវឲ្យផ្លូវទីតាំងនៃចំណតរថយន្ត ( បេនឡានសូរិយា) សំខាន់នៅទីក្រុងភ្នំពេញ ។ នាពេលនោះសកម្មភាពចំណតរថយន្តទាំងអស់ត្រូវប្រមូលផ្តុំនៅ ភាគពាយ័ត្យ និង និរតីនៃផ្សារធំថ្មី ។

ក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយនេះស្ថានភាពបានវិវត្តទៅមុខយ៉ាងឆាប់រហ័ស ។ ចាប់តាំងពីដើមទសវត្សឆ្នាំ ២០០០ មកផ្លូវនានាត្រូវបានជួសជុលឡើងវិញ ។ ការទំនាក់ទំនងជាមួយទីរួមខេត្តរមណីយដ្ឋានទេសចរណ៍ និងទីក្រុងធំៗនៃប្រទេសជិតខាងដូចជាទីក្រុងហូជីមិញ និងបាងកកជាដើមត្រូវបានពង្រឹងហើយជាអាទិ៍ការទំនាក់ទំនងនេះត្រូវធ្វើតាមផ្លូវថ្នល់ ពីព្រោះបណ្តាញផ្លូវរថភ្លើងមានតិចតួចណាស់ហើយចាស់ហួសសម័យទៅហើយ ព្រមទាំងមានល្បឿនយឺតពេកសម្រាប់អ្នកធ្វើដំណើរ ។ លើសពីនេះភាពទាក់ទាញសេដ្ឋកិច្ចនៃរាជធានីដែលប្រមូលផ្តុំ ៩០% នៃរោងចក្រទាំងអស់បាននាំឲ្យមានការធ្វើដំណើរនៃ ប្រជាជនកម្មករជាច្រើនមកពីជនបទដើម្បីធ្វើការនៅក្នុងវិស័យឧស្សាហកម្មក៏ដូចគ្នាដែរនៅរយៈពេលមធ្យមខាងមុខការកើនឡើង នៃចរាចរណ៍របស់អ្នកធ្វើដំណើរតាមការដឹកជញ្ជូនសម្ភាភាពតាមផ្លូវថ្នល់ តាមរថយន្តក្រុង រថយន្តក្រុងធុនមធ្យម រថយន្តភិកអាប់និងតាក់ស៊ី នឹងកើនឡើងតទៅទៀត ។ សព្វថ្ងៃនេះរាល់ស្ថានីយ៍ចតរថយន្តនានាដំណើរការជិតសាមសិបកន្លែង ហើយគេសង្កេតឃើញមានការលេចឡើងនូវចំណុចទទួលអ្នកដំណើរក្រៅផ្លូវការផងដែរ ។ ការកើនឡើងនៃសកម្មភាពចរាចរណ៍ខេត្តតាមផ្លូវថ្នល់ បណ្តាលឲ្យស្ទះចរាចរណ៍ក្នុងក្រុងដោយ សារតែមានសកម្មភាពចរាចរណ៍ និងការចតយានយន្តជាជួរវែងៗនៅលើផ្លូវថ្នល់ពេលចាំអ្នកដំណើរឡើងជិះរថយន្ត ។ ម្យ៉ាងទៀតស្ថានីយ៍សម្រាប់ចតរថយន្តនានាស្ថិតនៅកណ្តាលក្រុងរីឯប្រជាជនភ្នំពេញជាងពាក់កណ្តាលរស់នៅតាមខណ្ឌជុំវិញក្រុង ដូច្នេះចាំបាច់ត្រូវតែរៀបចំស្ថានីយ៍ចំណតរថយន្តនៅទីក្រុងភ្នំពេញឡើងវិញឲ្យបានល្អ ដើម្បីបង្កើតគុណភាពឲ្យបានប្រសើរឡើងនិង

ងាយស្រួលដល់ការប្រើប្រាស់ក្នុងការដឹកជញ្ជូនដែលគេមិនអាចជៀសរួច ។ ដោយហេតុនេះការប្តូរទីតាំងស្ថានីយ៍ ចំណតរថយន្តសម្រាប់អ្នកដំណើរពីកណ្តាលក្រុងទៅតំបន់ជាយក្រុងត្រូវបានសិក្សាក្នុងក្របខ័ណ្ឌសហប្រតិបត្តិការប៉ារីស-ភ្នំពេញ។ ផ្អែកលើមូលដ្ឋាននៃការសិក្សាស្ថានីយ៍ចំណតរថយន្តនៅភ្នំពេញ និងការសង្កេតមើលចំណតរថយន្តនៅភ្នំពេញនៅទីក្រុងហាណូយ និងហូជីមិញគេអាចស្នើបង្កើតចំណតរថយន្តគម្រូមួយដែលមានដំណើរការល្អ ហើយដែលអាចកាត់បន្ថយការប្រឆាំងដែលអាច នឹងកើតមានឡើងរវាងយានយន្ត និងយានយន្ត អ្នកថ្មើរជើង និងយានយន្ត ។ ស្ថានីយចំណតរថយន្តសាធារណៈជាទីប្រជុំ (ប៉ូល) មធ្យោបាយដឹកជញ្ជូនដែលអ្នកដំណើរអាចប្តូរប្រភេទយានជំនិះសម្រាប់ធ្វើដំណើរបន្តតាមតម្រូវការ។ ដូច្នេះចំណតប្រមូលផ្តុំមុខងារមួយចំនួយដែលរៀបចំឡើងនៅក្នុងលំហមួយដើម្បីឲ្យអ្នកដំណើរអាចទៅរកវាល់មធ្យោបាយដឹកជញ្ជូនដែលខ្លួនត្រូវការ និងទៅរកសេវានានាដែលខ្លួនត្រូវការសម្រាប់ធ្វើដំណើរដោយដើរជិតបំផុត ។ ស្ថានីយចំណតរថយន្តនៅភ្នំពេញមានកន្លែងសម្រាប់ឲ្យអ្នកដំណើរចុះឡើងទីកន្លែងចំណតសម្រាប់យានយន្តដែលដឹកអ្នកដំណើរមក (ម៉ូតូរឺម៉ក ម៉ូតូឌុប តាក់ស៊ីម៉ែត្រ) ទីកន្លែងសម្រាប់យានយន្តអន្តរជាតិ-ខេត្ត (រថយន្តក្រុងធុនធំ និងធុនមធ្យម រថយន្តភីកអាប់ តាក់ស៊ី សាធារណៈ) អាគារលក់សំបុត្រនិងសេវាកម្មចំណតរយៈពេលវែងដែលរួមមានសេវានានា(ការជួសជុលស្ថានីយ៍ប្រេងឥន្ធនៈកន្លែងលាងយានយន្ត។ល។)សមាសភាគនីមួយៗត្រូវតែកំណត់ទំហំតាមសកម្មភាពនៅពេលម៉ោងមានចរាចរណ៍កកកុញ និងដោយយោងទៅលើប្រភេទដំណើរការរបស់ការដឹកជញ្ជូនផ្សេងៗ (ចេញដំណើរតាមម៉ោងកំណត់ចេញដំណើរនៅពេលមានអ្នកដំណើពេញ ) ។ ផ្ទៃក្រឡាដីចាំបាច់សម្រាប់ផ្លូវជាតិនីមួយៗទាំងប្រាំមួយខុសគ្នាពី៦២០០ម² ទៅ ២៤១០០ម² ដោយមានផ្ទៃក្រឡាមធ្យម ១៤៧០០ម² ។ ការរៀបចំដែលបានជ្រើសរើសត្រូវការដីធំបន្តិពីព្រោះមុខការទាំងអស់ស្ថិតនៅលើជាន់តែមួយប៉ុន្តែក៏ត្រូវចំណាយតិចដែរចំពោះការកសាងហេដ្ឋារចនាសម្ព័ន្ធ និងអាចកសាងបានយ៉ាងឆាប់រហ័ស ។ នៅពេលខាងមុខដើម្បីបង្កើនសមត្ថភាពស្ថានីយ៍ចំណតរថយន្ត។ ដីមួយផ្នែកគឺកន្លែងចំណតងាចសាងសង់ជាច្រើនជាន់បានហើយលំហខ្លះអាចធ្វើជាសម្បទានទៅឲ្យពាណិជ្ជករដើម្បីផ្តល់សេវាដល់អ្នកដំណើរ។

**ទីតាំងចំណតនៅលើផ្លូវជាតិ**

នៅក្នុងប្លង់មេប្រព័ន្ធដឹកជញ្ជូនឆ្នាំ ២០០១ ដែលកំពុងតែធ្វើបច្ចុប្បន្នភាពឡើងវិញស្ថានីយចំណតត្រូវស្ថិតនៅជាយក្រុង និងនៅលើផ្លូវជាតិលើកលែងតែផ្លូវជាតិលេខ ៣ ។

បច្ចុប្បន្ននេះចរាចរណ៍គឺតម្រូវឲ្យបង្កើតឲ្យមាននូវស្ថានីយ៍ចំនតនៅលើផ្លូវជាតិនីមួយៗ ។ ប៉ុន្តែសម្រាប់ផ្លូវជាតិលេខ ៣ និងលេខ ៤ ដែលមានចរាចរណ៍ស្ថិតក្នុងចំណោមចរាចរណ៍ខ្សោយ

ជាងគេរូបរាងប្រព័ន្ធនៃផ្លូវទាំងពីរនេះអាចឲ្យគេប្រមូលផ្តុំយានយន្តនៅក្នុងចំណតតែមួយនៅចំណុចប្រសព្វនៃផ្លូវទាំងពីរបាននៅខាងត្បូងអាកាសយានដ្ឋាន ។ ដូច្នេះមានចំណតរថយន្តចំនួន៥ដែលត្រូវបង្កើតនៅក្នុងខណ្ឌជាយក្រុងភ្នំពេញ ។ ការប្តូរទីតាំងស្ថានីយចំណតបានផ្តល់ លំហាទំនេរខ្លះជាពិសេសនៅជិតផ្សារកណ្តាលក្រុងដែល នឹងអាចឲ្យគេរៀបចំឡើងវិញនូវសេវាកម្ម ការចត និងការទម្លាក់ទំនិញដែលបច្ចុប្បន្ននេះនឹងបង្កឲ្យមានភាពលំបាកហើយនេះជាចំណុចវិជ្ជមាន ។ ប៉ុន្តែការបង្កើតចំណតនៅជាយក្រុង និងធ្វើឲ្យមានតម្លៃបន្ថែមសម្រាប់អ្នកធ្វើដំណើរមួយចំនួន ។ ដូចនេះត្រូវរកដំណោះស្រាយសម្រាប់បញ្ហានេះ ។ ខ្សែដឹកជញ្ជូនពីប៉ូលមួយទៅប៉ូលមួយ (ដោយមិនតម្រូវឲ្យចំណតឈប់តាមផ្លូវ)ដោយភ្ជាប់ពីតំបន់កណ្តាលក្រុងភ្នំពេញទៅ និងចំណតនានាជាជំហានទីមួយត្រូវធ្វើមុនគេ ។ បន្ទាប់មកទៀតខ្សែគមនាគមន៍ទាំងនេះអាចនឹងវិវត្តបាន និងអាចក្លាយជាខ្សែរចនាសម្ព័ន្ធគមនាគមន៍នៃបណ្តាញដឹកជញ្ជូនរួម ។

# ជំពូកទី ២

# ទីក្រុងសិង្ហបុរី

## ជំពូកទី២ ទីក្រុងសិង្ហបុរី

សាធារណរដ្ឋសិង្ហបុរី ឬ សាំងហ្គាពួរជាអក្សរឡាតាំងគឺ REPUBLIC OF SINGAPORE ជាប្រទេសកោះស្ថិតនៅចុងខាងត្បូងនៃឧបទ្វីបម៉ាឡេ[37] ហើយក៏ជាមជ្ឈមណ្ឌលហិរញ្ញវត្ថុឈានមុខគេក្នុងចំណាត់ថ្នាក់លេខ ៤ នៅលើពិភពលោក ដែលដើរតួនាទីយ៉ាងចំបងក្នុងវិស័យពាណិជ្ជកម្ម និងហិរញ្ញវត្ថុអន្តរជាតិដែលមានកំពង់ផែរមមាញឹកជាងគេក្នុងលោក[38] ។ នៅសិង្ហបុរីមានប្រជាជនច្រើនជាតិសាសន៍រស់នៅដែលក្នុងចំណោមប្រជាជនជាង ៥លាននាក់មានតែ ២,៩១លាននាក់ទេដែលកើតនៅទីនោះមានន័យថា ៤៣% នៃប្រជាជនសិង្ហបុរីមកពីបរទេស[39] ។ ប្រជាជនសិង្ហបុរីចម្រុះដោយជាតិសាសន៍អាស៊ីជាពិសេស ចិន ម៉ាឡេ ឥណ្ឌា និងអំបូរ ជនជាតិកូកាស់[40] ហើយមានកម្លាំងពលកម្មក្នុងប្រទេស ៥០% ជាជនបរទេស[41] ។

### ២.១ ទិដ្ឋភាពទូទៅនៃទីក្រុងសិង្ហបុរី

#### ២.២.១ ប្រវត្តិទីក្រុងសិង្ហបុរី

សិង្ហបុរីមានន័យថាបុរីនៃសត្វសិង្ហ[42] ដែលមានរឿងតំនាលថាមានស្តេចមួយអង្គបានជួបព្យុះសង្ឃរាពេលធ្វើដំណើរតាមសំពៅរួច ក៏ចូលសុំចតនៅកោះមួយ ។ ស្តេចនោះក៏បានប្រទះឃើញលើឆ្នេរខ្សាច់មានសត្វមួយក្បាលដែលមានរាង ដូចជាសត្វតោរួចក៏សន្មត់ដាក់ឈ្មោះកោះមួយនោះថាជាបុរីនៃសត្វសិង្ហ ។ តែតាមការសិក្សានាពេលថ្មីៗនេះបានឲ្យដឹងថាកោះនេះមិនធ្លាប់មានសត្វតោរស់នៅទេសត្វតោក្នុងរឿងនិទាននោះអាចជា សត្វខ្លាម៉ាឡាយ៉ាន ហើយបើតាមឯកសារបញ្ជាក់ថាមានមនុស្សមករស់នៅកោះសិង្ហបុរីតាំងពី សតវត្សរ៍ទី ២ នៃគ.ស ។ កោះនេះដើមឡើយជាដែនដីរបស់ចក្រភពស្វ៊ម៉ាត្រានស្រីវិចាយ៉ា (នគរស្រីវិជ័យ) និងមានឈ្មោះដើមជាភាសាជ្វាថា តេម៉ាសេក ( Temasek ទីក្រុងសមុទ្រ) តេម៉ាសេកធ្លាប់ជាតំបន់ជំនួញដ៏មមាញឹកមុន នឹងធ្លាក់ចុះខ្សោយនៅចុងសតវត្សរ៍ទី១៤ ។ នៅរវាងសតវត្សរ៍ទី១៦និងទី១៩កោះសិង្ហបុរីជាផ្នែកមួយនៃរាជាណាចក្រស៊ុលតង់ចូហារ ។ ពួកព័រទុយហ្គាល់និងហុល្លង់បានមកគ្រប់គ្រងកោះនោះនៅសតវត្សរ៍ទី១៧ ក្នុងអំឡុងពេល

---

[37] ឧបសម្ព័ន្ធរូបភាព ទី ១

[38] សិង្ហបុរីរក្សាងារជាកំពង់ផែមមាញឹកជាងគេលើលោក ។ ឆាណែល ញូស៍អេស៊ា (Singapore)

[39] ជំរឿនប្រជាជនឆ្នាម ២០១០ ស្ថិតិផ្តល់លើកទី ១ បុគ្គលិកលក្ខណៈប្រជាសាស្ត្រ និងសាសនា ២០១០

[40] ស្ថិតិសិង្ហបុរី ទិន្នន័យថ្មីបំផុត ២០១០

[41] និន្នាការក្នុងទីផ្សារអន្តោប្រវេសន៍អន្តរជាតិ៖ កំណែឆ្នាំ ២០០៨ អង្គការសហប្រជាជាតិ,នាយកដ្ឋានសេដ្ឋកិច្ច និងកិច្ចការសង្គម

[42] ឧបសម្ព័ន្ធរូបភាព ទី ២

នោះប្រជាជនលើកោះភាគច្រើនជាអ្នកនេសាទ ។ រហូតមកដល់សម័យអាណានិគមលោកថូម៉ាស់ស្តេមហ្វដរ៉ាហ្វល (Sir Thomas Stamford Raffles) ដែលបានចុះចតនៅសិង្ហបុរីនៅថ្ងៃទី ២៨ មករា ឆ្នាំ១៨១៩ ដែលបានកត់សំគាល់ឃើញថាសិង្ហបុរីជាទីតាំងជំនួញដ៏មានសក្តានុភាពនៅអាស៊ីដែលតំណាងអោយក្រុមហ៊ុន British East India លោកក៏បានចុះសន្ធិសញ្ញាជាមួយព្រះចៅស៊ុលតង់ហ៊ូសសេនស្សា (Sultan Hussein Shah) នៅថ្ងៃទី៦ កុម្ភៈ ១៨១៩ ក្នុងគោលបំណងអភិវឌ្ឍន៍តំបន់ខាងត្បូងរបស់សិង្ហបុរីអោយក្លាយជាទីតាំងជំនួញនិងស្នាក់នៅរបស់ចក្រភពអង់គ្លេស ។ នៅថ្ងៃទី ២ ខែសីហា ឆ្នាំ ១៨២៤ សិង្ហបុរីបានក្លាយជាដែនដីអាណានិគមពេញសិទ្ធិរបស់ចក្រភពអង់គ្លេសបន្ទាប់ពីរេស៊ីដង់ទី២របស់សិង្ហបុរីឈ្មោះ ចន ក្រហ្វេដ (John Craw Furd ) បានចុះកិច្ចព្រមព្រៀងជាមួយព្រះចៅស៊ុលតង់ ហ៊ូសសេនស្សា ដែលក្នុងនោះព្រះចៅស៊ុលតង់យល់ព្រមប្រគល់កោះសិង្ហបុរីទាំងមូលទៅអោយក្រុមហ៊ុន British East India ។ មកដល់ឆ្នាំ១៨៦៩ មានមនុស្សប្រហែល ១សែននាក់រស់នៅលើកោះនេះ ។ ការគ្រប់គ្រងនគរូបនីយកម្មរបស់សិង្ហបុរីនៅសម័យអាណានិគមមានលក្ខណៈជា«ការបែងចែកដើម្បីគ្រប់គ្រង» មានន័យថាក្រុមមនុស្សប្រភេទផ្សេងគ្នារស់នៅតាមតំបន់ផ្សេងគ្នា។ ស្នឹងសិង្ហបុរីដែលជា តំបន់ពាណិជ្ជកម្មដ៏ធំនិងជាទីតាំងរស់នៅរបស់ពួកពាណិជ្ជករម្ចាស់ធនាគារចំរុះជាតិសាសន៍ហើយសំបូរទៅដោយកម្មករលើកដាក់ទំនិញជនជាតិ ចិន និង ឥណ្ឌា ។ ជនជាតិម៉ាឡេភាគច្រើនជាអ្នកនេសាទ និង អ្នកដើរសមុទ្ររស់នៅប៉ែកអាគ្នេយ៍ខាងចុងស្ទឹងជាមួយពាណិជ្ជករនិងបញ្ញាវ័នជនជាតិអារ៉ាប់ ។ ជនជាតិអឺរ៉ុបមានតិចតួចនៅឡើយដែររស់នៅម្តុំ Fort Canning Hill និងនៅខាងដើមស្ទឹងសិង្ហបុរី ។ នៅក្នុងសង្គ្រាមលោកលើកទី២កងទ័ព ព្រះចៅអធិរាជជប៉ុន បានឈ្លានពានតំបន់ម៉ាឡាយ៉ា និងបានបំផ្ទុះសមរភូមិជាមួយសិង្ហបុរី ។ កងទ័ពអង់គ្លេសដែលមិនបានត្រៀមខ្លួនជាមុនបានចុះចាញ់ក្នុងរយៈពេល៦ថ្ងៃនៃការប្រយុទ្ធគឺនៅថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ១៩៤២ ។ កងទ័ពជប៉ុនបានប្តូរឈ្មោះកោះសិង្ហបុរីទៅជា ស្យូណាន់តូ[7] រយៈពេល១ខែក្រោយពីជប៉ុនបានចាញ់សង្គ្រាមលោក ពួកអង់គ្លេសបានវិលត្រលប់មកកាន់កាប់កោះ វិញនៅថ្ងៃទី១២ កញ្ញា ឆ្នាំ១៩៤៥ ។ បន្ទាប់ពីសង្គ្រាម រដ្ឋាភិបាលអង់គ្លេសបានផ្តល់សិទ្ធិអោយសិង្ហបុរីរៀបចំការបោះឆ្នោតសកលដំបូងរបស់ខ្លួននៅឆ្នាំ១៩៥៥ ។ អ្នកឈ្នះឆ្នោតជាបេក្ខជនគាំទ្រឯករាជ្យភាពឈ្មោះដេវីដម៉ារស្សេល (David Marshall) ជាមេដឹកនាំគណបក្សរណសិរ្សពលកម្ម (Labor Front Party) ។ ដើម្បីសុំស្វ័យភាពពេញបរិបូណ៌ ម៉ារស្សេល បានដឹកនាំប្រតិភូមួយក្រុមទៅក្រុងឡុងដុងប៉ុន្តែត្រូវអង់គ្លេសបដិសេធ ។ លោកបានលាលែង ពីដំណែងពេលត្រលប់មកដល់សិង្ហបុរីវិញភ្លាមហើយតំណែងលោកត្រូវជំនួសដោយ

[7] "សិង្ហបុរី, ស្យូណាន់ះ ពន្លឺនៅខាងត្បូង"

លោក លីម យូហុក (Lim Yew Hock) ។ សិង្ហបុរីក្លាយជារដ្ឋស្វ័យគ្រប់គ្រងក្នុងចក្រភពអង់គ្លេសក្នុងឆ្នាំ ១៩៥៩ ដោយមាននាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីផ្ទាល់ខ្លួនសំរាប់មើលការខុសត្រូវកិច្ចការរដ្ឋាភិបាលលើកលែងតែវិស័យការពារជាតិ និងកិច្ចការបរទេស ។ នៅក្នុងការបោះឆ្នោតថ្ងៃទី៣០ ខែឧសភា ឆ្នាំ ១៩៥៩ គណបក្សសកម្មភាពប្រជាជន (People's Action Party) បានឈ្នះឆ្នោតយ៉ាងភ្លូក់ទឹកភ្លក់ដី ។ ក្រោយមកសិង្ហបុរីបានក្លាយជារដ្ឋស្វ័យគ្រប់គ្រងនៅក្នុងខំមិនវ៉េល ហើយបន្ទាប់មកលោក លីក្វាន់យូ (Lee Kuan Yew) បានស្បថចូលកាន់តំណែងជានាយករដ្ឋមន្ត្រីដំបូងគេនៅថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ១៩៥៩ ។ សិង្ហបុរីប្រកាសឯករាជ្យពី អង់គ្លេសជាឯកតោភាគីនៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៦៣ មុនពេលចូលជាសមាជិកសហព័ន្ធម៉ាឡេស៊ីនៅក្នុងខែ កញ្ញា។ រយៈពេល២ឆ្នាំក្រោយមកសិង្ហបុរីបានដើរចេញពីសហព័ន្ធម៉ាឡេស៊ី មូលហេតុបន្ទាប់ពីមានការខ្វែងគំនិតយ៉ាងក្តៅគគុកជាមួយរដ្ឋាភិបាលសហព័ន្ធម៉ាឡេស៊ី ។ សិង្ហបុរីបានទទួលអធិបតេយ្យភាពជាផ្លូវការនៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៦៥។ លោក យូសូហ្វ ប៊ីនអ៊ីស្សាក ( Yusof Bin Ishak ) បានចូលស្បថកាន់តំណែងជាប្រធានាធិបតី ដោយលោក លីក្វាន់យូ នៅតែជានាយករដ្ឋមន្ត្រី ។ ក្រោយពីសាធារណរដ្ឋសិង្ហបុរីបំបែកខ្លួនចេញ ពីសម្ព័ន្ធភាពប្រទេសម៉ាឡេស៊ីសាធារណរដ្ឋសិង្ហបុរីបានជួបបញ្ហាប្រឈមជាច្រើនកើតឡើងក្នុងប្រទេស ដែលមានវិបត្តិសង្គមធំៗត្រូវដោះស្រាយដោយខ្លួនឯងរួមមានបញ្ហាប្រឈមចំនួនបីគឺ (១)បញ្ហាប្រជាពលរដ្ឋអត់ការងារធ្វើ (២)វិបត្តិគ្មានផ្ទះសម្បែង និងដីគ្រប់គ្រាន់សម្រាប់រស់នៅ (៣)ប្រជាពលរដ្ឋជួបបញ្ហាខ្វះធន់ធានធម្មជាតិប្រើប្រាស់ដូចជាប្រេងឥន្ធនៈជាដើម ។ ប៉ុន្តែយ៉ាងណាក៏ដោយបញ្ហាទាំងនោះមិនត្រូវបានប្រងើយកន្តើយឡើយ ។ រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរីបានចាប់ផ្តើមអភិវឌ្ឍប្រព័ន្ធ័របស់ខ្លួនដំណាក់កាលដំបូងតាម ផែនការយុទ្ធសាស្ត្រនៃគោលនយោបាយរៀបចំទីក្រុង ។ ក្នុងខណៈពេលនោះការរៀបចំគោលនយោបាយរៀបចំទីក្រុងសិង្ហបុរីមានបញ្ហាប្រឈមច្រើនកើតឡើង ហើយបញ្ហាប្រឈមជាខ្លាំងនោះគឺជាមួយ នឹងការរៀបចំទីក្រុង ។ ហាង លីម អ្នកស្រាវជ្រាវរបស់វិទ្យាស្ថានសិង្ហបុរីសម្រាប់កិច្ចការអន្តរជាតិបានលើកឡើងដោយមានក្តីបារម្ភថាទីក្រុងសិង្ហបុរីជួបបញ្ហាជាច្រើនដោយមូលហេតុ មានចំនួនប្រជាជនរស់នៅក្នុងទីក្រុងកើនឡើងច្រើនយ៉ាងឆាប់រហ័សក្នុងរយៈពេលដ៏ខ្លី ។ ដូច្នេះការកើតឡើង និងចំនួនកើនឡើងនេះនាំឲ្យការរៀបចំទីក្រុងមានការពិបាកផងដែរ[44] ។ រដ្ឋាភិបាលសាធារណៈសិង្ហបុរីបានដាក់ចេញផែនការអភិវឌ្ឍទីក្រុងឲ្យក្លាយជាទីក្រុងដែលមានសេដ្ឋកិច្ចរឹងមាំ។

[44]ហាង លីម (មីនា ២០០៨)ជំពូកទី៨ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេសសិង្ហបុរីអាចចូលមើលលម្អិតបានក្នុង http://eew.eria.org/publications/research_project_reports/images/pdf/PDF%20No.2-part2-8.Singapore.pdf។

### ២.១.២ ភូមិសាស្ត្រទីក្រុងសិង្ហបុរី

សិង្ហបុរីកើតឡើងពីកោះសរុបចំនួន ៦៣ កោះដែលកោះធំជាងគេគឺ កោះសិង្ហបុរី ។ កោះសិង្ហបុរីមានឈ្មោះជាផ្លូវការថា ពូឡៅអ៊ូជុង ។ កោះសិង្ហបុរីភ្ជាប់ទៅខេត្តចូហរ (ម៉ាឡេស៊ី) ដោយផ្លូវសិប្បនិម្មិត២ គឺ Johor- Singapore Causeway នៅខាងជើង និង Tuas Second Link នៅខាងលិច និងកោះសំខាន់ៗមួយចំនួនផ្សេងទៀតដែលមានដូចជា៖ កោះជូរុង[45] (JurongIsland) កោះតេកុង[46] (PulauTekong) កោះអ៊ូប៊ីន[47] (Pulau Ubin) និងកោះសេនតូសា[48] (Sentosa)។ ចំនុចធម្មជាតិខ្ពស់ជាងគេនៅសិង្ហបុរី គឺកូនភ្នំប៊ូគីតទីម៉ា (Bukit Timah Hill) ដែលមានកំពស់រហូតដល់ទៅ ១៦៦ម៉ែត ។ តាំងពីឆ្នាំ ១៩៦០ រដ្ឋាភិបាលសិង្ហបុរីបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការកសាងក្រុងដែលជាលទ្ធផលសិង្ហបុរីបច្ចុប្បន្នមានទេសភាពជាទីក្រុងទាំងស្រុង ។ សិង្ហបុរីមានគំរោងវាតទីដីពីសមុទ្រដោយយកដីពីកូនភ្នំនានារបស់ខ្លួន និងដីពីបាតសមុទ្រ និងពីប្រទេសជិតខាងមកចាក់បំពេញ ។ ជាលទ្ធផលផ្ទៃដីសិង្ហបុរីបានកើនឡើងពី ៥៨១,៥គ.ម$^{2}$ ក្នុងឆ្នាំ ១៩៦០ មកដល់ ៧០៥គ.ម$^{2}$ ក្នុងពេលបច្ចុប្បន្ន។ សិង្ហបុរីមានគំរោង នឹងពង្រីកបន្ថែម ១០០ គ.ម$^{2}$ ទៀតមុនឆ្នាំ២០៣០[49] ។ គំរោងនេះក៏បានតភ្ជាប់កោះតូចៗនានាទៅកាន់កោះធំៗតាមរយៈការចាក់ដីតភ្ជាប់ផងដែរ ។ ប្រហែល ២៣% នៃផ្ទៃដីរបស់កោះសិង្ហបុរីត្រូវបានរក្សាឲ្យនៅជាព្រៃ និងឧទ្យានជាតិ និងធម្មជាតិហើយឧទ្យានជាតិធំជាងគេនៅសិង្ហបុរីដែលត្រូវបានការពារគឺឧទ្យានរុក្ខជាតិសិង្ហបុរី (Singapore Botanic Garden) ដែលមានទំហំ ៦៧,៣ ហិចតា ។ សិង្ហបុរីគ្មានស្ទឹង ឬបឹងទឹកសាបធម្មជាតិនោះទេ ចំពោះប្រភពផ្គត់ផ្គង់ទឹកសាបនៅក្នុងស្រុកវិញចំបងជាងគេនោះគឺ ទឹកភ្លៀងដែលត្រូវបានស្តុកទុកក្នុងអាងសិប្បនិម្មិត ដែលទឹកភ្លៀងផ្គត់ផ្គង់ទឹកសាបប្រមាណ ៥០% ហើយនៅសល់ ៥០% ទៀតគឺនាំចូលពីប្រទេសជិតខាង និង បានពីរោងចក្រចំរាញ់ទឹកស្អាតប្រើប្រាស់ឡើងវិញ ។ រដ្ឋាភិបាលមានគំរោងបង្កើនចំនួនរោងចក្រចំរាញ់ទឹកពីទឹកសមុទ្រដើម្បីកាត់បន្ថយការពឹងផ្អែកលើទឹកនាំចូល នឹងទឹកភ្លៀង ។ សិង្ហបុរីមានអាកាសធាតុតែមួយគត់គឺអាកាសធាតុត្រូពិច និងគ្មានរដូវដាច់គ្នាស្រលះទេហើយសីតុណ្ហភាព និងសំពាធថេរមានសំណើមខ្ពស់និងកំពស់ទឹកភ្លៀងខ្ពស់ ។ សីតុណ្ហភាពប្រែប្រួលពី ២២ ទៅ ៣៤ អង្សាសេដែលមានសំណើមជាមធ្យមគឺ ៩០% នៅពេលព្រឹក និង ៦០ % នៅពេលរសៀល ។ សីតុណ្ហភាពទាបបំផុតក្នុងប្រវត្តិសាស្ត្រគឺ ១៩.៤ និង ខ្ពស់បំផុត គឺ ៣៦.០ ។ ចំពោះខែ ឧសភា និងមិថុនា

---

[45] ឧបសម្ព័ន្ធរូបភាព ទី ៣

[46] ឧបសម្ព័ន្ធរូបភាព ទី ៤

[47] ឧបសម្ព័ន្ធរូបភាព ទី ៥

[48] ឧបសម្ព័ន្ធរូបភាព ទី ៦

[49] "ឆ្ពោះទៅកាន់និរន្តរភាពបរិស្ថាន, របាយការណ៍បរិស្ថានឆ្នាំ២០០៥

ជាខែក្តៅជាងគេហើយខែ វិច្ឆិកា និង ខែធ្នូជាខែដែលមាន សំនើមខ្ពស់ជាងគេ និងចាប់ពីខែ សីហា ដល់ខែ តុលា ខ្យល់មានលក្ខណៈស្ងួត ។

## ២.១.៣ ការគ្រប់គ្រងប្រទេសសិង្ហបុរី និង ប្រពន្ធ័នយោបាយដឹកនាំរដ្ឋ

## ក.ការបែងចែកអំណាចទាំងបីក្នុងការគ្រប់គ្រងរដ្ឋ

សម្លេងគាំទ្រពីអ្នកបោះឆ្នោត រួមទាំងការបែងចែកអំណាចក្នុងរបបដឹកនាំរដ្ឋនៃសាធារណរដ្ឋសិង្ហបុរី គឺពុំសូវមានភាពខុសប្លែកគ្នាច្រើនទេប្រសិនបើធ្វើការប្រៀបធៀបការដឹកនាំទៅ នឹងប្រទេសមួយចំនួនដែលអនុវត្តនូវគោលការណ៍ប្រជាធិបតេយ្យអាស្រ័យរដ្ឋសភា ក៏ប៉ុន្តែការបែងចែកអំណាចរបស់រដ្ឋ គឺពុំមែនមានន័យថាសាធារណរដ្ឋសិង្ហបុរីបានធ្វើការបែងចែកអំណាចបីដាច់ដោយឡែកពីគ្នានោះឡើយដែលមាន (១)អំណាចនីតិបញ្ញត្តិ (២)អំណាចនីតិប្រតិបត្តិនិង(៣)អំណាចតុលាការ។[50]

### ក.១ ស្ថាប័នអំណាចនីតិប្បញ្ញត្តិ

អំណាចនីតិបញ្ញត្តិ គឺជាស្ថាប័នជាន់ខ្ពស់ដែលមានអំណាចក្នុងការបង្កើតច្បាប់ ។[51] ស្ថាប័នសភាជាន់ខ្ពស់នេះ មានសមត្ថកិច្ចបង្កើតច្បាប់នានា សម្រាប់គ្រប់គ្រងអង្គភាពនយោបាយតាមថ្នាក់ក្រុង និងថ្នាក់ប្រទេស ។ សមាជិកទាំងឡាយរបស់ស្ថាប័ននីតិបញ្ញត្តិ ជានីតិបញ្ញត្តិជនដែលត្រូវបានបោះឆ្នោតជាប់ទើបមានអំណាចអាចបង្កើតច្បាប់ហើយ និងអនុម័តច្បាប់បាន ។ តាមគោលការណ៍នៃច្បាប់ដែលបានបញ្ញត្តិ ។ ហើយជនទាំងអស់គឺត្រូវចូលរួមប្រជុំពិភាក្សាបញ្ហានយោបាយ និងត្រូវចូលរួមបោះឆ្នោតអនុម័តច្បាប់តាមការស្នើសុំពីរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី ។ នៅក្នុងបរិបទនយោបាយនៅក្នុងប្រទេសសិង្ហបុរី បញ្ញត្តិជនទាំងឡាយដែលជាប់ឆ្នោតមានតួនាទី នៅក្នុងស្ថាប័នរដ្ឋសភានៃសាធារណរដ្ឋសិង្ហបុរី តែពុំមានសិទ្ធអំណាចដូចអ្នកនយោបាយ ដែលមានតួនាទីជាប្រតិបត្តិករនៃច្បាប់ដែលមានអំណាចគ្រប់គ្រាន់ក្នុងការដឹកនាំ និងអនុវត្តតាមច្បាប់កំណត់។

### ក.២ ស្ថាប័ននីតិប្រតិបត្តិ

អនុលោមតាមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសិង្ហបុរីរដ្ឋាភិបាលសិង្ហបុរី គឺជាស្ថាប័នតែមួយគត់ដែលមានអំណាចខាងនីតិប្រតិបត្តិ[52]។ អំណាចនីតិប្រតិបត្តិគឺជាអំណាចស្របច្បាប់ក្នុងការគ្រប់គ្រង

[50]នយោបាយប្រទេសសិង្ហបុរី, ក្នុង https://en.mwikipedia.org/legislative។

[51] នីតិប្បញ្ញត្តិ. ក្នុង https://en.mwikipedia.org/wiki/legislative។

[52] រដ្ឋាភិបាលនៃប្រទេសសិង្ហបុរី, ក្នុង https://en.mwikipedia.org/wiki/government_of_Singapore។

ប្រទេសតាមរយៈការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តតាមរយៈនីតិវិធី នៃការជ្រើសរើស ហើយនិងការតែងតាំងរដ្ឋាភិបាលក្នុងអង្គប្រជុំសភាដំបូង ។ ជាទូទៅនៅពេលគណបក្សនយោបាយណាមួយឈ្នះឆ្នោតដោយទទួលសំលេងគាំទ្រលើសលប់ នឹងត្រូវបានស្នើឲ្យរៀបចំគណៈរដ្ឋមន្ត្រី ។ រដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីរៀបចំរចនាសម្ពន្ធ័ដឹកនាំរដ្ឋាភិបាលរួមមាន (១)នាយករដ្ឋមន្ត្រីដែលជាតំណែងដែលផ្តល់សេចក្តីទុកចិត្តដោយអង្គសមាជិកសភាទាំងមូលដែលមានចំនួន១០០រូប នឹង(២)នាយករដ្ឋមន្ត្រីអាចតែងតាំងរដ្ឋមន្ត្រីជាច្រើនរូបជាទីប្រឹក្សានាយករដ្ឋមន្ត្រី ដែលជាទូទៅអ្នកទាំងនោះអាចធ្វើជួយដឹកនាំ និងគ្រប់គ្រងរដ្ឋាភិបាលរួមគ្នាជាមួយនាយករដ្ឋមន្ត្រីបាន។

### ក.៣ ស្ថាប័នអំណាចតុលាការ

ស្ថាប័នអំណាចតុលាការជាស្ថាប័នមួយឯករាជ្យ ។ ប្រធានស្ថាប័ននេះត្រូវបានតែងតាំងឡើងដោយនាយករដ្ឋមន្ត្រីកាន់តំណែង ជាប្រមុខរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ។ [53]ស្ថាប័នតុលាការជាស្ថាប័នកំពូលដែលត្រូវបានគេចែកចេញជា ពីរ លើការជំនុំជម្រះករណីបទល្មើសដូចជា (១) តុលាការឧទ្ធរណ៍ (២) តុលាការជាន់ខ្ពស់ ។ តុលាការឧទ្ធរណ៍កាត់ក្តីដោយសើរើបណ្តឹងជាថ្មីនៃបទល្មើសស៊ីវិល និងបទល្មើសព្រហ្មទណ្ឌចំណែកតុលាការជាន់ខ្ពស់កាត់ក្តីករណីបណ្តឹងដើមនិងដោយសើរើបណ្តឹងលើបទល្មើសព្រហ្មទណ្ឌផង និងបទល្មើសស៊ីវិលផង។

### ខ. ប្រព័ន្ធនយោបាយដឹកនាំ

ក្នុងឆ្នាំ ១៩៥៦ សាធារណរដ្ឋសិង្ហបុរីបានរៀបចំការបោះឆ្នោតទូទៅមួយសម្រាប់ជ្រើសរើសនាយករដ្ឋមន្ត្រីដើម្បីដឹកនាំប្រទេសសិង្ហបុរី ។ លោក លីខ្វាន់យូ ជាបេក្ខភាពនាយករដ្ឋមន្ត្រីមកពីគណបក្សសកម្មភាពប្រជាជន (People's Action Party) ដែលគណបក្សទទួលបានជ័យជម្នះជាច្រើនអាណត្តិចាប់តាំងពីមានការបោះឆ្នោតដំបូងក្នុងឆ្នាំ ១៩៥៩ ហើយរហូតមកដល់បច្ចុប្បន្ននេះក៏គណបក្សនេះនៅតែឈ្នះឆ្នោតដឹកនាំ នឹងគ្រប់គ្រងសាធារណរដ្ឋសិង្ហបុរីទៅទៀតផងដែរ ។ ក្រោយការបោះឆ្នោត ឆ្នាំ ១៩៥៩ លោក លីខ្វាន់យូ បានជាប់ឆ្នោតជានាយករដ្ឋមន្ត្រី និងកាន់តំណែងជានាយករដ្ឋមន្ត្រី ដែលប្រើប្រាស់ទស្សនៈផ្ទាល់ខ្លួនក្នុងការរៀបចំប្រទេសសិង្ហបុរីឡើងវិញ ។ លោក លីខ្វាន់យូ បានដឹកនាំប្រទេសសិង្ហបុរីរហូតមកដល់ឆ្នាំ ១៩៩០ មុនពេលប្រគល់អំណាចតាមរយៈការបោះឆ្នោតទៅអោយ លោកហ្គោលឆុកតុង បន្តជានាយករដ្ឋមន្ត្រីទី២ ។ ជាក់ស្តែងមុនពេលបោះឆ្នោតក្នុង ឆ្នាំ ១៩៥៩ ប្រទេសសិង្ហបុរីធ្លាប់ ជាប្រទេសមួយដឹកនាំរដ្ឋដោយខ្លួនឯង ប៉ុន្តែប្រទេសនេះ

[53] ប្រព័ន្ធតុលាការនៃប្រទេសសិង្ហបុរី, ,ក្នុងhttp://en.m.wikipedia.org/wiki/judicial_system_of_Singapore។

ស្ថិតក្រោមការគ្រប់គ្រងដោយចក្រអង់គ្លេស ។ ទស្សនៈរបស់លោកនាយករដ្ឋមន្ត្រីដំបូង លីខ្វាន់យូ ចង់ងើបខ្លួនចេញពីសម្ព័ន្ធភាពម៉ាឡេស៊ី និងចង់ធ្វើឲ្យប្រទេសនេះចេញពីការគ្រប់គ្រងរបស់ចក្រភពអង់គ្លេសទាំងស្រុង ។ ដោយសារទស្សននេះហើយទើបធ្វើឲ្យសាធារណរដ្ឋសិង្ហបុរីបានទទួលនូវឯករាជ្យពេញលេញក្នុងឆ្នាំ ១៩៦៥ ។ អ្នកវិភាគនយោបាយរួមជាមួយអ្នកនយោបាយប្រឆាំងជាច្រើននាក់មកពីគណបក្សនយោបាយ ពីរ ផ្សេងគ្នាដែលជាគណបក្សប្រឆាំងក្នុងប្រទេសសិង្ហបុរី (១)គណបក្សពលករសិង្ហបុរី និង(២)គណបក្សប្រជាធិបតេយ្យសិង្ហបុរីបានយល់ឃើញថាប្រទេសសិង្ហបុរីបានធ្វើពហិការសិទ្ធិដោយបានបំបែកខ្លួនចេញពីគំនាបនៃការគ្រប់គ្រងរដ្ឋពីចក្រភពអង់គ្លេស និងញែកខ្លួនចេញពីសម្ពន្ធ័ភាពម៉ាឡេស៊ី ហើយបង្កើតរដ្ឋមួយដោយឯករាជ្យដោយខ្លួនឯង ។ ហើយក្រោយមកគេបានចាប់ផ្តើមហៅប្រទេស សិង្ហបុរី ថាជាប្រទេសដែលមិនមានលទ្ធិប្រជាធិបតេយ្យតាមរយៈការបោះឆ្នោត ។

### ខ.១ បរិយាកាសនយោបាយក្នុងទីក្រុងសិង្ហបុរី

ទីក្រុងសិង្ហបុរីជាកន្លែងដែលរដ្ឋាភិបាលនៃប្រទេសសិង្ហបុរីគ្រប់គ្រងតាំងរដ្ឋបាលរបស់ខ្លួន ។ រដ្ឋាភិបាលទីក្រុងសិង្ហបុរីតែងតែបង្ហាញឲ្យឃើញថា ក្រោមការដឹកនាំប្រទេសគ្មានរូបភាពនៃអំពើពុករលួយជាដាច់ខាតបើទោះបីជាគេពុំឃើញសកម្មភាពលេចធ្លោនោះក៏ដោយ ។ រដ្ឋាភិបាលប្រទេសសិង្ហបុរី ត្រូវបានរកឃើញថាជាប្រទេសមានអំពើពុករលួយតិចតួចជាងគេក្នុងតំបន់អាស៊ី និង ក្នុងចំណោមប្រទេសដែលស្អាតស្អំ ចំនួន ១០ដែលខ្ពស់ជាងគេក្នុងពិភពលោកដោយយោងតាមរបាយការណ៍អង្គការតម្លាភាពអន្តរជាតិ ។ អភិបាលកិច្ចធនាគារពិភពលោកបង្ហាញថាប្រទេស សិង្ហបុរី ជាប្រទេសអនុវត្តច្បាប់ដោយគ្រប់គ្រងការប្រព្រឹត្តអំពើពុករលួយបានយ៉ាងល្អ និងគ្រប់គ្រងរដ្ឋាភិបាលយ៉ាងមានប្រសិទ្ធិភាព ក៏ប៉ុន្តែរដ្ឋាភិបាលពុំសូវមានការគោរពសិទ្ធិមនុស្សខ្លាំងនោះទេ ។ តែទោះជាយ៉ាងណាក៏ដោយតែ ហាក់បីដូចជាមានការខកចិត្តបន្តិចជុំវិញគំនិតខ្លះៗ នៃដំណើរការនយោបាយសង្គមស៊ីវិលសិទ្ធិនយោបាយ និងសិទ្ធិមនុស្សហាក់ដូចជាពុំមានអំណោយផលគ្រប់គ្រាន់ឡើយ ។

### ខ.២ អំពីសភានៃទីក្រុងសិង្ហបុរី

មុនទទួលបានឯករាជ្យក្នុងឆ្នាំ ១៩៦៥ គេស្គាល់តែសភាបញ្ញត្តិនៃសាធារណរដ្ឋសិង្ហបុរី។ កាលនោះមានសមាជិកតែចំនួន ៨៧ នាក់ប៉ុណ្ណោះដែលជាសមាជិកសភាជាប់ឆ្នោតក្នុងតំណែង។ ក្នុងចំណោមសមាជិកសភាសរុបខាងលើនេះមានស្ត្រីចំនួន ១០ រូបជាសមាជិកាសភាទាំងអស់មានអាណត្តិយ៉ាងច្រើនបំផុតរយៈពេលត្រឹម ៥ ឆ្នាំក្នុងតួនាទីជាសមាជិកសភាបញ្ញត្តិ ។ ហើយរៀងរាល់

អាណត្តិ (៥ឆ្នាំម្តង) ត្រូវមានការបោះឆ្នោតជាថ្មី ។ សមាជិកសភាអាចបង្កើតក្រុមពិភាក្សាច្បាប់បានក្នុងពេលប្រជុំសភាដោយមានគ្នាចន្លោះពី៣ទៅ៩នាក់។

### ខ.៣ ដំណើរការនៃការរៀបចំច្បាប់នៃសាធារណរដ្ឋសិង្ហបុរី

ច្បាប់ដែលអនុម័តឲ្យចូលជាធរមាន និងប្រើប្រាស់បានលុះត្រាតែបានឆ្លងកាត់សភាបញ្ញត្តិនៃសាធារណរដ្ឋសិង្ហបុរីជាមុនសិននោះគេហៅថាជាសេចក្តីព្រាងច្បាប់ ។ តាមធម្មតាសេចក្តីព្រាងច្បាប់ត្រូវបានលើកឡើង ជាសំណើរដោយរដ្ឋមន្ត្រីនៃគណៈរដ្ឋមន្ត្រីក្នុងតំណែង នៃជួររដ្ឋាភិបាល ហើយសំណើនេះគេហៅថាសេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាល ។ ក្នុងន័យនេះពុំមែនមានន័យថាសមាជិកសភាបញ្ញត្តិនៃសាធារណរដ្ឋសិង្ហបុរីទាំងអស់ពុំមានសិទ្ធិស្នើច្បាប់បាននោះទេ ។ ក៏ប៉ុន្តែចំពោះសេចក្តីស្នើច្បាប់របស់សមាជិកសភាបញ្ញត្តិនោះគេហៅថា សេចក្តីស្នើច្បាប់សមាជិកសភាមានលក្ខណៈឯកជន ។មុននឹងសេចក្តីស្នើច្បាប់ត្រូវបានដាក់ឲ្យទៅជាច្បាប់ធរមានត្រូវឆ្លងកាត់ច្រើនដំណាក់កាលក្នុងមន្ទីរសភាបញ្ញត្តិជាមុនសិន ។ ដំណាក់ដំបូងគេហៅថាដំណាក់កាលនៃ ការចាប់ផ្តើមអានដែលពុំមានការពិភាក្សាដេញដោលគ្នាឡើយ ។ បន្ទាប់មកគឺដំណាក់កាលទី២ ដែលមានសមាជិកសភាបញ្ញត្តិទាំងអស់ចាប់ផ្តើមអានជាលើកទីពីរហើយ ពិភាក្សាគ្នាអំពីគោលការណ៍ទូទៅនៃសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់នោះថាតើស្របតាមគោលការណ៍កំណត់ដែរឬទេ ប្រសិនបើក្រោយពីពេលពិភាក្សាអំពីគោលការណ៍ទូទៅរួចហើយ នោះគេមើលឃើញថាផ្ទុយពីគោលការណ៍សមាជិកសភាបញ្ញត្តិ នឹងធ្វើការបោះឆ្នោតលុបចោល ។ ផ្ទុយទៅវិញនៅពេលដែលសភាបញ្ញត្តិយល់ថាស្របតាមគោលការណ៍សេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ នឹងត្រូវបញ្ជូនទៅគណៈកម្មាធិការជ្រើសរើសដើម្បីពិនិត្យ ។ សមាជិកសភាបញ្ញត្តិរូបណាដែលមិនយល់ស្របអាចស្នើធ្វើវិសោធនកម្មបាន ។ ដំណាក់កាលទី៣ជាដំណាក់កាលចុងក្រោយ នៅពេលដែលសភាបញ្ញត្តិអានសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់រួចជាលើកទី៣ ចប់ហើយប៉ុន្តែអាចធ្វើវិសោធនកម្មបានដែលមានលក្ខណៈតិចតួចប៉ុណ្ណោះ មុនពេលត្រូវអនុម័តឲ្យចូលជាធរមាន។

## ២.២ អំពីការរៀបចំក្រុងសិង្ហបុរី

### ២.២.១ ស្ថានភាពសេដ្ឋកិច្ចនៃទីក្រុងសិង្ហបុរី

ការកសាងសង្គមនៃសាធារណរដ្ឋសិង្ហបុរីឡើងវិញជាកិច្ចការងារថ្មីបំផុត និងដំបូងគេបង្អស់ដែលរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី ត្រូវជំរុញរៀបចំផែនការដើម្បីស្តារសេដ្ឋកិច្ចក្នុងប្រទេសឈានឡើងជាលំដាប់តាមរយៈការរៀបចំ ផែនការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់រៀបចំទីក្រុង គឺរដ្ឋាភិបាលនៃសាធារណៈរដ្ឋសិង្ហបុរីប្រើនយោបាយទាក់ទាញវិនិយោគបរទេស ។ សេដ្ឋកិច្ចក្នុងទីក្រុងសិង្ហបុរី

បានរីកចម្រើនយ៉ាងខ្លាំងជាសេដ្ឋកិច្ចទីផ្សារពាណិជ្ជកម្ម ដែលសេដ្ឋកិច្ចនេះនឹងបើកទូលាយសម្រាប់ពិភពលោកទាំងមូលចូលរួមវិនិយោគ[18] ។ ការអភិវឌ្ឍសេដ្ឋកិច្ចរឹងមាំជាការរីកចម្រើនខ្លាំងសម្រាប់សេដ្ឋកិច្ចរបស់ទីក្រុងសិង្ហបុរីមួយទាំងមូល ។ ម្យ៉ាងទៀតសេដ្ឋកិច្ចសាធារណរដ្ឋសិង្ហបុរីជាចរន្តលំហូរចូលតាមរយៈការវិនិយោគផ្ទាល់ពីបរទេស[19]ជាប្រយោជន៍ដល់សង្គម នៃសាធារណរដ្ឋសិង្ហបុរីដែលអំណោយផលដល់បរិយាកាសនយោបាយ និងការទាក់ទាញវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកដែលមានសារសំខាន់យ៉ាងខ្លាំងបានរួមចំណែកក្នុងការអភិវឌ្ឍន៍ទីក្រុងសិង្ហបុរី ។ នៅក្នុងឆ្នាំ ២០១៣សាធារណៈរដ្ឋសិង្ហបុរីបាន ចាប់ផ្ដើមបង្កើតដៃគូសហប្រតិបត្តិការទាំងនាំចេញ និងនាំចូលផលិតផលទំនិញឧស្សាហកម្ម និងទំនិញប្រើប្រាស់ផ្សេងជាច្រើនជាមួយប្រទេសដៃគូក្នុងតំបន់ និងដៃគូអន្តរជាតិនានា ។ ក្នុងនោះរួមមានដូចជាៈប្រទេសម៉ាឡេស៊ីប្រទេសចិន ទីក្រុងហុងកុង ប្រទេសឥណ្ឌូនេស៊ី សហរដ្ឋអាមេរិក ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង និងប្រទេសកាណាដា ។ អត្រានាំចេញគិតជាភាគរយខ្ពស់ជាងគេបំផុតគឺ ប្រទេសម៉ាឡេស៊ី ដែលមានអាត្រាដល់ទៅ ១២.២% ។ ចំណែកប្រទេសដែលទាបជាងគេបំផុតគឺ ប្រទេសកាណាដា ក្នុងនោះមានអាត្រាត្រឹមតែ៣.៧% ប៉ុណ្ណោះហើយប្រទេសចិន ជាប្រទេសមួយដែលនាំផលិតផលទំនិញឧស្សាហកម្មចេញទៅច្រើនជាងគេជាលំដាប់ប្រទេសទី២ បន្ទាប់ពីប្រទេសម៉ាឡេស៊ី ។ សាធារណៈរដ្ឋសិង្ហបុរី ក៏បានធ្វើការទំនាក់ទំនង ជាមួយប្រទេសមួយចំនួនផ្សេងទៀតផងដែរដើម្បីនាំទំនិញប្រើប្រាស់ មានដូចជាប្រទេសចិន ប្រទេសម៉ាឡេស៊ី សហរដ្ឋអាមេរិក ប្រទេសកូរ៉េខាងត្បូង ប្រទេសជប៉ុន ប្រទេសឥណ្ឌូនេស៊ី និងសម្ព័ន្ធអារ៉ាប់រួម។[20]

### ២.២.២ ការកសាងផែនការសម្រាប់រយៈពេលវែង

ទីក្រុងសិង្ហបុរីមានបញ្ហាប្រឈមបច្ចុប្បន្នខុសគ្នាពីបញ្ហាប្រឈមកាលពី ទសវត្សរ៍ឆ្នាំ ១៩៦០។ អត្ថិភាពរបស់ប្រទេសសិង្ហបុរី ក៏នៅតែមានដូចមុនដដែល ដូចជាការស្វែងរកការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ច និងគុណភាពល្អក្នុងជីវភាពរស់នៅ ។ ប្រទេសសិង្ហបុរីតាមផែនការក៏នៅតែចង់បានការរក្សាបរិស្ថានពណ៌បៃតងឲ្យនៅស្រស់ស្អាត និង ចង់ឲ្យមានធនធានធម្មជាតិប្រើប្រាស់សំបូរបែបជារៀងរហូត ។ ហើយអ្វីដែលជាគោលបំណងនាំឲ្យប្រទេសសិង្ហបុរីខិតខំប្រឹងប្រែងរៀបចំគំរោងផែនការអភិវឌ្ឍន៍សម្រាប់អនាគតនោះគឺត្រូវធ្វើឡើងតាមរយៈផែនការរួមចំនួន៤សំខាន់ៗៈ

---

[18] សេដ្ឋកិច្ចប្រទេសសិង្ហបុរី, ,ក្នុង https://en.m.wikipedia.org/wikipedia.org/wiki/Economy_of_Singapore

[19]សេដ្ឋកិច្ចប្រទេសសិង្ហបុរី, ,ក្នុង https://en.m.wikipedia.org/wikipedia.org/wiki/Economy_of_Singapore

[20] សេដ្ឋកិច្ចប្រទេសសិង្ហបុរី, ,ក្នុង https://en.m.wikipedia.org/wikipedia.org/wiki/Economy_of_Singapore

1) ផែនការសេដ្ឋកិច្ចៈ ជំរុញឲ្យសេដ្ឋកិច្ចឈានឡើងជាលំដាប់ ។
2) ផែនការសង្គមៈ រៀបចំផ្តល់នូវគុណភាពនៃការរស់នៅនិងមានការយល់ឃើញអំពីសុខុមាលភាពសម្រាប់ទាំងអស់គ្នា។
3) ផែនការបរិស្ថានៈ ក្នុងការចូលរួមអភិវឌ្ឍរាល់ឥរិយាបទទទួលខុសត្រូវខាងបរិស្ថានជុំវិញខ្លួនយើងដល់ប្រជាជននៅក្នុងប្រទេស ។
4) ផែនការថែរក្សាដែនដីនិងដែនសមុទ្រៈ មានគំនិតវិជ្ជមានជានិច្ចចំពោះដែនដីគោក និងដែនសមុទ្រនៃប្រទេសសិង្ហបុរី។

ការពិគ្រោះយោបល់ និងការធ្វើប្រជាមតិជាសាធារណៈជាផ្នែកមួយនៃគំរោងប្រើប្រាស់ដីធ្លីសម្រាប់ការអភិវឌ្ឍក្រុងសិង្ហបុរីទាំងមូល ។ ការរៀបចំក្រុងអនុលោមតាមការយល់ដឹងអំពីចក្ខុវិស័យច្បាស់លាស់ក្នុងការពិគ្រោះយោបល់ជាមួយវិស័យសាធារណៈ និងឯកជនក៏ដូចជាសហគមន៍ផងដែរ។

### ២.២.៣ ផែនការរបស់ទីក្រុងសិង្ហបុរី

ក្នុងនាមជាទីក្រុងរដ្ឋមួយក្នុងចំណោមទីក្រុងនានាជាច្រើននៅលើពិភពលោក ទីក្រុងសិង្ហបុរីមានលក្ខខណ្ឌតែមួយគត់ លក្ខណៈនោះមិនខុសពីទីក្រុងផ្សេងទៀតនោះទេ ទីក្រុងសិង្ហបុរីរៀបចំឲ្យមានគំរោងនៃការសង់ផ្ទះសម្បែង និងរៀបចំជំនួញត្រឹមត្រូវ និងជាតម្រូវការសង្គមផង ។ ដើម្បីធ្វើឲ្យមានការសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព របស់ទីក្រុងសិង្ហបុរីត្រូវរក្សាបាននូវលទ្ធផលដែលបានកសាងសម្រាប់មនុស្សជំនាន់ក្រោយៗទៀត ។ ជាការពិតណាស់ការកសាងទីក្រុងសិង្ហបុរីត្រូវជួបការលំបាកច្រើន ក្នុងការសម្រេចលទ្ធផលលើកិច្ចការគំរោងសម្រាប់ផលប្រយោជន៍រយៈពេលវែង ។ ក្នុងការរៀបចំទីក្រុងសិង្ហបុរីប្រកបដោយភាពជោគជ័យត្រូវមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រងដីធ្លីនិងរៀបចំហេដ្ឋារចនាសម្ព័ន្ធ។

#### ក. ផែនការរៀបចំផ្ទះសម្បែង និងការគ្រប់គ្រងដីធ្លីក្រុង

ដើម្បីកំណត់ការគ្រប់គ្រងដីធ្លីក្នុងទីក្រុងឲ្យបានល្អ ការរៀបចំផែនការថ្មីមួយជាបញ្ហាសំខាន់យុទ្ធសាស្ត្ររៀបចំផែនការ និងការរៀបចំដីធ្លីផ្តល់មកវិញនូវការប្រើប្រាស់ត្រឹមត្រូវ ។ ប្រសិនបើការរៀបចំទីក្រុងបានល្អការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដូចជាការដឹកជញ្ជូនក្នុងក្រុង នឹង កាន់តែល្អប្រសើរឡើង ។ ការកសាងផ្ទះសម្បែងដែលមានច្រើនជាន់អាចជាកត្តាអំណោយផលដល់ការកសាងប្រព័ន្ធគមនាគមន៍ក្នុងទីក្រុងនិងបញ្ចៀសការកកស្ទះចរាចរណ៍ថែមទៀតផង ។

ទោះបី ជាស្ថានភាពក្នុងទីក្រុងសិង្ហបុរីអាចទំនងជាមានភាពចង្អៀតបន្តិចនៅក្នុងទីក្រុងសិង្ហបុរីក៏ពិតមែនប៉ុន្តែ បរិស្ថានមានភាពស្រស់បំព្រងនៅក្នុងទីក្រុងក៏ នឹងត្រូវរៀបចំផែនការដើម្បីថែរក្សាឲ្យបានល្អផងដែរ ។ គំរោងកសាងកន្លែងចតរថយន្តក្នុងទីក្រុងសិង្ហបុរីជាបញ្ហាចោទដ៏សំខាន់គឺ ដើម្បីរក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គម ។ ការរៀបចំទីក្រុងសិង្ហបុរីឲ្យមានរបៀបរៀបរយមានសោភ័ណភាព និងទុកកន្លែងខ្លះសម្រាប់កំសាន្តអារម្មណ៍ក្នុងទីសាធារណៈ ជាការរួមចំនែកសំខាន់ក្នុងការកសាងក្រុងឲ្យរីកចម្រើន។

### ខ.គុណភាពរស់នៅប្រកបដោយផាសុខភាព

ការររៀបចំក្រុងសិង្ហបុរី មិនគ្រាន់តែរៀបចំឲ្យមានផ្ទះសម្បែងសម្រាប់រស់នៅប្រកបដោយផាសុខភាពប៉ុណ្ណោះទេ ការរៀចចំក្រុងសិង្ហបុរីថែមទាំងបានផ្តល់ឲ្យនូវ ការថែរក្សាអំណោយផលបរិស្ថានល្អដែលនាំឲ្យមានសុខភាពល្អផងដែរ ។ ការក៏កសាងតំបន់ផ្ទះសម្បែងក្នុងទីក្រុងសិង្ហបុរីទាំងមូលជាការទទួលខុសត្រូវរបស់ រដ្ឋាភិបាលក្នុងការផ្តល់ជូនប្រជាពលរដ្ឋសេវាសាធារណៈដូចជាសាលារៀន មន្ទីរពេទ្យ កន្លែងពិនិត្យ សុខភាពសាធារណៈចំណតរថយន្តសាធារណៈកន្លែងគោរពតាមបែបសាសនា និងកន្លែងសាធារណៈ ។ ទីក្រុងសិង្ហបុរីក៏បានរៀបចំផ្លូវសាធារណៈ និងបណ្តាញផ្លូវតូចធំជាច្រើនដែលអាចបង្កភាពងាយស្រួលដល់អ្នករស់នៅក្នុងទីក្រុងនិងការធ្វើដំណើរផងដែរ ។

### ២.២.៤ គោលនយោបាយរៀបចំក្រុងសិង្ហបុរី

ក្រោយទទួលបានឯករាជ្យ សាធារណរដ្ឋសិង្ហបុរីមានសកម្មភាពយ៉ាងច្រើនជាបន្តបន្ទាប់ក្នុងការបង្កើតគោលនយោបាយរៀបចំក្រុងសិង្ហបុរី ។ ក្រុងសិង្ហបុរីគេអាចស្គាល់ម្យ៉ាងទៀតថាជាទីក្រុងនៃសត្វតោ ។ រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី ដែលសកម្មក្នុងការអភិវឌ្ឍន៍ទីក្រុងបានដោយជោគជ័យ ។ ពេលវេលានៃការរៀបចំក្រុងនេះបើគ្រាន់តែគិតជាបរិមាណថ្វីត្បិតតែមើលទៅឃើញចំនួនច្រើន ប៉ុន្តែជារយៈពេលដ៏ខ្លីមួយទៅវិញទេ បើគេប្រើប្រាស់ពេលវេលានេះដើម្បីរៀបចំទីក្រុងមួយទទួលបានជោគជ័យស្ទើរតែគ្រប់វិស័យ ។ តាមរយៈសកម្មភាពនានារបស់រដ្ឋាភិបាលសាធារណៈរដ្ឋសិង្ហបុរីមានគោលនយោបាយច្បាស់លាស់ក្នុងការអភិវឌ្ឍទីក្រុងស្អាត ទីក្រុងមានគុណភាពប្រកបដោយចីវភាពនិងទីក្រុងមានភាពជឿនលឿន ជាតម្រូវការរស់នៅសម្រាប់ប្រជាជនរបស់របស់ខ្លួនផង និងទាក់ទាញមនុស្សលើពិភពលោកផង ។ តែរយៈពេលជាង៥០ឆ្នាំប៉ុណ្ណោះរដ្ឋាភិបាលសិង្ហបុរីមានការរីកចម្រើនខ្លាំងទាំង សេដ្ឋកិច្ច និងបរិស្ថានស្រស់បំព្រង ។ ការរៀបចំទីក្រុងសិង្ហបុរីមានការរីកចម្រើនជឿនលឿនឆាប់រហ័សជាងទីក្រុងនានាលើពិភពលោកដែលមានចំណាត់

ថ្នាក់ជាទីក្រុងលំដាប់ពិភពលោក ។ ទីក្រុងសិង្ហបុរីមានស្ថិរភាពនយោបាយចំណែកសេដ្ឋកិច្ចរីកចម្រើនច្រើនគួរកត់សម្គាល់ផងដែរ ។ បើប្រៀបធៀបទៅ នឹងការរៀបចំទីក្រុងមួយចំនួនដែលស្ថិតនៅក្នុងពិភពលោក ឧទាហរណ៍៖ ដូចជាទីក្រុងឡុងដុងនៃចក្រភព អង់គ្លេសគេប្រើប្រាស់ពេលវេលាយូរជាងការរៀបចំទីក្រុងសិង្ហបុរី ។ គេប្រើពេលវេលាច្រើនរហូតដល់ជាង១សតវត្សទើបប្រែក្លាយទីក្រុងលំដាប់ពិភពលោកបាន[21] ។ ក្នុងការរៀបចំទីក្រុងសិង្ហបុរីឲ្យមានការរីកចម្រើនច្រើនដើម្បីជាផលប្រយោជន៍ទូទៅសម្រាប់ប្រជាជនសិង្ហបុរីជាពិសេស ចំពោះប្រជាជនរស់នៅទីក្រុងនោះផ្ទាល់ រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរីបានរៀបចំផែនការយុទ្ធសាស្ត្រដោយ រំពឹងធានាឲ្យបាននូវជីវភាពរស់នៅ និងបង្កភាពងាយស្រួលក្នុងការប្រើប្រាស់មធ្យាបាយ ក្នុងការធ្វើដំណើរប្រកបដោយគុណភាពល្អ ។ រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី ក៏មានផែនការសម្រេចឲ្យបាននូវការថែរក្សាបរិស្ថានស្អាតនិងការរស់នៅប្រកបដោយភាពវិជ្ជមានក្នុងការថែទាំសុខភាពសាធារណៈផងដែរ ។ បរិស្ថានស្រស់បំព្រងនាំឲ្យប្រជាជនរស់នៅមានផាសុខភាពល្អ ។ ផែនការរៀបចំទីក្រុងសិង្ហបុរីដែលលើកគម្រោងដោយរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនទៅដល់ អ្នករស់នៅក្នុងទីក្រុងយ៉ាងពិតប្រាកដ ។ ការរៀបចំទីក្រុងមិនត្រឹមតែផ្តល់ឲ្យនូវជំរករស់នៅល្អប្រសើរប៉ុណ្ណោះទេថែមទាំងផ្តល់នូវការរៀបចំបរិស្ថានស្រស់បំព្រងពេញលេញជុំវិញកន្លែងដែល យើងរស់នៅថែមទៀតផង។

## ២.៣ អភិបាលកិច្ចល្អនៃក្រុងសិង្ហបុរី

### ២.៣.១ គោលការណ៍អភិបាលកិច្ចល្អនៃទីក្រុងសិង្ហបុរី

ភាពជាអ្នកដឹកនាំល្អហើយមានលក្ខណៈរឹងមាំក្នុងការកសាង ក្រុងសិង្ហបុរី ឆ្ពោះទៅរកវឌ្ឍនៈភាពសង្គមយ៉ាងពិតប្រាកដជាការឆ្លុះបញ្ចាំងពីការស្វែងរក និងអនុវត្តតាមគោលការណ៍នៃអភិបាលកិច្ចល្អ ។ រដ្ឋបាលរៀបចំក្រុងសិង្ហបុរីជាពិសេសរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីបាន ជំរុញឲ្យមានការអនុវត្តគោលការណ៍ស្តីអំពីអភិបាលកិច្ចល្អ និងភាពជាអ្នកដឹកនាំដើម្បីណែនាំឲ្យមានការគ្រប់គ្រងស្របតាមការសម្រេចចិត្ត និងការបង្កើតនូវគោលនយោបាយសម្រាប់រដ្ឋបាល នៃទីក្រុងសិង្ហបុរី ។[22] រដ្ឋាភិបាលសាធារណសិង្ហបុរីបានដាក់ចេញនូវគោលនយោបាយចំនួន៥ក្នុងការរៀបចំ

[21] ប្រទេសសិង្ហបុរី៖ ការអភិវឌ្ឍយ៉ាងលឿនដោយសកម្មភាពខ្លាំង, អាចចូលមើលបន្ថែមបានក្នុង https://www.oecd.org/countres/sigapore/46581101.pdf។

[22] Zakaria Adbuj Wahab (ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩) ប្រទេសសិង្ហបុរីអនុវត្តអភិបាលកិច្ចល្អ ត្រូវមានភាពជាអ្នកដឹកនាំរឹងមាំ ចូលអានក្នុង https://sgforums.com/forums/10/topics/384164។

ទីក្រុងសិង្ហបុរី ។ គោលនយោបាយទាំងនោះរួមមាន៖

1. រៀបចំអោយមានអភិបាលកិច្ចល្អ
2. សេចក្តីសុចរិត និង គុណធម៌
3. គិតដល់ការផ្លាស់ប្តូរ និង ចូលរួមពាក់ព័ន្ធទាំងអស់គ្នា
4. ធ្វើអ្វីដែលត្រឹមត្រូវ មិនមែនធ្វើអ្វីដើម្បីប្រជាប្រិយទេ
5. ភាពជាអ្នកដឹកនាំជាគន្លឹះសំខាន់សម្រាប់ប្រជាជនទាំងអស់។

អភិបាលកិច្ចល្អ និងភាពជាអ្នកដឹកនាំប្រកបដោយការទទួលខុសត្រូវខ្ពស់ជាករណីកិច្ចចាំបាច់ក្នុងការចូលរួមអភិវឌ្ឍទីក្រុង និង ប្រព័ន្ធគ្រប់គ្រង។ ឧទាហរណ៍៖ការគ្រប់គ្រងប្រព័ន្ធទឹកស្អាត និង ថែរក្សាបរិស្ថានស្អាតក្នុងទីក្រុងសម្រាប់ការថែទាំសុខភាពសាធារណៈ ។ ការកសាង ក្រុងសិង្ហបុរីដោយផ្អែកលើគោលការណ៍អភិបាលកិច្ចល្អ ជាកត្តានាំឲ្យប្រមូលបានមកវិញនូវអត្ថប្រយោជន៍ និងផ្តល់ផលប្រយោជន៍ជាទូទៅសម្រាប់បំរើជាសាធារណៈក្នុងទីក្រុងសិង្ហបុរីទាំងមូល ។ ជាការពិតណាស់អភិបាលកិច្ចល្អគួរត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាប្រឈមជាច្រើនក្នុងការដោះស្រាយបញ្ហាសង្គម ។ ឧទាហរណ៍ដូចជា៖ រដ្ឋាភិបាលទទួលបានភាពជោគជ័យខ្លាំង ដោយសាររដ្ឋាភិបាលធានារៀបចំទីក្រុងសិង្ហបុរីឲ្យអភិវឌ្ឍ លើគ្រប់វិស័យដោយផ្អែកលើគោលការណ៍នានានៃអភិបាលកិច្ចល្អ ។[59] តាមរយៈការគ្រប់គ្រងរដ្ឋបាលដោយអនុវត្តគោលការណ៍អភិបាលកិច្ចល្អបានទាំងស្រុងបានធ្វើឲ្យបញ្ហាសង្គមត្រូវបានដោះស្រាយ ។ ៥០ឆ្នាំកន្លងផុតទៅ ទីក្រុងសិង្ហបុរីគឺជាទីក្រុងមួយថ្មីដែលមានភាពរីកចម្រើនខ្លាំងខាងសេដ្ឋកិច្ចល្អក្នុង ការគ្រប់គ្រងរដ្ឋបន្ទាប់ពីទទួលបានឯករាជ្យកាលឆ្នាំ១៩៦៥ ។

### ២.៣.២ បញ្ហាប្រឈមប្រឈមក្នុងរៀបចំទីក្រុងសិង្ហបុរី

កំណើនប្រជាជន និងការចូលមករស់នៅក្នុងតំបន់ដែលមានមនុស្សរស់នៅច្រើនកុះករ ក៏ជាកត្តាមួយដែលនាំឲ្យការអភិវឌ្ឍក្រុងកើតឡើង ។ សេដ្ឋកិច្ចទីក្រុងរីកចម្រើនរហ័ស ប្រជាជនរស់ នៅក្នុងក្រុងក៏នឹងទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍនេះដែរ ។ ការសិក្សាអំពីការ អភិវឌ្ឍក្រុង ត្រូវរៀបចំក្រុង ក៏នៅតែមានផលប៉ះពាល់ដល់សង្គម ។ ប៉ុន្តែឥទ្ធិពលនៃការរៀបចំក្រុងក៏នៅតែមានផលប៉ះពាល់ ទោះបីជាមានការសិក្សាអំពីគំរោងកសាងទីក្រុងក៏ដោយ។

[59] ក្នុង http://www.channelnewsasia.com/new/sigapore/ideal-fo-good-governance/2336390.html។

### ២.៣.៣ សកម្មភាពប៉ះពាល់ដែលត្រូវដោះស្រាយក្នុងទីក្រុងសិង្ហបុរី

ចូសេតហ្វ ឡេតម៉ាន រកឃើញកត្តាប្រឈមជាច្រើនបានកើតឡើងនៅក្រុងទីក្រុងសិង្ហបុរីអាជ្ញាធរគ្រប់គ្រងក្រុង បានក្រើនរំឮកជាសាធារណៈអំពីផលប៉ះពាលដល់សោភ័ណភាពទីក្រុងក្នុងអំឡុងពេលនៃការរៀបចំទីក្រុងសិង្ហបុរី ។ ការគ្រប់គ្រងសំណង់អាគារដីធ្លីផ្ទះសម្បែងជាបញ្ហានៃការរៀបចំក្រុង ។ ការរៀបចំប្រព័ន្ធគ្រប់គ្រង ទឹកស្អាតមានសារៈសំខាន់ខ្លាំងណាស់សម្រាប់អ្នករស់នៅតាមទីក្រុងសិង្ហបុរី ព្រោះបើកាលណាប្រើប្រាស់ទឹកដោយពុំមានប្រព័ន្ធលូបង្ហូរចេញដោយត្រឹមត្រូវទេនោះបញ្ហាទឹកស្អុយ និងកាកសំណល់ផ្ទះបាយមុខជាបញ្ហាប្រឈមដល់បរិស្ថាន និងសុខភាពមនុស្សរស់នៅក្នុងទីក្រុងទាំងមូលជាមិនខាន ។បើកាលណាការរៀបចំក្រុងដែលមានការគ្រប់គ្រងកាកសំណល់មិនបានល្អទេនោះ ទីក្រុងសិង្ហបុរី និងជួបបញ្ហាប្រឈមច្រើន ។ ឧទាហរណ៍ៈ នៅតំបន់ខ្លះក្នុងទីក្រុងសិង្ហបុរី ដែលគេកំណត់ថាជាតំបន់ដែលមានកំណើនសេដ្ឋកិច្ចកើនឡើងយ៉ាងលឿន និងមានសកម្មភាពឧស្សាហកម្មច្រើនបាននាំឲ្យប្រទេសសិង្ហបុរីទាំងមូលជា ពិសេសទីក្រុងសិង្ហបុរីអនុវត្តវិធីសាស្ត្រទីក្រុងសិង្ហបុរីធ្លាប់បានប្រើប្រាស់មធ្យោបាយ ជាច្រើនក្នុងការដោះស្រាយបញ្ហាប្រឈមនានាក្នុងបរិស្ថាន ។ រដ្ឋាភិបាលនៃទីក្រុងសិង្ហបុរី បានរៀបចំការគ្រប់គ្រងបរិស្ថាន និងគំរោងរៀបចំបរិស្ថានតាមរយៈការអនុវត្តការងារក្រោមពាក្យស្លោកថា អនុវត្តការងារល្អក្នុងវិស័យប្រើប្រាស់ដីធ្លីមធ្យោបាយធ្វើដំណើរក្នុងទីក្រុងការគ្រប់គ្រងប្រភពទឹក ការគ្រប់គ្រងកាកសំណល់សុខភាពបរិស្ថានការគ្រប់គ្រងការបំពុល បរិស្ថានការអភិរក្សធនធានធម្មជាតិការគ្រប់គ្រងសម្លេងកងរំពងរំខានជាដើម ។ កត្តាមួយចំនួននាំឲ្យប៉ះពាល់ដល់ទីក្រុងសិង្ហបុរីរួមមានដូចខាងក្រោមនេះ ។ សូមបែងចែកចេញជាផ្នែកនីមួយៗដូចតទៅៈ

#### ក. ការប្រើប្រាស់និងរៀបចំដីធ្លីក្នុងទីក្រុងសិង្ហបុរី

បញ្ហាគ្រប់គ្រងការប្រើប្រាស់ដីធ្លីក្នុងទីក្រុងសិង្ហបុរី គឺជាកត្តាចំបងក្នុងការគ្រប់គ្រងបរិស្ថានស្រស់បំព្រងក្នុងទីក្រុង ស្របតាមគោលនយោបាយរៀបចំទីក្រុងរបស់រដ្ឋាភិបាលសិង្ហបុរី ក្នុងការរៀបចំគំរោងរៀបចំតំបន់ណាដែលមានទឹកហូរក្នុងទីក្រុងសិង្ហបុរី ។ ក្នុងនោះឃើញថាអាជ្ញាធរទីក្រុងសិង្ហបុរីត្រូវមានវិធានការប្រមូលកាកសំណល់ក្នុងទីក្រុងដើម្បីរៀបចំសោភ័ណភាពទីក្រុងឲ្យ ស្អាតមិនប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននិងប្រមូលកាកសំណល់យកទៅគំទេចចោល។ក្រសួង បរិស្ថានសិង្ហបុរីបានចូលរួមក្នុងគំរោងសំអាត និងរៀបចំទីក្រុងសិង្ហបុរីផងដែរ ។ បរិស្ថានជាបញ្ហាសំខាន់ដែលត្រូវដោះស្រាយដែលមានការចូលរួមរៀបចំពីក្រុមអ្នកអភិវឌ្ឍដីធ្លីខាងវិស័យសាធារណៈដែលបានពិភាក្សាអំពីផលប៉ះពាល់ដល់បរិស្ថាននៅក្នុងទីក្រុងសិង្ហបុរី។

## ខ. ការប្រើប្រាស់មធ្យោបាយធ្វើដំណើរក្នុងទីក្រុងសិង្ហបុរី

គោលបំណងនៃគំរោងមធ្យោបាយធ្វើដំណើរក្នុងទីក្រុងសិង្ហបុរី ត្រូវរៀបចំឲ្យក្លាយជាប្រព័ន្ធមួយដែលអាចជឿទុកចិត្តបានជាពិសេស សម្រាប់ដឹកជញ្ជូនមនុស្ស និងទំនិញផ្សេងនៅក្នុងទីក្រុងសិង្ហបុរី ។ ការរៀបចំប្រព័ន្ធដឹកជញ្ជូនមនុស្ស និងទំនិញផ្សេងៗនៅក្នុងទីក្រុងសិង្ហបុរី ។ ការរៀបចំប្រព័ន្ធដឹកជញ្ជូននេះត្រូវធ្វើឲ្យបានតាមរយៈយុទ្ធសាស្ត្រខាងក្រោម៖

- ដាក់បញ្ចូលគំរោង និងសហប្រតិបត្តិការ ការប្រើប្រាស់ដីធ្លី និងការធ្វើប្រាស្រ័យមធ្យោបាយធ្វើដំណើរ ។
- ពង្រីកលទ្ធភាពផ្លូវនានាក្នុងទីក្រុងសិង្ហបុរី ។
- កែលំអប្រព័ន្ធមធ្យោបាយធ្វើដំណើរសាធារណៈ ។
- ការគ្រប់គ្រងតំរូវការធ្វើដំណើរឲ្យមានប្រសិទ្ធភាពល្អ ។
- កែលំអការគ្រប់គ្រងចរាចរណ៍

យុទ្ធសាស្ត្រទាំងអស់ខាងលើនេះ អាចជាចំណែកក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍ នៅក្នុងទីក្រុងសិង្ហបុរី ដែលជះឥទ្ធិពលមិនល្អដល់ការធ្វើដំណើរលើវិថីសាធារណៈ និងប៉ះពាល់ទៅដល់បរិស្ថាន និងដល់សុខភាពមនុស្សផងដែរ ។ ក្នុងឆ្នាំ ១៩៦៧ ប្រទេសសិង្ហបុរីបានរៀបចំនូវផែនការយុទ្ធសាស្ត្រមួយគេឲ្យឈ្មោះថាផែនការមូល Ring Plan ផែនការនេះមានគោលបំណងក្នុងការកាត់បន្ថយ និងរៀបចំតំបន់ផ្ទះសម្បែងដែលផ្តុំគ្នាច្រើនអាគារឧស្សាហាកម្ម និងតំបន់ទាំងនោះស្ថិតនៅជាបញ្ហាសម្រាប់ការប្រើប្រាស់ផ្លូវថ្នល់ជាមធ្យោបាយសាធារណៈក្នុងក្រុង ។ តាមរយៈគំរោងនេះដែរ ក៏បានជំរុញឲ្យមានការកសាងថ្មីនូវតំបន់ប្រជុំជនបណ្តាញផ្លូវលំនិងផ្លូវជាតិ ។

## គ. ការគ្រប់គ្រងប្រភពទឹកក្នុងទីក្រុងសិង្ហបុរី

ដោយសារតែទីក្រុងសិង្ហបុរី គឺជាទីក្រុងកោះដូច្នេះការគ្រប់គ្រងទឹកស្អាតពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសសិង្ហបុរីទាំងមូល ។ ទីក្រុងសិង្ហបុរី គឺជាទីក្រុងសម្រាប់ផ្គត់ផ្គង់ទឹកស្អាត ចាប់ពីការគ្រប់គ្រងធនធានទឹកស្អាត រហូតដល់ការគ្រប់គ្រងទឹកកខ្វក់ និងការគ្រប់គ្រងការបំពុលទឹក ។ ទីក្រុងសិង្ហបុរីក៏មានការរៀបចំប្រព័ន្ធគ្រប់គ្រងទឹកជំនន់ទៀតផង ពីព្រោះទីក្រុងសិង្ហបុរីមានសារៈសំខាន់ទាំងស្រុងសម្រាប់ប្រទេសសិង្ហបុរីទាំងមូល។

### ឃ. ការគ្រប់គ្រងកាកសំណល់ក្នុងទីក្រុងសិង្ហបុរី

ទីក្រុងសិង្ហបុរីជាទីក្រុងដែលមានដំណើរការប្រតិបត្តិពាណិជ្ជកម្មខ្លាំង ចំណែកសេដ្ឋកិច្ចក៏រីកចម្រើនខ្ពស់គួរឲ្យកត់សម្គាល់ជាខ្លាំងផងដែរ ។ ដោយសារទីក្រុងសិង្ហបុរីមានសេដ្ឋកិច្ចរីកចម្រើនយ៉ាង លឿនបែបនេះ បានធ្វើឲ្យទីក្រុងនេះជួបបញ្ហាការគ្រប់គ្រងកាកសំណល់រឹង និងកាកសំណល់មានជាតិពុល ដើម្បីដោះស្រាយបញ្ហាផលប៉ះពាល់កើតឡើងដោយសារកាកសំណល់នេះ ទីក្រុងសិង្ហបុរី ទាមទារឲ្យមានការរៀបចំប្រព័ន្ធគ្រប់គ្រងកាកសំណល់ដែលមានបច្ចេកទេសខ្ពស់ ។

### ង. សុខភាពបរិស្ថានក្នុងទីក្រុងសិង្ហបុរី

អស់រយៈពេលជាង១០០ឆ្នាំ ទីក្រុងសិង្ហបុរីមានប្រវត្តិសាស្ត្រមួយដោយផ្តោតជាសំខាន់លើការលំអសុខភាពបរិស្ថានក្នុងទីក្រុងកោះសិង្ហបុរី ។ ក្រៅពីការគ្រប់គ្រងកាកសំណល់ដែលមានពាសពេញទីក្រុងសិង្ហបុរី មានវិធីសាស្ត្រជាច្រើនដែលបង្កើតឡើងដើម្បីដោះស្រាយសុខភាពបរិស្ថាននៅក្នុងទីក្រុង ។ វិធីសាស្ត្រងាយៗរួមមាន៖ (១) អនាម័យចំណីអាហារ (២) ការគ្រប់គ្រងសត្វល្អិតចង្រៃដែលអាចបណ្តាលឲ្យកើតជម្ងឺឆ្លង (៣) ការគ្រប់គ្រងជម្ងឺឆ្លង ។ យោងតាមរបាយការណ៍សុខភាពពិភពលោក ទីក្រុងសិង្ហបុរីជាតំបន់កោះដែលគ្មានជម្ងឺគ្រុនចាញ់ទេ នេះតាមការអះអាងរបស់អង្គការសុខភាពពិភពលោក។

### ច. ការគ្រប់គ្រងសម្លេងកងរំពងរំខានក្នុងទីក្រុងសិង្ហបុរី

ទីក្រុងសិង្ហបុរី មិនអាចជៀសផុតពីបញ្ហានៃការរំខានដោយសម្លេងកងរំពងទាំងពេលថ្ងៃទាំងពេលយប់បានទេ ។ ភាគច្រើនសម្លេងរំខាននេះកើតចេញពីរោងចក្រឧស្សាហកម្ម និងសម្លេងរំខានមកពីខាងក្រៅដូចជា សម្លេងម៉ាស៊ីនយានយន្តគ្រប់ប្រភេទដែលត្រូវប្រតិបត្តិលើវិថីសាធារណៈក្នុងទីក្រុងសិង្ហបុរី ។ រដ្ឋាភិបាលទីក្រុងសិង្ហបុរីមានវិធានការដោះស្រាយ ចំពោះបញ្ហាសម្លេងរំខានក្នុងទីក្រុងសិង្ហបុរី ។ អង្គភាពគ្រប់គ្រងបរិស្ថានក្នុងទីក្រុងត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤ ។ អង្គភាពនេះត្រូវបានជ្រោមជ្រែងចរិការដោយគណៈកម្មការប្រឹក្សាយោបល់លើ បញ្ហាសម្លេងរំខាននៅក្នុងបរិស្ថានដែលមានការចូលរួមដោយក្រសួងឧស្សាហកម្ម អ្នកជំនាញអ្នកសិក្សា និងអ្នកតំណាងរបស់រដ្ឋាភិបាលសិង្ហបុរី ។ ក្នុងបេសកកម្មនេះក្រុមអង្គភាពគ្រប់គ្រងសម្លេងរំខានក្នុងបរិស្ថាន បានដាក់ចេញនូវកម្មវិធីសម្លេងរំខានក្នុងបរិស្ថាន ដោយមានការត្រួតពិនិត្យគ្រប់គ្រងចរាចរណ៍ផ្លូវគោកក្នុងទីក្រុង ។ អង្គភាពនេះក៏បានពិនិត្យសម្លេងតាមរថភ្លើងសម្លេងម៉ាស៊ីនក្នុងរោងចក្រ សហគ្រាសតូចធំនិងសម្លេងទាំងក្នុង និងក្រៅកន្លែងកំសាន្តនានាផងដែរ ។ អង្គភាពបានសិក្សាអំពីផលប៉ះពាល់

និងរកមធ្យោបាយកាត់បន្ថយសម្លេងរំខានទាំងនោះក្នុងទីក្រុងសិង្ហបុរី ។ អង្គភាពបានជំរុញ នឹងពន្យល់តាមបច្ចេកទេសអំពីការអនុវត្តការគ្រប់គ្រងឲ្យបានល្អប្រសើរ សម្រាប់ការកាត់បន្ថយសម្លេងនៅតាមការដ្ឋានសាងសង់នានាក្នុងទីក្រុង ។ បន្ថែមលើនេះទៀតអង្គភាពក៏បានរៀបចំគំរោងណែនាំសម្រាប់ការគ្រប់គ្រងសម្លេងរំខាន ។ គេបានតំឡើងលើឧបករណ៍ជាប្រព័ន្ធត្រួតពិនិត្យសម្លេងដោយបានអនុវត្ត ២ដងរៀងរាល់ឆ្នាំហើយមានវិធានការត្រួតពិនិត្យ រយៈពេលមួយសប្តាហ៍នៅតាមតំបន់ជាង២១កន្លែងនៅជុំវិញទីក្រុងសិង្ហបុរី។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការបកស្រាយប្រធានបទស្តីពីការរៀបចំទីក្រុងសិង្ហបុរី និងរាជធានីភ្នំពេញរួចមក យើងបានដឹងថាមាន កត្តាដែលជំរុញដែរនាំឲ្យមានការរៀបចំក្រុងមានកត្តាចំបងៗ៥ធំ និងតម្រូវការដើម្បីរៀបចំទីក្រុងឲ្យបានល្អគឺ ផែនការរៀបចំទីក្រុងដែលហៅថាជាប្លង់គោល ។ ហើយកត្តាចំបងៗ ៣នោះមានដូចជា **កំណើនប្រជាពលរដ្ឋ** យើងដឹងហើយថាការណាប្រជាពលរដ្ឋមានការកើនឡើង តម្រូវការក៏មានការកើនឡើងផងដែរ ដែលតម្រូវឲ្យមានការរៀបចំទីតាំងមួយចំនួនដូចជាទីផ្សារ លំនៅស្ថានជាដើម ។ ចំណែក **កំណើនសេដ្ឋកិច្ច** វិញក៏ជាប់ទាក់ទងផងដែរទៅ នឹងការអភិវឌ្ឍន៍រាជធានី ខេត្តក្រុងក្នុងនោះគឺគេត្រូវរៀបចំឲ្យមានអាគារពាណិជ្ជកម្មផ្សេងៗ រៀបចំទីតាំងរោងចក្រ ឧស្សាហកម្ម សិប្បកម្ម ទីតាំងធនាគារ ផ្លូវគមនាគមន៍ជាដើម ។ **ការកើនឡើងនៃលំនៅស្ថាន និងប្រើប្រាស់ដី** ក៏ជាកត្តាមួយដែរនាំឲ្យមានការរៀបចំក្រុងនោះគឺដោយសារតែការរីកដុះដាលគ្រប់ទិសទីកន្លែងនៅក្នុងក្រុងបញ្ហាក៏អាចបង្កឡើងដោយសារតែ លំនៅស្ថានមានការកើតឡើងយ៉ាងគំហុក ដែលលំនៅស្ថានខ្លះពុំមានរបៀបរៀបរយ និងអនាធិបតេយ្យ ដែរដាច់ខាតតម្រូវឲ្យមានការរៀបចំឡើងវិញ ។ **ការអភិរក្សបេតិកភ័ណ្ឌជាតិ និងបរិស្ថាន** ក៏ជាផ្នែកមួយដែលនាំឲ្យមានការរៀបចំក្រុងទាំងពីរនេះផងដែរ ជាពិសេសគឺបរិស្ថានតែម្តង ក្រុងទាំងពីរបានយកចិត្តទុកដាក់ជាខ្លាំងទៅលើបរិស្ថាន មិនថាមានការសាងសង់លំនៅស្ថាន ឬផ្លូវអ្វីនោះទេ គឺមិនចោលបានឡើងនូវបរិស្ថានស្អាត និងបេតិកភ័ណ្ឌជាតិ ។ ការរៀបចំក្រុងក៏ជាផ្នែកមួយទៀតដើម្បីរក្សា**សន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម** ដោយគេបានកែប្រែសំណង់មិនរៀបរយឲ្យទៅជាកន្លែងថ្មីមួយសម្រាប់ការអភិវឌ្ឍន៍។ ដើម្បីអភិវឌ្ឍន៍កត្តាទាំងអស់ខាងលើឲ្យបានល្អប្រសើរទៅមុខរលូននោះ ទីក្រុងទាំងពីរចាំបាច់តម្រូវឲ្យមាននូវផែនការយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីធ្វើអភិវឌ្ឍន៍ឲ្យចំគោលដៅ និងមិនចំណាយខាតបង់ពេលវេលា និងថវិកាជាតិ ។

សរុបមកការរៀបចំទីក្រុងទាំងពីរ គឺពិតជាមានសារៈសំខាន់ណាស់ព្រោះកាលណាយើងរៀបចំទីតាមលក្ខណៈបច្ចេកទេសមានផែនការ និងប្លង់ត្រឹមត្រូវគឺធានាបានគុណភាពនៃសំណង់មានសោភ័ណ្ឌភាពសន្តិសុខ សណ្តាប់ធ្នាប់ល្អ ហើយការរៀបចំទីក្រុងនេះគឺមាន កត្តាជម្រុញសំខាន់ ៥ គឺ កំណើនប្រជាជន កំណើនសេដ្ឋកិច្ច កំណើនលំនៅស្ថាន និងការប្រើប្រាស់ដី និងដើម្បីអភិរក្សបេតិកភ័ណ្ឌ និងបរិស្ថាន និងដើម្បីសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម ។

# ឧបសម្ព័ន្ធ

# អនុសាសន៍

យោងតាមការបកស្រាយខាងលើយើងឃើញថាភ្នំពេញ នឹងប្រទេសសង្ហបុរីគឺមានការរីកដុះដាលទៅគ្រប់ទិសតំបន់យ៉ាងឆាប់រហ័ស ជាមូលហេតុនាំឲ្យមានការរីកចម្រើននូវគ្រប់វិស័យជាពិសេសមានការរីកចម្រើនទៅលើ ប្រជាសាស្ត្រ លំនៅស្ថាន និងសេដ្ឋកិច្ច ទន្ទឹមនឹងការចំរើននេះក៏បានបង្ហាញឲ្យនូវចំនុចអវិជ្ជមានមួយចំនួនដែលបង្កមកពីការរីកចំរើននោះដែលមានដូចជា៖ កត្តាប្រជាសាស្ត្រ នៅពេលដែលប្រជាជននៅក្នុងប្រទេសមួយ ឬក្នុងក្រុងមួយមានការកើនឡើងខ្លាំងពេក នឹងនាំឲ្យមានបញ្ហាប្រឈមដូចជា ការខ្វះខាតនៃលំនៅស្ថាន សេវាសុខភាព នឹងបញ្ហាប្រឈមដែលទីក្រុងភ្នំពេញតែងតែជួបប្រទះគឺ ការកកស្ទះចរាចរណ៍ និងការកើនឡើងនៃការធ្វើឲ្យកង្វក់នៃបរិស្ថាន ។ កត្តាលំនៅស្ថានយើងមើលឃើញថាទោះបីជានៅទីក្រុងភ្នំពេញសំបូរទៅដោយលំនៅស្ថានល្អប្រណិត ខ្ពស់បែបណាក៏ដោយ ក៏តំបន់មួយចំនួនធំនៅតែមានភាពអនាធិបតេយ្យ និងលំនៅស្ថានមានតម្លៃថ្លៃហួសសមត្ថភាពរបស់ប្រជាជន ។ កត្តាសេដ្ឋកិច្ចបើយោងតាមការស្រាវជ្រាវ និងការឃើញជាក់ ស្តែងជាប្រចាំឃើញថាប្រជាជនក្នុងប្រទេសកម្ពុជាដែលធ្វើការងារនៅក្នុងរោងចក្រគឺទទួលបាននូវ ប្រាក់ខែតិចតួច និងទំនិញដែលនាំចូលមកពីក្រៅប្រទេសមានតម្លៃថ្លៃ ចំនែកឯប្រទេសសង្ហបុរីក៏ជួបនូវបញ្ហាប្រជាសាស្ត្រនេះដែរដោយមានការខ្វះខាតលំនៅស្ថាន និងការបែងចែកដីធ្លីប្រើប្រាស់ តែផ្ទុយទៅវិញប្រទេសង្ហបុរីគឺជាប្រទេសដែលមានលំដាប់សេដ្ឋកិច្ចពិភពលោក និងមានលំស្ថានប្រណិតជាច្រើន ដើម្បីជាការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ ក្រុមខ្ញុំទាំងពីរខ្ញុំសូមមានយោបល់ដូចតទៅដូចជា៖

សូមអំពាវនាវដល់សាលារាជធានីភ្នំពេញ និងមន្ត្រីគ្រប់ជាន់ថ្នាក់ សូមជួយយកចិត្តទុកដាក់ទៅលើបញ្ហាប្រឈមដែលទាក់ទងទៅនឹងបញ្ហាកំណើនប្រជាជនខ្លាំងនៅក្នុងក្រុង ដូចជា សេវាសុខភាព អំពើល្មើសច្បាប់គ្រប់រូបភាព និងបញ្ហាលំនៅស្ថាន ព្រមទាំងសេដ្ឋកិច្ចដោយរកវិធីលើកស្ទួយផលិតផលក្នុងប្រទេស និងសូមឲ្យពន្លឿនការអនុវត្តន៍គម្រោង និង អនុវត្តន៍គម្រោងតាមប្លង់គោលឲ្យចំនុច និងមានប្រសិទ្ធភាព ។

សូមអំពាវនាវដល់សាលារាជធានីភ្នំពេញ ឲ្យជួយដោះស្រាយនូវបញ្ហាការកកស្ទះចរាចរណ៍ដោយបង្កើតចំណតរថយន្តសាធារណៈ និងរថយន្តសាធារណៈ កាត់បន្ថយការប្រើប្រាស់រថយន្តឯកជន និងការពេញលើផ្លូវសាធារណៈ ។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

១.ច្បាប់រដ្ឋធម្មនុញ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣

២.គម្រោងប្លង់គោលរាជធានីភ្នំពេញឆ្នាំ ២០២០

៣.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុង ឆ្នាំ ២០០៥-២០១៥

៤.ផែនការយុទ្ធសសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ឆ្នាំ ២០១២-២០២០

៥.សៀវភៅ ព្រឹត្តិបត្រ រដ្ឋបាលរាជធានីភ្នំពេញ បោះពុម្ពផ្សាយ ថ្ងៃ ទី ១ ខែ ឧសភា ឆ្នាំ ២០១៦

៦.សៀវភៅនីតិនគរូបនីយវិទ្យារៀបរៀងដោយ លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា ក្នុងឆ្នាំសិក្សា ២០១៦-២០១៧

៧.សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរ ខែវិច្ចការ ឆ្នាំ ២០០៩

៨.វចនានុក្រមខ្មែរសម្តេចសង្ឃរាជជួនណាត

៩. www.everyday.com.kh

១០. www.tourismcambodia.com

១១.សៀវភៅ ភ្នំពេញ កំណើន និងការផ្លាស់ប្តូរការធ្វើជំរឿនប្រជាជនទូទៅឆ្នាំ ១៩៩៨ ២០០៨ -

១២. http://phnompenh.gov.kh

១៣. http://vovworld.vn

១៤. senith.wordpress.com

១៥. www.airvuz.com ( Explore Phnom Penh City)

១៦. https://en.wikipedia.org/wiki/Phnom_Penh

១៧. https://en.wikipedia.org/wiki/Singapore

# ឧបសម្ព័ន្ធ

# បញ្ជីរាយឈ្មោះ

# ឯកសារ

# បញ្ជីរាយឈ្មោះឯកសារនៅក្នុងឧបសម្ព័ន្ធ

១.និមិត្តសញ្ញាសាលាក្រុងភ្នំពេញ

២.រូបភាព

-រូបភាពឧបសម្ព័ន្ធ

-គម្រោងបែងចែកតំបន់ប្រភេទដីធ្លីសម្រាប់អនាគត ២០២០

៣.អនុក្រិត្យស្តីពីការគ្រប់គ្រងដីរដ្ឋ

៤.ប្លង់គោលរាជធានីភ្នំពេញ

៥.ប្រវត្តិនៃការរៀបចំប្លង់គោលរាជធានីភ្នំពេញ

៦.ឯកសារពីគ្រោះ

# ឧបសម្ព័ន្ធ ទី ១

# ឧបសម្ព័ន្ធ ទី ២

# រូបភាពឧបសម្ព័ន្ធ
# ភ្នំពេញ

រូបភាពឧបសម្ព័ន្ធទី ១



សាលាភូមិន្ទរដ្ឋបាល



សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

និង

វិទ្យាសាស្ត្រសេដ្ឋកិច្ច



សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

រូបភាពឧបសម្ព័ន្ធទី ២




សាកលវិទ្យាល័យភូមិន្ទកសិកម្ម



សាកលវិទ្យាល័យជាតិគ្រប់គ្រង




វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា




វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ឧបសម្ព័ន្ធរូបភាពទី ៣

# ផែនទីរាជធានីភ្នំពេញ



- ផ្ទៃដីសរុប = ៦៧៨ គ.ម២
- ប្រជាជន = ១.៤៤៥.៨៨៨ ស្រី ៧៦៥.៤៦៦ (ឆ្នាំ២០១៤)
- ចំនួនគ្រួសារ = ២៧៨.៧៤២
- ដង់ស៊ីតេ = ២.១៣២ នាក់/គម២
- ខណ្ឌ = ១២
- សង្កាត់ = ៩៦
- ភូមិ = ៩០៩

ឧបសម្ព័ន្ធរូបភាព ទី ៤



ឧបសម្ព័ន្ធរូបភាព ទី ៥



ភ្នំពេញថតពីខាងលើ

ឧបសម្ព័ន្ធរូបភាព ទី ៥



ទន្លេនៃទីក្រុងភ្នំពេញ

ឧបសម្ព័ន្ធរូបភាព ទី៦



ឧបសម្ព័ន្ធរូបភាព ទី ៧

| | ១៩៩៨ | ២០០៨ | ការវិវត្តន៍ | ការប្រមាណចំនួនប្រជាជននាឆ្នាំ២០១៨ |
|---|---|---|---|---|
| ខណ្ឌឬស្សីកែវ | ១៨០៦៦៨ | ២៥១ ៩២២ | ៧៨ % | ប្រជាជនចំនួន៤៤៧៧០០នាក់ |
| ភ្នំពេញ | ៩៩៩៨០១៥ | ១ ១៦៥ ២០១ | ១៦,៥ % | |

## ការធ្វើសន្ទស្សន៍នៃចំនួនប្រជាជនជាមួយនិងគំរោងលំនៅដ្ឋានថ្មីៗ

| | គ្រួសារមានទំហំមធ្យម | ២០១០ លំនៅដ្ឋាន | ប្រជាជន ២០១០ នាក់ | ២០១៥ លំនៅដ្ឋាន | ប្រជាជន ២០១៥ នាក់ |
|---|---|---|---|---|---|
| លំនៅដ្ឋានជាផ្ទះល្វែង | ៦,៧ | ១៣៣៤ | ៨៩០០ | ១៣៣៤ | ៨៩០០ |
| វីឡា | ៧ | ១៣៧ | ៩៥៩ | ១៣៧ | ៩៥៩ |
| ទីក្រុងរណបកាមក (ខុន-ដូ និង វីឡា) | ផ្នែក១: ៤,២<br>ផ្នែក ២: ៥,៣ | ១០០១ | ៤៦១១ | ៥៦០០ | ៣០ ០០០ |
| ទីក្រុងរណបក្រុងភ្នំពេញ (វីឡា) | ផ្នែក១: ៧<br>ផ្នែក២: ៥,៣ | ៤៨៧ | ៣៤០០ | ៥០០០ | ២៦ ០០០ |
| **ចំនួនធ្វើចរាចរសរុប** | | **២៩៥៩** | **១៧៩០០** | **១២០៧១** | **៦៥ ៨០០** |

ឧបសម្ព័ន្ធរូបភាព ទី ៨



CAMKO CITY

ឧបសម្ព័ន្ធរូបភាព ទី ៩



ឧបសម្ព័ន្ធរូបភាព ទី ១០







GRAND PHNOM PENH

ឧបសម្ព័ន្ធរូបភាព ទី ១១



ឧបសម្ព័ន្ធរូបភាព ទី ១២



ឧបសម្ព័ន្ធរូបភាព ទី ១៣





ឧបសម្ព័ន្ធរូបភាព ទី ១៩



ឧបសម្ព័ន្ធរូបភាព ទី ១៥



ឧបសម្ព័ន្ធរូបភាព ទី ១៦



ឧបសម្ព័ន្ធរូបភាព ទី ១៧



ឧបសម្ព័ន្ធរូបភាព ទី ១៨





ឧបសម្ព័ន្ធរូបភាព ទី ១៩





ឧបសម្ព័ន្ធរូបភាព ទី ២០

នៅតាមដងទន្លេសាប ផែកាណូតបច្ចុប្បន្ន សំរាប់កាណូតដឹកអ្នកដំណើរ និង កាណូតសំរាប់ការជិះកំសាន្ត

Sur le Tonlé Sap, le débarcadère actuel des bateaux à passagers et des bateaux de promenade

© Teng Peng Seang



ឧបសម្ព័ន្ធរូបភាព ទី ២១



ឧបសម្ព័ន្ធរូបភាព ទី ២២



ឧបសម្ព័ន្ធរូបភាពទី ២៣




ទិន្នន័យសំនង់នានា ឆ្នាំ ២០១១

ឧបសម្ព័ន្ធរូបភាពទី ២៤

| | | | | |
|---|---|---|---|---|
| ខណ្ឌដង្កោ | – | ៣៨,៧៨៨.០០ | ២២,០៦៧.០០ | ៤៥១,៧៦៧.០០ |
| ខណ្ឌសែនសុខ | – | ៣,៨៦០.០០ | ៧,៧១០.០០ | ១០៥,៥២៨.០០ |
| ខណ្ឌឫស្សីកែវ | ៧,០២០.០០ | ១៨,៤០៩.០០ | ៦២,២៤១.០០ | ១៨៦,៥២៨.០០ |

****ប្រវែងផ្លូវគិតជា ម៉ែត្រ (ទិន្នន័យទទួលបានពីមន្ទីរសាធារណការ និងដឹកជញ្ជូន)

## ស្ថិតិយានយន្ត (ខែសីហា ២០០៦ ដល់ ខែសីហា ២០១១)

| ល.រ | ប្រភេទ | ចំនួនចុះបញ្ជី |
|---|---|---|
| ១ | រថយន្តធុនតូច | ៩៤,៧៨២ គ្រឿង |
| ២ | រថយន្តធុនធំ | ៨,២១៣ គ្រឿង |
| ៣ | ទោចក្រយានយន្ត | ៤៦២,៦២៣ គ្រឿង |
| ៤ | ត្រីចក្រយានយន្ត | ១,១៣៧ គ្រឿង |
| ៥ | ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក | ៣,៣៣៦ គ្រឿង |

## អត្រាប្រជាជនក្រីក្រ(គិតចាប់ពី២០០៥-២០១០) ជា%

| ខណ្ឌ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ |
|---|---|---|---|---|---|---|
| ចំការមន | ៦,៨៩ | ៦,០៥ | ០,០៣ | ០,០២ | ០,០០ | ០,០០ |
| ដូនពេញ | ៤,៣៦ | ៤,៣៩ | ០,០០ | ០,០០ | ០,០០ | ០,០០ |
| ៧មករា | ២,២២ | ១,៧៨ | ០,០០ | ០,០០ | ០,០០ | ០,០០ |
| ទួលគោក | ៥,៩២ | ៥,៦៣ | ០,០០ | ០,០០ | ០,០០ | ០,០០ |

ស្ថិតិយានយន្ត

# រូបភាពឧបសម្ព័ន្ធ
# សិក្ខបុរី




# ផែនទីប្រទេសសិង្ហបុរី

ឧបសម្ព័ន្ធរូបភាព ទី ២




និមិត្តសញ្ញានៃប្រទេសសិង្ហបុរី Merlion

ឧបសម្ព័ន្ធរូបភាព ទី ៣





កោះជូរុង

ឧបសម្ព័ន្ធរូបភាព ទី ៩







កោះតេកុង

ឧបសម្ព័ន្ធរូបភាព ទី ៥






# កោះអ៊ូប៊ីន

ឧបសម្ព័ន្ធរូបភាព ទី ៦





<u>កោះសេនតូសា</u>

# ឧបសម្ព័ន្ធ ទី ៣

# ឧបសម្ព័ន្ធ ទី ៤